ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១១

លេខ ៤, ៥, ៦, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨២

គ.ស. ១៩៣៩

# បញ្ជីរឿង


| | ទំព័រ |
|---|---|
| ១ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . | ៣ |
| ២ — សិលាចារិកនគរវត្ត និងបទានុក្រម . . . . . . . . . . . . | ១១ |
| ៣ — ប្រជុំពាក្យកាព្យភាគទី ២ (តទី ៤) . . . . . . . . . . . . . . | ៤៣ |
| ៤ — ព្រហ្មចរិយកថារបស់ព្រះមហាលេស (តនឹងចប់) . . . . . . . . | ៥៥ |
| ៥ — រឿងព្រេង — គ្រូនិងសិស្ស . . . . . . . . . . . . . . . . . | ៧១ |
| ៦ — លទ្ធិទំនៀមទម្លាប់ខ្មែរ ពិធីលើកកសី . . . . . . . . . . . . . | ៧៧ |


## រូបក្រៅរឿង


ប្រទេសលាវវៀងចន្ទន៍ វត្តថាខែក . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


| | Pages. |
|---|---|
| 1. Informations diverses | 3 |
| 2. Les inscriptions de Nokor-Vat (suite) | 11 |
| 3. Recueil des Poèmes du roi Préas Bat Samdach Préas THAMMARÉACHÊA, 2e partie. (suite) | 43 |
| 4. Brahmacariyakathâ par Vénérable Préas Maha SÈS (suite). | 55 |
| 5. Contes populaires cambodgiens inédits: Conte du Kroû et de son Sœus (le maître et son élève). | 71 |
| 6. Mœurs et coutumes cambodgiennes: Cérémonie pour rehausser sa gloire | 77 |

HORS TEXTE:

| | |
|---|---|
| Vientiane: Pagode de Thakhek | 1 |



ប្រទេសណាំរវៀងបន្ទូន់ វត្តប៉ាខែក

ដំណឹងផ្សេងៗ

# អំពីសៀវភៅពុទ្ធសាសនា

# ជាភាសាអង់គ្លេស

មានអ្នកប្រាជ្ញធំជាតិអង់គ្លេសម្នាក់ឈ្មោះលោក ឯ. ជ. ថូម៉ាស បានបោះពុម្ពសៀវភៅពុទ្ធសាសនាមួយផ្សាយឲ្យឈ្មោះថា «ពុទ្ធវចនៈនៃពុទ្ធសាសនា ក្នុងបឋមពោធិកាល ( *Saintes écritures du Bouddhisme de la première période* ) ។ លោកបានប្រមូលគម្ពីរភាសាបាលី ហើយប្រែចេញជាភាសាអង់គ្លេស មានរឿងពុទ្ធប្រវត្តិ; ការប្រតិបត្តិតាមលទ្ធិបព្វជិត និងលទ្ធិគ្រហស្ថ, ឧបាយស្វែងរកមោក្ខធម៌, អំពីវិន័យ, អំពីកម្ម, អំពីហេតុផលនៃសំសារវដ្ត (បច្ចយាការ?) និងការចាត់របៀបកសាងអារាមសម្រាប់សង្ឃ ។

ដោយការសិក្សាគម្ពីរពុទ្ធវចនៈជាភាសាសំស្ក្រឹត និងសេចក្ដីប្រែក្នុងគម្ពីរនោះ លោក ឯ. ជ. ថូម៉ាស អាចយល់ដំណើរសេចក្ដីក្នុងគម្ពីរបាលីខ្លះ ដែលគេយល់ឃើញលទ្ធិផ្សេងៗគ្នា ដោយផ្គូរគំនិត ក្នុងផែនដីឥណ្ឌៀ សម័យនោះ ។

*

*　　*

# អំពីការសិក្សាសម្រាប់បណ្ដាជន នៅប្រទេសឥណ្ឌៀ

យើងបានដំណឹងថា នៅប្រទេសឥណ្ឌៀទើបបង្កើតសមាគមមួយ ហៅថា « សមាគមឥណ្ឌៀ ដើម្បីជួយជ្រោមជ្រែងការសិក្សារបស់បណ្ដាជន » មានគោលសំខាន់ៗ ដូច្នេះ គឺ:

១) ដើម្បីកំចាត់បណ្ដាកស្ដ្រដែលល្ងង់ខ្លៅឲ្យអស់ទៅអំពីប្រទេសឥណ្ឌៀ ។

២) ដើម្បីជួយជ្រោមជ្រែងប្រជាជនជាតិឥណ្ឌៀឲ្យទៅជាប្រជាជនល្អឡើង ។

៣) ដើម្បីនាំគ្នាប្រឹងប្រែងស្វែងរកឧបាយ វិធីធ្វើឲ្យចំរើនចរិយា ទឹងចំណេះវិជ្ជារបស់បណ្ដាជនប្រុសស្រី ដែលនៅក្នុងវ័យក្មេងកុមារ តែរកកន្លែងរៀនសូត្រពុំបាន ។

អ្នកមុខអ្នកការធំៗ ជាតិឥណ្ឌៀទឹងជាតិអង់គ្លេស ប្រួមគ្នាធ្វើការដ៏ប្រសើរនេះ ។

⁂

# អំពីពុទ្ធសាសនានៅស្រុកទីបេត៍

ព្រះរាជបណ្ណាល័យ បានទទួលកាសែតក្រយការរបស់ក្រុមសមាគមភូមិសាស្ត្រ នៅប្រទេសអង់គ្លេស កាលពីខែដេសម្ប៊្រឆ្នាំ ១៩៣៧ នោះ មានរូបថតពណ៌ផ្សេង ៗ អំពីប្រទេសទីបេត៍ ៗ នេះជាប្រទេសកាន់ពុទ្ធសាសនាប៉ែកខាងមហាយាន តាំងនៅទិសខាងជើង ឆៀងខាងកើតនៃស្រុកឥណ្ឌា ក្នុងកាសែតនោះនិយាយថា មានវត្តមួយមានចំនួនលោកសង្ឃដល់ទៅ ៥.៥០០ រូប វិហារនោះមានកំពូលជាមាស (?) ឯក្បាច់រចនាវត្តនោះសំដែងឲ្យឃើញសេចក្តីអស្ចារ្យគួរស្ញប់ដែលគេកសាងឡើងនៅលើកំពូលភ្នំខ្ពស់ដាច់ស្រយាល ដែលមាននៅក្នុងលោកនេះ ។ ឃើញមានកុដិមួយដំកល់ព្រះពុទ្ធទ្រង់ធ្វើសមាធិនៅត្រង់កណ្តាលបឹងមួយ ។

ក្នុងក្រុងឡាសា ( នៃប្រទេស ) នោះមានទីសំកប់ដើរកំសះលមួយ ដែលពុទ្ធសាសនិកតែងដើរទៅមកជាច្រើនក្នុង ១ ថ្ងៃ ៗ មានដុំថ្មជាច្រើនដែលនៅក្បែរថ្នល់នោះ គេឆ្លាក់ជាដំណាងព្រះពុទ្ធធ្វើអាការផ្សេង ៗ ពីគ្នា ( ព្រះពុទ្ធធ្វើមុទ្រាច្រើនអន្លើផ្សេង ៗ គ្នា ) ហើយមានពួកឧបាសកក្រាបថ្វាយបង្គំសុំពរជ័យមង្គល ។

ក្នុងពពួករូបមានពណ៌ផ្សេង ៗ នោះ ឃើញមានរូបលោកចៅអធិការវត្តពាក់ស្បង់ចីវរ (ពាក់អាវកាសារ៍?) ក្រាស់មានពណ៌លឿង ហើយ

នៅខាងក្រោយវិហារនោះ មានកំណាត់ថ្មមួយធំក្រាស់ពណ៌ក្រហមដណ្តប់គ្របមួយជាន់ទៀត ដ្បិតនៅស្រុកទីបេត៍នោះរងាណាស់ ។ នៅឱកាសបុណ្យឆ្នាំថ្មីពួកលោកសង្ឃតែងប្រៀងកំនៅក្នុងវត្ត មានរូប ១ ទៀត ឃើញមានលោកសង្ឃឈរដម្រៀបគ្នាជុំត្រៃយ៉ោងធំសម្បើម នៅខាងមុខមណ្ឌបមាសមានក្បាច់ចម្លាក់ ៗ តាមដោយពិត ទីអស់នោះសុទ្ធតែជាភ្នំខ្ពស់ ៗ មានតែទឹកសន្សើមសក្បុះ ។

*

* *

# អំពីសសរថ្មបុរាណ

តាមកាសែតទេះភ្លើង (ស្រុកឥណ្ឌៀ) ចុះខែស្ដូយេតឆ្នាំ ១៩៣៨ ដែលព្រះរាជបណ្ណាល័យបានទទួលនោះ ឃើញមានរូបថតជាច្រើនដែលមានប្រយោជន៍ដល់អ្នកកាន់ពុទ្ធសាសនា ។

ក្នុងចំណោមរូបនោះ ឃើញមានរូបសសរបស់ព្រះបាទធម្មាសោកមួយ កំពស់ ៣៦ ជើង (១ជើង ៣០ សង់ទីម៉ែត្រ) ធ្វើដោយថ្មជា មានចារិកពជប្រកាសផង ។ ពីដើមមកមានរូបគោមួយទំនៅខាងលើ ប៉ុន្តែឥឡូវបាត់បង់ទៅហើយ សសរនេះនៅក្នុងស្រុក "សាឡាហាប័ត" (ស្រុកឥណ្ឌៀ) ។

*

* *

# អំពីមហាវិទ្យាល័យបុរាណ

ក្នុងកាសែតដែលនោះ មានសេចក្ដីដំណាលអំពីសាលាមហាវិទ្យាល័យជាន់ចាស់នៅស្រុកឥណ្ឌា ហើយមានរូបចេតិយយ៉ាងល្អមួយនៅវត្តនាឡន្ទមហាវិហារ កន្លែងនេះជាទីតាំងមហាវិទ្យាល័យ ពុទ្ធសាសនាប៉ែកខាងមហាយានជាយូរអង្វែងណាស់មកហើយ ជាទីមួយយ៉ាងសំខាន់សម្រាប់ជាទីប្រជុំរៀនសូត្រ មិនមែនត្រឹមតែរៀនសូត្រចំណេះ ពុទ្ធសាសនាប៉ែកខាងមហាយានប៉ុណ្ណោះទេ គឺជាទីសម្រាប់សិក្សាគម្ពីរវេទរបស់ពួកឥណ្ឌូ ( ព្រាហ្មណ៍ ) ទៀតផង ។

លុះកាលតមកមានពួកខ្មាំងសត្រូវ ចូលទៅកាយបំផ្លាញកន្លែងអស់នោះឲ្យខូចទៅ ៗ តមកក្រោយទៀត ត្រឡប់តាំងឡើងជាមហាវិទ្យាល័យពុទ្ធសាសនាប៉ែកខាងមហាយាន មានសេចក្ដីរុងរឿងឡើងវិញម្ដងទៀត ។ តមកប្រមាណ ១.០០០ ឆ្នាំទីនោះ នៅជាទីរៀនសូត្រពុទ្ធសាសនាដដែល ប៉ុន្តែគ្រាក្រោយមកទៀត មានគ្រោះថ្នាក់ដោយស្នាដៃពួកមហាហ្មតធ្វើបំផ្លាញឲ្យបាក់បែកខូចខាតទៅអស់ ៗ ដល់មកឥឡូវនេះដែលគេបានដឹងថា ទីនោះជាទីប្រជុំសិក្សាចំណេះពុទ្ធសាសនាមួយយ៉ាងធំដោយសារពួកពុទ្ធសាសនិកជនជាតិចិន ធ្វើដំណើរទៅនមស្សការទឹងពួកទីបេត៍ដែលបានកត់ត្រាទុកមកថា ទីនុ៎ះជាទីប្រជុំរួមចំណេះវិជ្ជាខាងព្រះពុទ្ធសាសនា ហើយច្រើនស្កុកទៅដោយអនុស្សាវរីយ៍ (ចេតិយ) ៗ ចំ-

ណែកឯពួកអ្នកធ្វើការខាងបុរាណវត្ថុក៏បានប្រទះឃើញមានព្រះពុទ្ធរូបនឹងរូបព្រះពោធិសត្វជាចំនួនច្រើន ។ មួយវិញទៀត នៅមហាវិទ្យាល័យសាសនានោះ ពួកសិស្សត្រូវសិក្សាជាវេលា ១២ ឆ្នាំហើយត្រូវចេះភាសាសំស្ក្រឹតផង ។ សិស្សដែលមានទោសធ្ងន់ជាបំផុត ត្រូវបណ្តេញចេញពីសាលាមហាវិទ្យាល័យ ។

មហាវិទ្យាល័យមួយនេះហើយ ដែលជាទីសិក្សារបស់នានាជាតិ បណ្តាពួកសិស្សទាំងគ្រូ ដែលសំណាក់នៅក្នុងសាលានោះសឹងមានសេចក្តីសុខក្សេមក្សាន្ត ហើយចំប្រឹងប្រែងរៀនសូត្របំណេះវិជ្ជាខាងព្រះពុទ្ធ· ដីកាឲ្យចេះដឹងកាន់តែជ្រាលជ្រៅឡើងទៅប៉ុណ្ណោះ ។

## អំពីឧម្មគ្គ (ផ្លូវ) របស់ខុងជឺ

កាលនៅថ្ងៃ ៤ ខែយ៉ាំងវីយេរ ឆ្នាំនេះ កងទ័ពយ៉ីពុនបានវាយយកបានក្រុងគូប៉្ហូ ខែត្រសាន់ទុង (ស្រុកចិន) ។

ក្រុងគូប៉្ហូនេះជាទីគោរពសក្ការបូជារបស់បណ្តាពស្តចិនទាំងមូល ពីព្រោះខុងជឺដែលជាអ្នកប្រាជ្ញចិនបានមកចាប់កំណើត ហើយធ្វើដំណើរចាកលោកនេះទៅវិញនៅក្នុងទីនោះដែរ ។

មួយវិញទៀត ពិតមែនតែស្រុកចិនមានចម្បាំងនឹងបាស់ប្រោះច្រើនលើកច្រើនគ្រា តែត្រង់ឧម្មគ្គដែលបញ្ចុះសពខុងជឺនឹងវិហារមួយដែលគេ

សាសនទុទ្ធិសចំពោះមហាអ្នកប្រាជ្ញនេះ (ជិត) ចំនួន ២៥០០ ឆ្នាំមកហើយ នៅក្នុងក្រុងគូហូ គេប្រើនវែថពាំមិនឲ្យខូចខាតបន្តិចសោះ ។

ពួកញាតិរបស់ខុងជឺមាននៅក្នុងក្រុងនេះជាប់រហូតមកដល់សព្វថ្ងៃនេះ ព្រះចៅយ័ពុនបានតាក់ព្រះរាជបំរើមួយក្រុម ឲ្យទៅទូលសួរក្សត្រចិនមួយអង្គព្រះនាម "គន់តេវែង" ដែលជាប់ជាញាតិសាលោហិតទីង ខុងជឺ ៧៥ ដំណមកហើយ តើព្រមទទួលសិរីភពសម្បត្តិជាមហាក្សត្រដែនដីចិនឬទេ ក្សត្រនោះទ្រង់ប្រកែកពុំព្រមទទួលហើយមានបន្ទូលថា តាំងពីខុងជឺអនិច្ចកម្មទៅ វង្សានុវង្សនេះមិនដែលស្វែងរកព្រះអំណាចឡើយ ។

ព្រះរាជបណ្ណាល័យ មានអំណរសូមដឹកបជូនដំណឹងដល់មិត្តានុមិត្ត ដ្បិតទើបនឹងបានទទួលរូបថតយ៉ាងល្អ ១ សំរាប់ផ្ទះធ្វើជាកុន រូបថតទាំងឡាយនេះ នឹងប្រគល់ឲ្យរថយន្ត ដែលដឹកសៀវភៅព្រះរាជបណ្ណា-ល័យ មួយវិញទៀត ក្នុងពពួកខ្សែរូបថតកុនទាំងឡាយនេះមានមួយខ្សែ ផ្ទុះអំពីរឿងអ្នកប្រាជ្ញ ខុងជឺកាលរស់នៅឡើយ ហេតុនេះមិនត្រឹមតែ បណ្តាជនជាតិខ្មែរយើងដែលនៅក្នុងក្រុងភ្នំពេញនេះទេ ទាំងអ្នកដែលនៅខេត្តក្រៅក៏នឹងបានមើលហើយនឹងដឹងរឿងរ៉ាវដ៏មានប្រយោជន៍អំពីប្រវត្តិ ខុងជឺដែលជាអ្នកប្រាជ្ញធំមួយនៅក្នុងអាស៊ីយ៉ាទិកយើងនេះ អ្នកប្រាជ្ញនេះ កើតក្រោយព្រះពុទ្ធជាម្ចាស់និព្វានទៅចំនួន ៦៤ ឆ្នាំ ។

# សិលាចារឹកជតវត្ត

និង

# បទានុក្រម

លេខ ៣១

N° 34 (A)

N° 34

(១) បុពិត្រ [ទេះគឺ] រោះត្រីពិត្រសុច្ចរិត្តសារទ្វាមហារិ បុលអតុ (២) ល្បអត្តិរេកឯតរកតាប្រាមោជោតិបង្កុបរត្នរិនពិន្ទ (៣) អាបិន្តទិត្រយ្យបិត្តិមាគោជព្បៀរោជសុគណ្ឋរបវិរ (៤) សរ សោមន៍ស្បាភិលង្កិតរិកសិសោតរបរបទុំមាភា (៥) មបោអត្តិ សៃក្រែសមៃសុមហុត្តិមហោតំមសមន្ធអា (៦) សទារិកបិត្ររិធ សុច្ចរិត្តភាប្ច សត្យអាទិស្នាណប្រ (៧) និជានឆៃសំតែបព្រះបរិ ទុបុពិត្រក្រាបប្វាយបង្គម (៨) ប្រនំទូលល្អងធូលិព្រះគ្រីវិរបាទ យុគ្គលវិមលត្រៃឆៃសំ (៩) តែបព្រះសិសាក្យាមុណិត្រៃគោតំមប រម្មបុពិត្រក៍ម្រតៃ (១០) ឯយើង ស្តែបប្កើងនូអដ្ឋតូរវិសតមុគ្គល អំពលនូលា (១១) យលក្ខុកុងបក្ក អនគ្សអនាចំពិព៌ារសបារ ព្រះអង្គ (១២) ជាព្ធំនាក់ត្រៃយត្រានរោហានសំពោរត្នរង ឱតុងស (១៣) ម៉ារនោ៉ នូអាបន៍មសត្ធដោងឆ្ពាងលៃងរិត្ត សង្ហារស្មៃ (១៤) ប្រវិលមហានុព្ទស្រែមុទពោលមុនអើកិលេស្ប ស្មុង (១៥) ព៌ន្មោរយភព្យជាតិកត្តាលសាណ្នាទៃសំតែបព្រះបរ

(១៦) វិទូខ្ញុំមអំប៌សក្រែងបាទធ្វើនូវអំពើហអកុសលអំពល (១៧) នូប់តុតិស័យ្យោជាទ្វារទិដ្ឋិទ្រិសតមសនូបតុទសបេត្ត (១៨) សើកិ វព្ទកនូវប្រកាយស្មើតព្ទតសង្ឃារបីអ្សិតខ្លួមអា (១៩) សារ ជាភាព្យាធផោងសិងតប្បៀតប្បៀណ នៃទើបសំ (២០) តបព្រះបរិទូមោគគិតជញ្ជឹងវម្តិងអានិត្តអនិ (២១) ហាអាយុខៃយ្យាកាំម្មខៃនានិតសជន្មាពិត្តិទោបរេ (២២) លាកនា្យបិតូបធ្វញប្លាយសំពៅអ្សិតឯពុំទាក ក្រៃលែង (២៣) នៃសំតែបព្រះអ៊ិរន្តតត្រៃបរំមបុពិត្រ ។ លុតលសព្ទមស្ត (២៤) មុង្គលជ្យោតិរេក ១៦០៦ សក្កជូតនក្សត្រ ៩ រោជ (២៥) កាត្តិកពុទ្ធពារសាណ្ណាភ្យជាស្រែនៃសំតែបព្រះបរិ (២៦) ទូមានបិតតំម្លាសាទ្វាហាបតើមអំមព្យ ១៦ ឆ្នាំមលុវ៉ិប (២៧) រិល៉ប៉ាលតពតល្ងនៃះព្រះជនបាន ៥៧ ហ្សេ ព្រះ (២៨) អង្គវែងកាតស្រែលែញសាទ្នាំអោកគន្ត្រាតសសំអ្នាងសា (២៩) ធរ៉ាអំម្ភ្តិកុសលធលបុនអំមព្យមុនមោកលុវ៉ិបតល (៣០) តល្ងនៃះព្រះអង្គសាជព្រះមាសព្រះប្រាកអង្គ ១០០ នូ (៣១) ព្រះឆ្លាកប្ផិយ ៣៥ អង្គ

នព្រះអន្តរធាប្អូនអំមព្យ (៣២) មុនមោកអង្គ ១០០ នូព្រះ សីហៀងអង្គ ១ ឥសសំ

No. 34 (2)

(១) នាងព្រះអង្គទុំអម្បាលនោះបានជា ២៣៥ ហៀមោក់ ទ្រុំងសា (២) ទ្វាតាម្មនូព្រះត្រៃរត្នមហាពោធី ៣០ តេម្ម ហៀ ព្រះអង្គសាងព្រះ (៣) ចៃត្យខ្សែបសំរែបសាងព្រះពុទ្ធព្រះធម្ម ព្រះសឃ័ផ្លងនូកបើ (៤) ណាឲយជាទាន ៥ តោង ជិកអន្លុងជីក ស្រោះជុំរះផ្លរិសង្ឃស្ដា (៥) នឱយទាន ៥ តោង ព្រះអងឲ្យទាន ភ្លើងឱយទានទឹកឱយទា ៦) នសំពត្តឱយភោជនាហារត្រកាល ពីសា ឱយទានកន្ទេលអាស(៧)នា ឱយទានគ្រឿងបាយគ្រឿង ទឹកគ្រឿងស្លាម្ល កាំតត្រៃបីរ (៨) ឱយទានកាំតទងកាតពិតាន សាងកំពីព្យហ្វាយព្រះមហាស្រែរ (៩) គ្នាត្រៃបរំម្មបុពិត្រទុំបីទ្វី សង្ឃ សាលា ៥ បញ្ញាំមឱយជាទាន (១០) ហៀព្រះអង្គមានមៃត្រី កុណ្ណាអាស្សូរឥសមេបាបោងផ្ដណាក្ខ (១១) ណាហៅ នៅញាតអំ ម្បាលសង្ហាតមោកខ្វីប្របៃរត្តព្រះអង្គ (១២) ឥសទុំហ្សាយជា

ជញ្ជាំង ៧ ហើយព្រះអង្គមិនមើលយល់ជាទឹម (១៣) ដុនពានប្រ ហ្មានឥតសញ្ញាតសន្តានទុំអុំម្បាលនោះព្រះអង្គ (១៤) ស្មោះត្រោះ ទ្រង់សាទ្វាលើកឱ្យជាទានឥតសញ្ញាតសន្តានទុំដិញ្ចា (១៥) ង ៧ នោះស្រែបហោង បុពិត្រនែះគឺសំហ្លាងសំតែបព្រះបរី (១៦) ទុ ឥតល្វរិព្រះអង្គស្លូមកើតសព្វ ៗ ជាតស្លូមទ័ន្ធពុទ្ធបាទបាំបំម្រើ (១៧ ហាឱ្យឥតសសៃប្ដុក្តិ ខ្ញុំមស្លូមមានទ្រ៉ាព្វធនកែវរត្នគុណ មាស (១៨) មុណីត្លូបជោតិកសេស្ឋិមុះហើមាអ្យិតថ្មិមបាន ខ្ញុំម ស្លូមកុណ្ណា (១៩) សត្វស្លូមបិត្រកាតអំនោយទានស្មោះសាពន ប្រមានត្លូបព្រះវេ(២០)សន្ធរហោង ខ្ញុំមស្លូមត្លូបតេមេបិត្រអតគេ ហអ្យិតំងហ្មោង សូ (២១) មបីត្រខ្ញុំមល្អហាកគ្លោងជាសំលៃញ ទុំប្រុសទុំគ្រីយ ទោះទោស (២២) អ្នកនិងស្លាបទុលទុក្ខខាប អ្យិតប្រានិស្លូមតោះរង្គោះក្តីជីវិតបា (២៣) ឆវស្សរប្បាជិវិត ខ្ញុំម ស្លូមផ្ដិរត្លូបអំម្បូរព្រះប្រាជ្ញា ខ្ញុំមស្លូមពោង (២៤) ជារណាជីវិត ណត្តំនាកគ្រែ បុពិត្រព្រះមហាស្រីរត្នត្រៃបរម្មបុ (២៥) ពិត្រ ខ្ញុំមស្លូបបំពេញពោធិសម្ភារបារម្មីអំពីនេះទៅរ៉ូបរ៉ាលទាំ (២៦) លអនាគតកាល លុះតលពោធិសត្វ ១០ ព្រះអង្គបំពេញពោធិ

សំ (២៧) ម្ការបាម្មី បានត្រាសប្រជ្ញាសាព្វេជ្ញតាញ្ញាណជា ព្រះពុទ្ធបរប្បូរបួល (២៨) និញានជាសុរ្យេបហើ្យ ឯក្រោយនោះ ឯងអញ្ញខ្ញុំមស្ញូមឱយបាន (២៩) ត្រាស់សប្រជ្ញាសាព្វេជ្ញតាញ្ញាណ ជាព្រះពុទ្ធបំបាត់ទាំមសត្វផោង (៣០) ត្វបកស្លោងព្រះពុទ្ធអំព្យ បុរានវៀងមោកនោះឯងហោង (៣១) បុពិត្រព្រះមហាស្រីរត្ន ត្រៃយបរម្មបុពិត្រ អញ្ញខ្ញុំមឈ្មោះសំ (៣២) តែបព្រះបរវិទ្ធបុ ពិត្រប្រាជ្ញាត្វប្ទេះ ស្ញូមឱយបរប្បូរប្រាកដ្ឋកំនត្រ (៣៣) កុំម្បីមាន ឃ្លាតឃ្លាល្បៀ បុពិត្រស្ញូមធុត ៗ ត្វបសព្វាអាទិស្ឋានផែះហោង

លេខ ៣៤

No 35 (A)

(១) សព្ទមស្តុស្វស្តិស្រីយសព្ទមុង្គលពហុលបេស្តាជ្យោតិរ (២) ក ១៦០៩ នក្សត្រឆ្នាម្មមោះខែមាគ្គ ៧ រោជថ្ងៃយ (៣) ២ ពារសារណា មន្តិតសជំនុម្មអ្នកសំម្តេចមហាសយកាម្ម បុ (៤) ពិត្រនូអ្នកសំតែបព្រះបរិវបញ្ញាបុពិត្រនុអ្នកទារបុពិត្រ នូ (៥) អ្នកត្រៃយ ឯគ្រហសសោតមានបោបាជនុព្រះស្បៃ គាង (៦) វត្ត នុះបោបនាំងោរ នូនាងនាំនាងនៃវជ្យិតុជ្យមិម្ម តស

ន្ទ (៧) កន្ទំអំម្បូលនែះស្បៀងតជាសាក្សិយសុក្ខិវិញ្ញាណនៃនាង
បែន (៨) មានបិត្រកាត្តម្លាសាទ្ធាំមោកលែង (ខ្ញុំ) ១ឱ្យរ័បជា
ព្រៃប្រាម្ប៉ូ (៩) ទិសតតប្បីបីរពោលល្បៀ នែះគឺរោះត្រិពិត្រ
សុប្ចរិត្តសាទ្ធាម (១០) ហាវិបុលអតុលអត្ថរេកឯក្កាភាត្តាប្រមោ
ជោតិបង្កុជ្ឈសុប្ចរ៍ (១១) តវិតពិន្ទអាជិនត្រិណាំបិតិមានោជបភិ
ពោបសុគណ្ឌរបវិរ ស (១២) រម្ភស្សាភិលុក្ខិតវិក្សសោន្ទរ បវិរប
ទំមាភា មហោអត្តិសៃត្រៃសុមៃសុមហុ (១៣) ត្តិមហោតម្ម សម
អសយាំរិក វាចាសិត្យាអន្ទិស្ឋាណាប្រណាំជាណាំនៃ (១៤) នាង
បែនក្រាប្បថ្វាយបង្គមប្រែនមទូលល្អងធូលីព្រះស្រិយវិបា (១៥)
ទយុគ្គុលវិមុលភិបិនត្រៃយ នៃសំតែបព្រះសិសាក្យាមណីព្រះ
(១៦) ស្រិយគោតំមព្រះកំម្រតែងយេង ស្ដេចប្តិងន្ទអដ្ឋតវិរសិទ្ធ
មុង្គលអម្ព (១៧) លនោលាយលាក្ខក្នុងបកអក៌កអនារពិពារ
សហារអ៌ាបនាម្មសត្វ (១៨) ដោងឆ្លោងលែងវិពរសង្សារស្មើ
ហប្រវាលមហោនុព្វស្រមុទ្ទ ពោល (១៩) មុនគិកិលេសទំពាន្ទ
ហារយភុព្វជាតិកន្ទាលសាណ្ណានៃ្យវា (២០) ឯបែនមាន
បិត្រកាតតំម្លាសាទ្ធាំបាបតើមអំពិប្រាម្បុទ (២១) ន្ទបន្ទាំមបាម

ដោយនូវសម្អាងអំពើកុសលផលបុណ្យអំពីមុននោ (២២) លុះតល ឆ្នាំជាសេសេប្ប សេ ហៀ មោកគន្ធាត្រាសំម្អាងសាង (២៣) ព្រះពុទ្ធរូបមាសអង្គ ២ ព្រះប្រាក់ ១២ ព្រះអង្គព្រះសំរិទ្ធអង្គ១ ព្រះ (២៤) សិលាអង្គ ១ ព្រះទេព្វហារូអង្គ ១ ព្រះបទ្ធូអង្គ ១ កាតទុង ៩ (២៥) ផ្គាន ៣ ក្លស ១ សាងភ្នំពាន្ធ ពីរតោង ភ្នំ ៥ ពីរតោង បំបូសក្ត (២៦) ន ៩ តោង សាងកាត្ត ៥ ផ្លុងត្រៃបិរ ៥ វិសប្តន ៤០ សាង (២៧) ភិរគ្នាខ្ញុំឃ្បុបជាសំតែបព្រះស្រិរត្នត្រៃមតោងនេះហោង (២៨) អម្ពើកុសលផលបុណ្យអ្នកនាងបែនទូអម្បាលនេះហោង អាហារ (២៩) អញខ្ញុំប នមាមិ ស្រែបឃ្បបង្គមប្រនំមសិរសាតាក លើប្បុង ទិនេ ៗ សព្វ (៣០) ៗ ប្វៃយ កាលំ ឮតកាល ហោង។ ឱកាស្យបុពិត្រហៀហេតុគេកតេ (៣១) ដះត៏ពាះ នៃអំម្ពេកុសលផលបុណ្យខ្ញុំទូអម្បាលនេះធិព្វសម្បត្តិ (៣២) បុរិប ត្នាំ បុពិត្រហៀស្មូមខ្ញុំបានស្មោសម្បាតទូបិប្រាកាយនោះ អ្ស គឺ (៣៣) សំម្បាតមហាចក្កពត្តរាជមានរិទ្ធិអំនាចអរាជទ្រូងត្ន ទស្សពិត្ត (៣៤) រាជធម្មិទូ ១០ គោរោព្វ ឮតែទានតិងសិល

តោះសព្វ ៗ ជាតកុំម្រេត (៣៥) ហាង ម្យគឺសម្បាតទេវតានៅទា ស្លូគ៌ាយប្រសេដ្ឋប្លាថ្ងៃក្រៃ (៣៦) យលែងទេវតាអោងទុំប្លាយ ម្យសម្បាតនិពាំណាតជាស្ពាណោ (៣៧) ប្រិមព្រៃសតិភាស្ប លែងជាតជាភាមរនោះទៀងប្រាកុត (៣៨) ហាង " សង្ក្រារ ត្តោ ទោះយោបិខ្ញុំមនិងអត្ថោល (៣៩) មាកយោនយោកកំ នេតកើតព្វតភ្យុភុព្វ (៤០) មន្តុលអំម្ពុលគ្ឫត្តសង្ក្រារនា ៗ ក្តិ ម (៤១) ពោបញ្ចាំ ស្លូមខ្ញុំមានប្រាជ្ញាប្លាថ្ងៃ (៤២) វ៉េយមោះ ហិមាដ្ឋបព្រះមហានា (៤៣) គ្គសេនហោង បុរិបត្មាំ បុពិត្រ (៤៤) ហ្សេស្លូមយេងខ្ញុំបានលុះសំ (៤៥( រិទ្ធិត្ថូបក្តិប្រាជ្ញាបិត (៤៦) បិត្តានៃ្សខ្ញុំហោង

*លេខ ៣៣*

No 36 (B)

(១) សត្តមស្តុស្លូស្តិគ្រៀសត្តមុង្គលពហុលបេស្តាជ្យោតិអេក (២) ១៦ ១២ ស្ព៉កមមីន្ពក្បត្រ ១៤ កើតខែហាបៃត ( ៣ ) ថ្ងៃយសោ ពារសាណ្ហិ មន្ទិតសជុំនម្មសំម្តេចព្រះ (៤) សុមុង្គលមហាសយ៌ រាជបុពិត្រ នុសម្តេចព្រះអរជេ (៥) ដ្ឋសិត្តាមពោសយ៉ារាជបុពិត្រ

នុសម្តេចអរិប្រិញា (៦) នុព្រះមហាថេរម្នីសុធិម្ម នុព្រះមហេថេរ
បរខាន្តិ (៧) ព្រះអរិយបទុំម ព្រះបញ្ញាពិទូរ នុព្រះបរបាឡិ នុអ្នក
(៨) ផ្ទូវនុអ្នកទ្រឹងនុអ្នកល្បិ ឯគ្រសោតមានព្រះសុភាធិ (៩) ព្យ
តាសួសនុអ្នកព្រះស្នាសម្បាតនុជ្បូតើកនុអ្នកជ្បែនុ (១០) អ្នក
អគ្គហ្មឹនត្យ ឯតើសោតមានតួនតាំននុតាំហោរតាំ (១១) បុកតាំ
គាំតាំបែនតាំក្រៀតាំបែនតាំផាត តវេអ្នកទុំអំម្បា (១២) ល
នោះមោកជាសាក្ខស៊ីពេជ្រញាណនៀអ្នកអ្នូតនុអក (១៣)
ហ្មៀនជៀមតាំតាំទួមានបិត្រប្លាសាទ្វាមោកសាងព្រះ (១៤)
មាសអង្គ ១ ទុំងប្រ៉ាអង្គ ១ ប្រាកអង្គ ២ ឯស្នាទាតសោត (១៥)
តំលិង ១០ ហើយលែងមេបុសនែះឲ្យវិបជាស្រែបុន្យប្រិ (១៦)
ម្បិទិសតតបិបិរពោលល្បៀ ហ៊ាបេហាពោងផ្គណាកូន (១៧) ក្លួយ
ឯតាម្បូមោករិភាតមាត្រាមេបុសនែះហើយព្រះត្រា (១៨) សអិ
ម្បាលខ្សាបកុំបីប្រោសអ្នកនោះល្បៀហើយឲ្យរា (១៩) ផ្ទះទូអាន
នបកក្រពាលបែញក្បាលអ្នកនោះសព្វ (២០) ។ ជាតកំ
នើតហោង ៗ

លេខ ៣៤

nº 37 (A)

(១) នេះគឺរោះសុប្បុរិតវិវត្តជំរិតជាន្នាធ្យាស្រែនៃឧកញ្ញា (២) យំម្ភរាជ្ជនរិទ្ធជាតិវិរវង្សអង្គអគ្គមហាសេនាធិប្ប (៣) តិយេន្ត្រា វន្តាភិរក្ខបក្ខសិទ្ធធរាធរ ព្រះមហានគរបាលិអភៃគី (៤) វិបាក ក្រិពហុឯកមន្ត្រីយ តជាង្គិបំទារទេព្វសុភារមានបិត្រ (៥) ទាំពីរ នោះគឺត្រអន្និបាក្រាបលាព្រះបាទអ្នកជាអំបស្សរ (៦) ហ្សត្រាស្ស ប្រែហមោកឆោងឲ្យសាងត្រីសួរគាងឃ្មាយហ្វា (៧) យទៅ ព្រះគ្រីវត្តតត្រៃទ្វីបី មានបិត្រនោះខ្ពីសាទ្វារត្តាបឲ្យសង (៨) យាយនាសង្ហាលាបំម្រែបរាសស្រែបហៀនៃទេបស្មាទាន នា កាលស (៩) ង្ហាយនានោះនិមន្តព្រះសង ១៦ អង្គ គឺមហា សង្ឃរាជទាំ ១៦ អង្គ (១០) ត្តសំតែបភិកបេរសិនេរឆោង ប្រេន ឯប្រិតាបសំនាងសាងព្រះ (១១) មាស្សទំម្ងន់លិង ៤ នោះអង ១ ព្រះសិហិងអង ១ សាងតសុត្រាទសជាត្រ (១២) ព្រះអភិធម្ម ប្រឋម្មព្រះធម្មបក្ខឆោង តសព្រះពន្ធន្សបោង ផ្កុណាក្លូនក្សុយ (១៣) ឆោរិញាត្តសោតបុះព្រះតំបារ ១១ អង្គ

ហៀសិង្ឃស្រន្តាប្បគ្រឿងផ្លូងឧយ (១៤) មាន ឯព្រគេឧស្មាមាន
សង្ឃាយតាសោតត្រៃបិរប្រិខាគសំរាបម្សៀម្យ (១៥) ១៦
បាទខ្លួស្លោក ១៦ គ្រែងស្លាភ្ជកសំរាប្បមេម្យ ១៦ ប្រត្ត១៦
កុំម្សឹត្ត (១៦) កោរ ១៦ កុំម្សឹត្តរីទែយ ១៦ តែកភ្លើង ១៦
តែកបារ ១៦ ជើងអង្គារ (១៧) ១៦ កាំម្ទីយ ១៦ បត្តាត្តំ
១៦ ឫទ្ធសត្រា ១៦ ខ្សែប្រាស្ប ១៦ បិងស្លា ១ (១៨)
៦ ប្អូប្ប ១៦ តឿងទ្ធំ ១៦ តឿងត្លប ១៦ អងរូស្ប ១៦
បន្លាក (១៩) ១៦ អន្លង ១៦ គ្រែង ១៦ ខ្សែស្នៀង ១៦
គ្រប្បតិសទ្ធំសយ៉ទ្រែងស (២០) ង្ហាយគាគឹត្តតិសទ្ធំទំម្ទេប
ស្មាទាណាជាប្រាកជំញ្ជូង ៤ តាកាល (២១) លើកត្រីស្សួរគាង
ឃ្វាយ ឯសក្រាជ ១៦១៨ សក័ជ្ញត្រីខ៌ផលគុណ (២២)
ស្លួតព្រះទិព្វមន្ត្រធម្មបកមហាសុមៃយថ្ងៃ ៣ គលថ្ងៃព្រះហស្បតិ៍
(២៣) ៩ កើត្រលើកហ្លៀង ទៅគលថ្ងៃសុក្ត ១០ កើត្រតោះ
លើកតាំហ្លៀង (២៤) ជាសំរៀប ឯប្រវែងត្រីស្សួរតោះហោគ ១៥
ហត្ថឯជំរោវខន្សាំសោត (២៥) ហត្ថ ៤ ឯស្លាបគាងឃ្វាយ
តើមហត្ថ ៦ កន្តាលហត្ថ ៥ ឯចុងតោះហត្ថ (២៦) ៤ តេជះ

ខ្ញុំសាងជូនទៅឱ្យឥសអ្នកតមានគុណ ខ្ញុំសូមឱ្យបានទាណ (២៧) ព្រះសីអារ្យមេត្រីបានបួសសំនាកពុំនាកព្រះសាស្នា ឱ្យបានព្រះពុទ្ធទំនាយ្យ (២៨) នាកន្លងព្រះអងប្រាជ្ញាម្តេចមិញ ខ្ញុំសូមប្រាជ្ញាឱ្យបានដូចព្រះអងហោង នា (២៩) លែងជាត នេះទៅតលខ្ញុំកើតហ្វើងវិញ ខ្ញុំសូមឱ្យបានបេះសើល្បជុំបធុត ពោប្ប្យ (៣០) ប្រកដូតូបព្រះឥស្សូរហោង នាជាត្តនេះខ្ញុំប្រាស និងផ្តីណានិងកូណខ្ញុំ (៣១) ទុំ ២ ហោងសូមសព្វជាតណោង កម្មិមានឃ្លាតតលតែបហ្សេ ឥសត្រកូល (៣២) វិង្ស្វា ផ្ញើនោព្រះ សាស្នាកម្មិឃ្លាតល្បេហោង "០" ទោះខុស្សលុសអ (៣៣) ក្សរសូមព្រះអង្គជួយបំពេញផោងហោង "០" បុះរ្ទប់ខែភុទ្រ (៣៤) បុត ៩ ពោជប្ញៃ ២ ជាសួរេបហោង "០"

### លេខ ៣៨

### No 38 (A)

(១) សព្វម្ឫស្សុស្តិ៍គ្រីសព្វមង្គលពហុលបេសូ្ជាជយ្យោតិ៍ (២) ស្ទក ១៦២០ ន្ទុក្សត្រសក្កខាល ១ រោជខែពីសាខ្យប្ញៃអាទិត្យ ពារសាណា មុ (៣) ន្ទិតសង្ឃុំគុមសំតែបព្រះសុមង្គលម្ចាសយ៉ា

រាជបុត្រី នូវសំតែបព្រះរាជ(៤)សិលាចារ្យម្ចាស់យ៉ារាជបុត្រី
នូវសំតែបព្រះបញ្ញាពិទូរម្ចាស់បរិរាជបុ (៥) ត្រ នូវសំតែបព្រះ
ជេដ្ឋសត្តាបុត្រី នូវសំតែបព្រះគាថាបាម្ពុបុត្រី នូ (៦) សំតែប
ព្រះបញ្ញាវិនៃបុត្រី នូវសំតែបព្រះអរិង្សាបុត្រី នូវសំតែប (៧)
ព្រះស្នេណារនៃបុត្រី នូវសំតែបព្រះព្រហ្មរត្នបុត្រី នូវសំតែបព្រះ
អរឱទ្យេបុ (៨) ត្រី នូវសំតែបព្រះឱទ្យេបញ្ញាបុត្រី នូវសំតែបព្រះ
ត្រៃបាឡី ឯគ្រហ័សសោ (៩) តមានអ្នកហៅពញាសេនាធិព
ត្បី នូវអ្នកហៅពញាដោប្រអង្គ នូវប្យគ្រឹកនា (១០) ងនៀវនូវប្យតុក
នាងតុត្ថប្យតនូវនាងត្បូនព្រះធិកសេនា នាងគុងនូវតូន (១១) គាំម្ម
នូវតូនជ្រៀនូវនាងឱង នូវនាងដោវនូវប្យគ្រីហៅតូនបែនឯងនូវនាង
ខ្វេន តស (១២) អ្នកទាំអម្បាល្មេះស៊ឹងផាសុក្ខវិញាណនៃ
នាងបែននូវនាងដោវមាតបីត្រតំ (១៣) លាសាទ្ធាប្រោសខ្ញុំ
គ្រឹម្បូឈ្មោះម្យេឈ្មោងនេះឲ្យរក្សាព្រះគ្រឹរត្នត្រៃជាស្រលាះ (១៤)
តត្បីបីរកាលល្បេ ក្រេងខ្លាបមានបោងផ្កាណកូនកូយឯនា ម្លោក
ស្រ (១៥) ត្បីម្យេឈ្មោងនេះហិជាខ្ញុំល្បេ ព្រះពុទ្ធត្រាសបូអម្បាល
ខ្សេបកុំត្រាប្រោស្ប (១៦) អ្នកនោះល្បើ ហើយឲ្យរត្នាះទាំអានន្ទ

បក្កុក្រវាលបាញក្បាលអ្នកនោ (១៧) (១៨) ៖ សព្វៗ ជាត
កំណើត្តហោង ‿, ∘ នេះព្រគេនព្រះសុមង្គលហោង

*លេខ ៣៦*

**Nº 10 (A)**

(១) នែះសំម្តេបជោត្តិទេវាមហាសយ៉វាជបុពិត្រមាន (២) ចិត្រថ្លាសាទ្ធាំនាំអ្នកព្រះពុទ្ធ ២ អង្គអង្គ ១ ស្បូងទុម្មុន (៣) មហាប្បូទ្វាំ ២ អង្គស្មើហគ្នាមួកតំកលព្រះ (៤) មហោនគរទ្វាំរគ្វាំ ៤ វាយជើតសំមរ (៥) ភ្លងឯគ្គងទ្ធុំមមេក្កុះគ្គោងត្តុប ៣ ពាត (៦) គ្គោង ១៦ ឆេង ២ សំម្រាប ស្រស្បៃ ២ សំពោរ ២ សុត្រាហិប្ប (៧) ១ ពានប្រាកទ្ធុំម្មុន ១៤ ពានទ្ធង្វែង ១ ក្អម សម្រិ (៨ ទ្ធ ១ ប្តិលប្រាក ២ ហៅស ១ ពពីល ១ តំកលទុក មហោន (៩) គរព្រះអង្គឯនាមានសទ្ធារក្សាព្រះពុទ្ធនែះ (១០) គិសក្រេងសំម្រាប្បនែះឲ្យរក្សាឲ្យមួលនិងអ្ន (១១) កព្រះពុទ្ធនែះ ឲ្យបំម្រើបាតល់ ៥០០០ បសា ហ៊ុប្បើ (១២) អ្នកឯនា ១ មោក ស្រតីប្បយ៉ុកវិញអំពី្យ (១៣) អ្នកព្រះពុទ្ធទ្វាំ ២ អង្គនែះបំប្លែក រ៉ិញឲ្យជា (១៤) ស្ពាន ២ កន្លោងនិងព្រះវុត្តិ្យការនែះល្បេ កុំឲ្យ

(១៥) អ្នកព្រះពុទ្ធអំប្បាលត្រាសទៅហៅក្តិអ្នកព្រះពុទ្ធ (១៦)
និងត្រាសមោកឯភ្នែកនេះក្តី កុំត្រា (ស) ឲ្យបាន (១៧) ព្រាស
អ្នកនោះលើយ ឲ្យវគ្នាះទូំមសែនបញ្ញត្រីអ្ន (១៨) កបម្បែកនោះ
ហោង បាបើតសញ្ញាតភោរឯ (១៩) នាជួយអនមោទនាជួយ
វាក្យនិងប្រាងជាសង (២០) តំណាហាងក្រៀវទោហោង ឲ្យ
តសញ្ញាតនោះបាន (២១) យលនាកាលបានត្រសធម្មទូំប្រាំបី
ហ៊ើនបួនពាន់ (២២) ឲ្យប្រកោប្បត្តបអំប្បូរអ្នកព្រះពុទ្ធអំពីយ
មួននោះ (២៣) ហោង ឯកូនចៅនេះសិងអាទិ្ធស្ថានទុកស្មើហ
កួនបរ (២៤) ង្កើតចៅបង្កើត បើញាតឯនាបំម្បែកហាជាខ្ញុំម
ផ្ញើឲ្យមា (២៥) នទុកឯក្រៀវ ឲ្យញាត្តនោះត្រូវបុត្តាសាព្រះ
ពុទ្ធតីកា(២៦) ទុកឯក្រៀវនេះឯងហោង ហាបើញាតឯនា
(២៧) ជួយអាស្សូវតុំរហោតុំរូងជួយវាក្យព្រះសស្មាអ្នកព្រះ (២៨)
ពុទ្ធឲ្យអ្នកនោះបានទ័ននាកាលត្រសធម៌ប្របីហ៊ើនបួ (២៩)
នពាននោះកុំឲ្យញាតនោះខ្លាតខ្លាហលេយះហោង

*លេខ ៦៧*

Nº 2 (B)

(១) សក្តមស្បុតមុង្គុលាជ្យៃាតិរេក ១៥៩៣ ឆក្សត្រ (២) ឆ្នាំមក្សូរខែហអាសាធថ្ងៃយសោរិប្រាំបីយកើត (៣) ពារសត្វសត្វមហោរត្ថឹងមះហោទ្យាពេច្ចភ្ញូលអំពីព្រះ (៤) ព្រះពុទ្ធហ្វៃទ្ប្លាំថ្លៃយ ឆៃយអ្នកសំតែបព្រះមុនីយកុ (៥) សលបុពីត្រព្រះអង្គមោកសំពះព្រះអង្គរត្រៃ (៦) ទេះព្រះតិគ្រ្នាធិរាជ្ជលោកឲ្យព្រះពីសស្នោរិកម្មិបុះ (៧) មោកសាងទុក្ខជាកំប្លួនលោកដោងឯក្រោយ (៨) នោះហ្បៀព្រះអង្គមោកគិត្តអ្នីញាំហាប៉ាំខ្លួណនេះ (៩) មោកអំពីយវត្រអន្លងតោកនាយនោះ យោលស (១០) ងខារនេះពុំទៀងលេយ មោកអារាទ្ធនានីមន្ទម (១១) ហាសយិរាជព្រះរាជ្ជសុមង្គុលសីលាបាយ៉្យបុពីត្រ (១២) ឆ្គិសសងដោងទំហ្ប្លៀ ៥៥ មោកទ្រង់បាំ (១៣) ងស្ទួលព្រះអង្គគ្នល្បើហាព្រះពន្ធនោះបបាយប្រ (១៤) បៃយវត្តល្មើកឡ្យជាស្នាំទានោះប្រាកជញ្ជីង (១៥) ១ តំលឹង ៧ ស្លឹង ៥ ស្បុង ១៣ ដឹពរ ២០ ជាសុរប (១៦) ឆ្វប្រាកាយ៉្យអំម្បាលនេះហោង

លេខ ២៨

No 32 (B)

(១) សព្វមស្តុមង្គលជយ្យាតិរេក ១៦០៥ សកកុរនក្សត្រ ខែចែត្រ (២) ៧ រោជអាទិត្យពារសាណ្ហ៍ាមន្ត្រិតិសជុំនាងហើម មានបិត្រប្លា (៣) សាទ្ធាំប្រោសអាសិងនៅជាព្រៃស្រលះអ្យត ពោលបិរល្បៀ កាល្មោះ (៤) ស្រោតមានសំតែបព្រះរាជសមង្គល មហាសឃ៊ីរាជបពិត្រ (៥) នូសំតែបព្រះរាជសិសាបាយ៉ៀមហា សឃ៊ីរាជបុពិត្រ នូសំតេប (៦) ព្រះមហាបទុំមហាសឃ៊ីរាជបូពិត្រ នូសំតេបព្រះធម្មុស (៧) ត្លាបុពិត្រ នូតិសភិក្ខុបេរសំម្នើរដោង ប្រេណាស្បៀងដាស (៨) ក្វិវិញ្ញាណ ឯគ្របាសសោតមានតាង មានបោលិកនាងបុស (៩) នូព្រះវង្សាគាយ្យុកនាងម៉ន្នូព្រះ រាមសេន្នានាងជ្រាបោ (១០) ឲ្យនាងភរិ តិសអ្នកទុំអម្បាលនែះ ស្បឹងជាសក្សីពើជ្រាណមានបិត្តប្លាសាទ្ធាំជួយ (១១) ជ្រោម អនុមោទ្ធនានឹងតាងហើមប្រោសអាសិងនៅជាស្រលះហោង ហា ហ៊ិមានអ្នកឯនា ៗ (១២) ម្បស្រតីយោកអាសិងនែះជាខ្ញុំះល្បួ ឲ្យ ព្រះពុទ្ធអម្បាលខ្សែបកុម្បីប្រោសអ្នកនោះហោង

*លេខ ៤៩*

No 32 bis (B)

(១) សក្ដមស្បុត្រស្តីស្រីសក្ដមង្គលពហុលបេស្ដាផ្សៃ តីរេក្ខ ១០៦៨ ស័ក្ខបុ (២) ហ ខែបែតថ្ងៃយសុក្ខម្យរោជ ព្រះមន្ត្រីសង្គ្រាមនូនាងញាមានបិត្រកត្តម្រាតសា (៣) ទ្វា មុក្ខសាងព្រះសាធ ៩ នូព្រះជិនរូប ១៧ ព្រះអង្គ តាមតើមព្រះស្រី វត្តមហាពោធិជាស្ត (៤) ណាពុំនាក្ខព្រះសាស្នា ហោពញា ម្នោនេត ១ មុតស្បៃ ១ ទូតិសញ្ញាត្តិកាបោងផ្តិណក្ខណ (៥) ក្ដយសិងមក់ជួយជាកុសលអនុមោទ៍នាព្រហ្មលួមជាម្ស នឹងព្រះ មន្ត្រីសង្គ្រា (៦) ម នោវត្តព្រះអង្គមហាសឃរាជ្ជព្រះរាជសិលា បាយ៉ៀបាន្នឱប្បសំម្បត្ត (៧) ជាភ៏ក្ខ បំម្រើណទៅមាតាបីតា នូផ្តើយក្រោម្មស្ចូមឲ្យបានទាំនព្រះប្អាង — (៨) ក្ករាជ្ជព្រះសិអារ ម្បៃត្រៀពោធិសត្វ ស្ចូមផុត្តបំហុត — ត្រ — ន៍រូបួតលនិរ (៩) ញានហោ (ង) ឯតំម្នូបប្រាក់ជាស្នាហាទានតម្លិង ៣ ឯព្រ មន្ត្រី សង្គ្រាមនោះ (១០) នូស្រុកស្រែហ្ម ខ្មេរពាន់ព្រៃយក្របាស់ប្រាទ្វី និពានុសម្ប្បយោ (១១) ហោន្តុ

លេខ ៣០

№ 33 (A)

(១) សព្ទមស្តុស្តស្តីយស្រីសព្ទមង្គលពហុលបេស្តាជៀ
(២). តិរេក ១៦០៦ សក្កជូតនក្សត្រ ១ រោជកាត្តិ (៣) ក
ប្ញៃអង្គារពារសារណា មគ្គិតសជុំនុំមហាសឃ៊ារាជ (៤) ព្រះរាជ
សុមង្គលបុពិត្រ មហាសឃ៊ារាជព្រះរាជសិលាបាយ្យ៉ុ (៥)
ពិត្រ សំតែបព្រះស្សូរបញ្ញាបុពិត្រ សំតែបព្រះមរវីនៃបុពិត្រ (៦)
សំតែបព្រះជេដ្ឋសិទ៍ាន្ត សំតែបព្រះជេដ្ឋស័ត្តា សំតែបព្រះ (៧)
បរវិទូ សំតែបព្រះបញ្ញាវីនៃ ព្រះបញ្ញាពិទូរ ព្រះមហាបេរស្ម (៨)
ណាកីរ អ្នកបវរពោធិ ឯគ្រហស្នសោតមានបៅពញ្ញារាម្ម (៩)
ជា ព្រះមន្ត្រីធូបេស ព្រះជិតខ្សត្រិ ព្រះមនោអនិជិត្រ នាង
ទានា (១០) ឯសរបៅមំមបៅនួតនាងគ្រឹនាងសុកនាងខែមេស្សិក
តិស (១១) អ្នកទំអិម្បាលនែះសីងជាសាក្សីសក្ខីវិញ្ញាណនាង
គន្ធមា (១២) ឥបិត្រសាទ្ធាសាងព្រះពុទ្ធរូបមាសអង្គ ១ ប្រាក
អង្គ ១ សំណាហអង្គ (១៣) ៣ ទង ១ ពិតាន ១ កំព្យ.៥ តិស
ប្រាកស្មាទានជញ្ជីង ១ ទូរនឹងស្ប (១៤) ង ២០ គ្រឿងបាយ

សំម្រាប ៣ គ្រឿងទិកសម្រាប់ ៣ កន្ទេលខ្នើយ (១៥) សំម្រាប់ ២ គ្រឿងស្លាសម្រាប ១ កុម្សិតឬបពិន្លាគតើង តស គ្រឿង (១៦) តែកសឹងជាទានទុំអម្បាលនេះបំម្រើនទៅព្រះ រាជាធិរា (១៧) ជតជាស្វាមីខ្នុំឲយខ្ញុំ ៥ អ្នករ៉ូប អ្នកសី ១ អ្នកមោក ១ (១៨) មេរត្ន ១ មេកែវ ១ មេប៉ុក ១ តសទុំនេះសឹងរ៉ូបស្រលាះ ៨ (១៩) ទិសអ្សិតបីបីរពោល ល្បេ ទោះយោប្ជិមានបោងផ្គុណកូណ (២០) បៅធោពារ ញាតិកាងនាម្យមោកពិពាធមាត្រាឋាជាខ្ញុំ (២១) ល្បេ ព្រះ ត្រាស់អម្បាល់ខ្សែបកម្សីឲយប្រោសអ្នកនោះបា (២២) ឥល្បេ ហើយឱយរិត្នាះទុំអានន្ដបក្រពាលបែញក្បាល (២៣) នៃ អ្នកនោះសព្វ ៗ ជាតកុំនេតហោង បើហបៅក្រ (២៤) មង នាម្យបង្គាបឱយសោតឱយរិត្នាះបែញត្វប្នោះហោង

លេខ ២៧

№ 2 (B)

(៣) សព្វិសព្វមហោរតឹង មហោឡា ពេញភ្ញូល

សំ. ម. សតិសតិមហោរត្តិ-មហោឡារ-ពេចកូល ។ សតិសតិមហោរត្តិ = សព្វថ្ងៃសព្វយប់ ឬរាល់ថ្ងៃរាល់យប់ ។ មហោឡារ = ធំឱឡារ ធំធំក្រៃ ។

ពេចកូល ប្រហែលជា "ពេញកូល" គឺពេញពោរឡើង...ឬកើតពេញ... ។ ចូរមើលពាក្យថា កុល ។

(៧) ទុក្ខជាកំប្លូនលោកជោង ១. ទុកជាក្បូនលោកជន ។

(៩) វិត្រអន្ទងតគោក ១. វត្ត អន្ទង៍គគោក ឬវត្តអន្ទង៍គា គោក ។

(១៣) ទ្រង់បាំងស្លួលព្រះអង្គនូល្ហើហាព្រះពន្ធ ម. ១. ទ្រង់បង្ក្រូលព្រះអង្គនៅលើព្រះពាន់ ។

(១៤) បញាយប្រែយ ១. សំ. ចាយប្រត្យ័យ ។ ម. បច្ច័យ ។

(១៥) ជីពរ ម. ចីពរ, មកពី ចីវរ ។

លេខ ២៨

№ 32 (B)

(៣) អ្សូតពោលបិរល្បេ ១. ម. ឥតពោល-បិរ-ឡើយ ។

ចិរ ប្រែថា ចេរកាល-អស់កាលដ៏យូរ ។ ឥតពោលចិរទៀយនេះបាន សេចក្ដីថា យូរទៅក៏ឥតមានពោលតក់យកមកវិញដែរ ។

(៧) សម្មើរផោងប្រេណា ម. ១. សាមណេរ-ផងច្រើន ។

លេខ ២៩

No 32 bis (B)

(២ — ៣) បិត្រក័ត្តម្រាតសាទ្ធាំមូក្ខសាងព្រះសាធ សំ. ១. បិត្តកាត់ជម្ទាសត្តា មកសាងព្រះសាធ ។

(៥) អនុមោទិតាព្រហ្មល្មប ម. ១. អនុមោទនាព្រមល្មម ។

(៦ — ៧) បាន្ទឱប្បសំម្បត្ត ជាភិក្ខុ ១. ម. បានឧបសម្បទជាភិក្ខុ ។

(១០) ន្លូស្រុកស្រហ៉េខ្មេរពាំង ១. ទៅស្រុកស្រហ៉ា-ខ្មែរពាន់ ។

(១០ — ១១) និពានុសម្បប៉យោ ហោត្ត ម. និព្វានស្ស បច្ចយោ ហោតុ ។ ប្រែថា សូមជាបច្ច័យដល់ព្រះនិព្វាន ។

លេខ ៣០

No 33 (A)

(៨) ប៉ៅពញាកមជោ (ងារ) ចៅពញាកមតេជោ ។

(៩) ព្រះមន្ត្រីធូបេស (ងារ) ព្រះមន្ត្រីធិបេសរ៍ ។

(៩) ព្រះមនោរថនិជិត (នា៖) ព្រះមនោរថនុជិត ឬព្រះមនោរថនុជិត ។

(១៣) ទូរនិងស្បង់ ឧ. ទូស័នឹងស្បង់ ។ សំពត់សសម្រាប់បន្សុកូលហៅថា ទូស័ មកពីពាក្យ មគធថា "ទុស្ស" ។

(១៥) ប៉ុប ពិឡាគ តើង ឧ. បប-ពឡាក-ដ័ង ។

លេខ ៣១

Nº 34 (A)

Nº 34/1

(១–៦) បពិត្រ នេះគឺ ពោះ ត្រីពិធសុបរិត សទ្ធា មហាវិបុល្យ អតុល្យ អតិរេក ឯកគ្គតា ប្រមោជ ជោតិបង្កជវត្តរេណូវពិគ្ន អបិគ្គនិយ៖ បីតិមានោជ ពៃរោចន៍ សុគន្ធបវរ សរសោមនស្សាភិលង្កិត វិកសិត សោត្តុរបរមបទុមាភា មហាអតិស័យក្រៃសម័យសុមហុត្តិមហោត្តម សមន្ត អសំខារិកបិត្តវិរិធសុបរិត ភាវាសត្យាអធិស្ឋាន ។

(៩) សំតែបព្រះសិសាក្យាមុណី ឧ. សំ. សម្តេចព្រះត្រៃសាក្យមុនី ។

(១០) ស្ដេចប្កើងទូអដ្ឋុត្តរវិរសគមុង្គល ១. ម. ស្ដេចថ្កើន ទូវអដ្ឋុត្តរវិសេសមង្គល ។ មង្គលដ៏ប្រសើរ ១០៨ ។

(១១) ឈាយលក្ខក្ងបក្ក អនគ្ឃអនាថិពិពារ៍សហារ ១. សំ. លាយល័ក្ខណ៍កង់ច័ក្រ អនគ្ឃ អនាថិ ពិពណ៌សំហារ ។ អនគ្ឃ អនាថិ ក្នុងទីនេះប្រែមិនបានសេចក្ដី ប្រហែលសរសេរខុស ព្រោះឃើញក្នុងទីដទៃសរសេរជា អន័ក អនាថ ក៏មាន ។

ពិពណ៌ — មានគុណគឺបណ្ឌិតគប្បីពណ៌នាដោយវិសេស, គឺជារបស់អស្ចារ្យ-ប្លែក ចំឡែក, ត្រកាល ។

សំហារ ប្រែថា នាំព្រម, បណ្ដុំចិត្ត, បណ្ដាលចិត្ត ដូចពាក្យថា ទេពសង្ហារ ប្រែថា ទេវតាបណ្ដាលចិត្ត ។

(១៣) សម៉ារនៀ សំ. សមានៅប្រែថា ទីរួមនៅនៃទុក្ខ គឺវដ្ដ-សង្សារ ។

(១៤) ប្រភិលមហានុទ្ធស្រមុទ ១. សំ. ប្រភល-មហានទសមុទ្រ ។ ប្រភល ទីដាច់សង្វែង-លង្វិមលង្វោប-ល្វឹងល្វើយ ។

(១៥) ស្ទួងពន្ធហារយ (សៀម) សង់ពាន់ហារយ គឺ ពីរពាន់ប្រាំរយ ។

(១៥) ភព្វជាតិកន្ទាល ម. ភព ជាតិ កន្ទារ ។

(១៧) បតុតិស័យោជា ទ្វារទិដ្ឋិទ្រិស្តមសន្ធបតុទសចេត្ត សៃកិ សំ. បតុតឹសយោជា? ទ្វាសដ្ឋិទ្រិស្តិមស? នូវចតុទសចេតសិក ។ ម. ចតុតឹសយោជា ទ្វាសដ្ឋិទិដ្ឋិមស នូវចតុទសចេតសិក ។ មស នេះ ប្រហែលជាសរសេរខុស ដោយប្រមាណមើលប្រហែលជាមិស ដែលប្រែថា ច្រឡំ-លាយឡំ, ឬក៏មសិដែលប្រែថា របស់ខ្មៅ-គ្រឿងខ្មៅ ឬក៏ មិថ្យាដូចមានពោលហើយខាងដើម ។

(២១) អាយុខៃយ្យកាំម្មខៃនាគិតសជន្តាពិត្តិ ម. សំ. អាយុខ័យ កម្មខ័យនាទីងអស់ជន្មពិធី ។

(២៥) កាត្តេកពុទ្ធពារ, សាណ្ណារ ភ្យជាស្រៃ សំ. ១. កត្តិក ពុធពារ, សារណា ពីអធ្យាស្រ័យ ឬ ពី អជ្ឈាស័យ ។

(២៧) វ៉្ឋបរិលវ៉ាបាលតលឥល្ងូវៃនេះ ១. រួចកល់របាល ដល់ឥលូវនេះ ។ របាល គឺលំដាប់ ដូចពាក្យថារបាលក្សត្រ ។

(៣១) ព្រះអង្គរយាបណ្ណាង ពាក្យនេះជាព្រះរឿ គិតមិនយល់ ។ ប្រហែលជា ព្រះអន្តរធានបង់ទេដឹង ។

(៣២) ព្រះសឹហៀង ម. ព្រះសីហិង្គ ។ ជាឈ្មោះព្រះពុទ្ធរូប ១ យ៉ាង ដែលដើមមកពីលង្កាទ្វីប ។

No 34 2

(៣) ទូ កបើណ ម. ទូកចិន ។

(៤) សង្ឃស្ពាន ខ. សង់ស្ពាន ។

(១៣) រត្នគុណមាសមុណី ម. ខ. រ័តន មាស មណី ។ រ័តនក្នុងទីនេះឲ្យមើលថា ពត់-តន់ ។ ដែលសរសេរជារត្នគុណនេះលើស ពីរត្ន គឺ គុណ ពាក្យនេះជាដូច្នេះឯង កុំឲ្យអ្នកមើលគិតសង្ស័យជាសព្ទ អ្វីផ្សេងឡើយ ។

(២០) អ៊្យិតឯហ៊្យោង ខ. ឥតឯហ្វូង ។

លេខ ៣៦

N. 35 ( A )

(១៥) យុគ្គលវិមុលភិបិនត្រៃយ សំ. យុគលវិមល អបិទ្រៃយ ។

(២៤) ព្រះសិលា ម. គឺព្រះស្អាងអំពីថ្ម ។

(២៤) ព្រះទេពហារូប ម. ព្រះទេពតារូ គឺព្រះដែលស្អាងអំពី ដើមទេពតារូ ដែលអ្នកខ្លះហៅថា ទេពតារ៉ូ ។

(៣២) ធិព្វសម្បត្តិ បុរិបុណ្ណាំ សំ. ទិព្វសម្បត្តិ បរិបុណ៌ម៍ ឬបរិបុណ្ណំ ។

(៣៧) ជាតជារាម៉ែរ ម. ជាតិ ជរា មរណ៍ ។

(៣៨) សង្សារគ្តោ ម. សំសារន្តោ ប្រែថា អន្ទោលទៅ ។

(៤១) មហាបញ្យាំ សំ. មហាបញ្ញ័ម៍ ឬ មហាបញ្ញាំ ។

លេខ ៣៣

*No 36 (B)*

(៨) ឯគ្រសសោតមាគព្រះសុភាធិព្ទតា ស្ទួស ១.

(ឆារ) ឯគ្រហស្តសោតមានព្រះសុភាធិបតី សួស្តី ។

(១៩) ពាគ្នះទ្ធអាគគបកក្រពាលបែញក្បាល ១. សំ.

រន្ទះទាំងអនទ្តបក្រពាឡ បាញ់ក្បាល ។

លេខ ៣៤

*No 37 (A)*

(១ – ៤) គើតគឺ រូ សុចរិតវិរិផរិតធារណាធ្យាស្រ័យ នៃ ទកញ្ញា យមកជ នរិន្ទ្រជាតិវរវង្សអង្គអគ្គមហាសេនាធិបតិន្ទ្រាវដ្ឋាកិរក្ខ ចក្រសិទ្ធិធរាធរ ព្រះមហាទគរបាលអភ័យគិរីបាកក្រមពាហុ ឯកមន្ត្រី ដ៏ ជាប្តីចមទាវ ទិព្យសុពណ៌ ។ ឆារយមកជសម័យនេះសរសេរជាយោមកជ តែប្រើបែបបូរាណនោះត្រូវជាង ។

(៨) សង្ហាលាបំម្រើបរាសស្រែចហៀ ខ. *សង់សាលា បម្រើបម្រាស់ស្រេចហើយ ។*

(១១) សុត្រាទសជាត្រ សំ. *សាស្ត្រាទសជាតិ ។*

(១២) ព្រះអត្តិធម្ម ប្របឋម្ម ព្រះធម្មបក្ខដោង ម. *(ឈ្មោះ) ព្រះអភិធម្ម ប្រថម (គឺបឋមសម្ពោធិ ឬបឋមត្រាស់) ព្រះធម្មចក្កជង ។*

(១៣) បុះព្រះតំបារ ខ. *បុះព្រះដំបារ គឺ បុះក្ទនផែនមាស ។*

(១៤) គ្រែងស្លាភ្លក ខ. *គ្រឿងស្លាភ្លុក ? បើពុំដូច្នោះទេគឺជា កញ្ច្រូងស្លា ១ យ៉ាងគេធ្វើដោយភ្លុក ហៅថា គ្រែង ទេដឹង ។*

(១៧) វិតសត្រា *វិតសាស្ត្រា គឺស្លឹកវិតដែលចារសាស្ត្រា ។*

(១៨) បុប្ប-តៀងទំ-តៀងតូច-អងរស្ស-បន្លាក ខ. *ចប-ដឹងធំ-ដឹងតូច-អង្រែស-ពន្លាក ។*

(១៩) ក្រង—ខ្សៀស្តៀង ខ. *គង-ខ្សែស្តៀង ឬគ្រឿងខ្សែស្តៀង ។*

(២០) គីត្តតិសទុំទិម្ទេប-ស្មាទាណា ខ. ម. *គិតអស់ទាំងបំណាច់-សមាទាន ។*

(២៨) ជំពោរទន្សា ខ. ដស្រោមទន្យា ។ ពន្ធញដែលសម្រាប់បញ្ចូលទៅក្នុងដំណាប់ហៅថា ទន្យា ។ ម្យ៉ាងទៀត ឈើដែលគេបោះជាគោលឲ្យនឹង ក៏ហៅថា ទន្យា ដូចពាក្យថា ទន្យាចេតិយ គឺគេយកឈើមកបោះហើយទើបផ្ចានខ្សាប់មកចាក់គរឡើងជាចេតិយ ។ ម្យ៉ាងរបស់ដែលជាគោលសំខាន់បាននឹងអំពើបុណ្យបាបដែលសត្វធ្វើហើយ ជាអ្នកនាំសត្វបដិសន្ធិ អំពើបុណ្យបាបនេះក៏ហៅថា ទន្យាដែរ ដូនក្នុងពាក្យសុភាសិតថា បុក្សជាតា មិនក្រែណាទឹងទន្យាកំណើត ។ តែដូនណាគេហៅថា អន្យា ។

(២៩) សើល្បជុប សំ. សិល្បជប្ប៍ ។ តាមទម្លាប់សរសេរជាសិល្បដុប ។

លេខ ៣៨

No 38 (A)

(៩) ចៅពញាសេនាធិបតីនូវអ្នកចៅពញាជោប្រអង្គ

(ខារ) ចៅពញាសេនាធិបតី នូវអ្នកចៅពញាគេជោព្រះអង្គ ។

លេខ ៣៦

No 10 (A)

(៦) ពាតគ្រោង ខ. ពាទ្យគង ។

(៦) សំពោរ ខ. សម្ភោរ ។

(៦) សុត្រាហិប្ប សំ. ខ. សាស្ត្រាហិប ។

(១១) តល ៥000 បសា ខ. ម. ដល់៥.០០០ពស្សា ឬ ដល់ ៥.០០០ វស្សា ។

(១៩) ប្រាងជាសង ? (គិតមិនយល់សេចក្តី)

(២៦) បុត្ដាសាព្រះពុទ្ធតីកា ខ. ម. បណ្ដាស្សាព្រះពុទ្ធដីកា ។

(២៧) តុំរេហាតុំរ្វង ខ. ដំរែដម្រង់ ។

(២៨) បានទ៌ន៍នាកាលត្រសធម្មិប្រិប្បីហ្មើនប្អូនពាន ខ. បានទាន់នាកាលត្រាស់ធម៌ប្រាំបីហ្មឺនបួនពាន់ ។

(២៩) ខ្លាតខ្លាហលេយ ខ. ឃ្លាតឃ្លាឡើយ ។

# ប្រជុំពាក្យកាព្យ

## ភាគទី ១

ព្រះរាជនិពន្ធ ព្រះបាទសម្ដេចព្រះស្រីធម្មរាជា

ព្រះរាជសម្ភារ

ព្រះចៅក្រុងកម្ពុជាធិបតី

គទី ៤

# ច្បាប់ព្រះរាជសម្ភារ

ហៃសាធុជនផង    នេះគឺចំណាំ
បទបាឡីថា    គម្ពីរសធម៌
អាណាក្រិតិកា    គួរគប្បីមហា
ជនផងត្រងត្រាប់ ៗ    ធម៌នេះដំបូន្មាន
រួមគ្យាប្រាណ    ឲ្យបានក្តីគាប់
ដល់លោកបរលោក    ហៅរស់ពុំស្លាប់
ធម៌នេះជាច្បាប់    ក្តីគាប់បរិយាយ ៗ
កុំទុកចិត្តបរទេស    កុំទុកចិត្តអក៏នេស
កុំទុកចិត្តអភិប្រាយ    ប្រើស្នំរែងខ្ពស់ (១)
រំពឹងឲ្យឆ្ងាយ    ស្ដាប់ពាក្យបរិយាយ
បណ្ដាំមេដី ៗ    កុំជឿងដោយខ្យល់
កុំឱនពាក្យពល់    កុំខ្វល់ដោយស្រី
កុំកាន់ពិសយន៍    គប់ទឹងស្ត្រី
សមណជនដី    កុំឲ្យក្ដីត្រូវ ៗ
កុំនៅញ៉ងឈ្លោះ    កុំស្ដាប់អាសូពេះ
កុំស្ដាប់អាស្រូវ    កុំ[illegible]ពានស្ទុន

---

១ ច្បាប់ខ្លះថា ប្រើធំ ... ក៏មាន ។

កុំស្កាត់ច្រកផ្លូវ កុំធ្វើស្រែស្រូវ
នៅផ្លូវដំរី ៗ ផ្អែមពីរប្រការ
ចំណោរនៅផាល កុំអាលឲ្យធី
ផ្អែមមួយពាក្យពាល វែងកលកេត្តិ
ផ្អែមមួយពាក្យស្រី ស្រដីមាយា ៗ
ពាក្យគ្រូវែងវែង ស្រាវែងស្រវឹង
ពុំដែលពីសា ពាក្យពិតវែងស្វែង
ពុំពីរោះថា បណ្តាំមេបា
វែងថាពុំគាប់ ៗ ទៅវែងស្អប់បេះ
ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ
ស្រីស្រាលប្រចណ្ឌ វែងស្អប់ខ្ញុំគាប់
ពាលពិតឥតច្បាប់ វែងស្អប់ប្រដៅ ៗ
ចង់បុណ្យបានបាប បរបើងចង់លាភ
វែងបាត់ធនទៅ មានះបាត់មិត្រ
ឥតអ្នកជារៅ ក្រែវក្រោះយោរយៅ
រមែងបាត់អង្គ ៗ ស្វែងគាប់បានយស
ចង់ស្វែងរបស់ ប្រើបេះផ្គត់ផ្គង់
ចង់ធំកុំអួត ដើមមានពូជពង្ស

បង់ឲ្យខ្លួនត្រង់ ប្រើផ្គាប់អ្នកមុខ ៗ
ខ្លួនហើរដ្បិតខ្យល់ នាយជើងដ្បិតពល
រក្សាឲ្យសុខ ទ្រព្យគង់ដ្បិតស្រី
ចេះសំចៃទុក មានផ្ទះស្រណុក
ដ្បិតករិយាជា ៗ បាត់យសដ្បិតខ្ជិល
បាត់ញាណទានសីល ដ្បិតសេពសុរា
ប្រមាទបាត់បុណ្យ ខឹងបាត់ប្រាជ្ញា
លេញលេងដៀលថា បាត់កិរិយាគាប់ ៗ
អត់ធុនឥតទោស ធ្វើចិត្តសន្តោស
បង្កើតជាទ្រព្យ មេត្រីជាញាតិ
រក្សាដល់ស្លាប់ ចៀសក្តីពុំគាប់
ជាគន្ធពិដោរ ៗ ទឹកបាក់ទៅធាប
បុណ្យបាត់ដ្បិតបាប លាភបាត់ដ្បិតឃោរ
ទឹកថ្លាដ្បិតរលក ពុំយល់ស្រមោល
ទោសកើតដ្បិតពោល ល្ងមមាត់ឈ្លានពាន ៗ
ខ្មៅរែងស្អប់ប្រាជ្ញ នាអ្នកខ្លួនខ្លាច
រែងធ្វើជាហ៊ាន ខ្សត់ខ្សោយស្ទិតទ្រុត
រែងធ្វើជាមាន អ្នកឥតសន្តាន

រីឯមើលគេឆាយ ៗ ទាហានច្កើឯដ្បិតសឹក
ធ្វើស្រែដ្បិតទឹក ត្រេកពលដ្បិតបាយ
សិស្សប្រាជ្ញដ្បិតគ្រូ ផេរពោលដំរាយ
ពលជាដ្បិតនាយ ហ្វឹកហ្វឺនខះខំ ៗ
រៀនក្ដីគួរគិត ចាស់ឥតប្រព្រឹត្ត
នូវប្រែប្រឡំ អ្នកជា ៗ កាច
តូចប្រែជាធំ ពង្សពូជឧត្ដម
ប្រឡំជាក្រស្ដ ៗ ឃើញសេះជាលា
ក្ងានជាទា ពពាយជាទាស
សំណជាប្រាក់ ស្ពាន់ឆ្លាក់ជាមាស
បន្ទ្វយជាជាស កប្បាសជាគរ ៗ
ហេតុនេះគួរគិត គួររិះរកហេត
ដឹងរសគន្ធ ពីដោរអេសុដោរ
ពីសាសាទរ ហាឹតៈហើយគប្បីប-
វិភោគ្គាគ្គិត ៗ ល្គឹកត្រ្ពីពាក្យ
សាកសួរកេសាប់ សន្ដានព្រេងព្រឹទ្ធ
រករិះកល្បើ សុបរិតទុច្ចរិត

ហើយហោងគួរគិត ឲ្យដឹងខ្ពស់ទាប ៗ
ដូចខ្លាក់ប៉ាំងស្បែក មួយដូចទំពែក
ចង់សុំប្រេងលាប ដូចថ្ងង់ភ្ជាប់ប្រៀង
ទះដៃព្រាក ៗ ដូចខ្ទិនអាបឡាប
ចង់ចងក្បិនតែ ៗ ពុតញាយមានបី
មួយដូចដំរី សាហាវឥតបទ
អាចផ្សះផ្សាំងបាន កន្ទើរកាន់កត់
ដាលវេញគោតគត់ ៦ ហត្ថហោង ៗ
មួយចង់ឈ្នះ ចិត្តចង់ចចេស
ពុំដោយគន្លង ពាក្យពោលអ្នកធំ
ប្រឡំសូរសេង ពុំគិតក្តីហ្វង
ចងចេរអន្ទាយ ៗ មួយស្រីពេស្យា
បំពេញព្រហ្មចា- រីរួសអគិព្រាយ
អំពើទាំងបី ហៅពិសពុតញាយ
សាធុសម្លាយ បៀសកុំបីគ្រាប់ ៗ
ប្រាជ្ញពុំស្មើពុត បំរើលំទុត
ពុំស្មើក្តីគាប់ មានគុណពុំស្មើ

អ្នកមានបុណ្យក៏ឮ　　ស្វែងរៀនគេច្បាប់
ពុំស្មើចិត្តជា ៗ　　ស័ក្តិពុំស្មើយស
អ្នកមានរបស់　　ពុំស្មើស្តា .
សូមបង់ធនធាន　　កុំខុសអាជ្ញា
សូមមានមេត្តា　　កុំឲ្យគ្នាមើលងាយ ៗ
សូមសុំកុំយក　　គ្នាស្មើកុំរក
ដូចបារទឹងនាយ　　ខុសគាប់សូមអត់
កុំឲ្យឃ្លាតឆ្ងាយ　　ក្តីសុខុមទាំងឡាយ
កុំហាយសូរស័ព្ទ ៗ　　ធម៌នេះដំបូន្មាន
រួមរក្សាប្រាណ　　ឲ្យបានក្តីគាប់
សូមបង់ធនធាន　　កុំឲ្យខ្លួនស្លាប់
សូមស្តាប់គួរគាប់　　សេធម៌កុំបីបង់ ៗ
បន្ទិបមេត្តា　　អំបូរលោកថា
ទូកតាមកំពង់　　សំពៅតាមខ្យល់
បង្កងដំរង់　　មើលមើតែត្រង់
ត្រីរៃសជាមុខ ៗ　　ដូចចិត្តបិតា
ដូចមានករិយា　　ទៅផ្ទះស្រណុក
ដូចកូនទទួល　　យកពាក្យរកពុក

ដូចខ្ញុំឲ្យមុខ អម្ចាស់ប្រើហៅ ។
បន្ទិចមេធា អំបូរលោកថា
ព្រេងព្រឹទ្ធប្រើដៅ ទើងធីប្រើរក
ទើងស្វែងប្រើទៅ ទើងស្នេហ៍ប្រើហៅ
មិត្រមកជាមិត្រ ។ ពាក្យខុសកុំស្ដាប់
ក្ដីខុសកុំត្រាប់ អ្នកកាចកុំបិត
ល្ងង់កុំស្រដី ខ្សត់កុំទុកចិត្ត
ពាលោកុំបិត ជាមិត្រមេត្រី ។
ប្រើថ្លឹងឲ្យស្មើ ទោះបីទឹងប្រើ
ប្រើអ្នកបេះក្ដី កុំយកពាក្យស្មោក
ផ្ដឹមទឹងគម្ពីរ កុំយកពាក្យដី
ផ្ដឹមទូវពាក្យពាល ។ មើលក្នុកដញ្ជីន
កន្ទិចិត្តឲ្យដឹង ណាធ្ងន់ណាស្រាល
កុំយកមណីរ័តន៍ មាសមានជាកាល
ចិត្តកុំបណ្ដាល ទូវបង់សីលធម៌ ។
ប្រើដឹងតុលហាប ប្រើដឹងខ្ពស់ទាប
មានក្នុកយល់ល្អ ទោះដឹងទឹកមាស

ពុំបេរនៅថ្ង ទោះដឹងនៅដ៏ស
ពុំបេរសុំបុត្រ ៗ ផ្ញើស្រែមើលស្មៅ
សត្តានមើលផៅ បំរើមើលពុត
ទោះដឹងពុតជា ពុំបេរពុតត្បុត
ដឹងចិត្តបរិសុទ្ធ ពុំបេរតេរិយា ៗ
ទេពីមើលក្រិត្យ ក្សត្រាមើលបុទ្ធ៍
ទាហានមើលចេស្តា ជាងមើលអំពើ
អំពីហត្ថា ទោះយកករិយា
មើលនាលំនៅ ៗ អាសាគ្គបី
បណ្តាំមេដឹ ព្រេងព្រឹទ្ធប្រជា
អង្គរសសុទ្ធ ចំអិនឲ្យឆៅ
ពីសីហើយខ្មៅ ផ្កាដូតគមារយោទ ៗ
អ្នកបួសឥតក្រិត្យ ចាស់ឥតប្រព្រឹត្ត
ខ្សត់ប្រើនប្រមាទ ករិយាផុយផាយ
ចាយព័យត់តខ្នាត ពលពាលសុទ្ធសាត
ប្រដៅក្រុបាន ៗ ជុះក្លើងមានបី

អំពើពុតស្រី ទំនត់ប្រមាណ
កូនកាបចចេស ពុំដោយដំបូន្មាន
ខ្ញុំកាចកៀសប្រាណ ពុំឲ្យម្ចាស់ប្រើ ៗ
ហោកប្រើគ្រូ កូមប្រើមូល
ស្ទង់ទឹកប្រើស្នូ បន្ទាត់ប្រើត្រង់
ពាលផ្តន់គប្បីប្រើ ពុំហើយគប្បីធ្វើ
កុំលែងគប្បីភ្ជា ៗ ក្តីកោតមានបី
កោតមួយពួកស្រី ស្រដីមាយា
កោតមួយពាក្យពិស អាស្រូវដៅថា
កោតមួយពាក្យពា- លោលោកខ្វះផន ៗ
ពិសពស់នានា កុយខ្លាយខ្ទា
កាលគតស្តាប់មន្ត ត្រង់ពិសពាក្យពាល
ពេលកលពុំស្រន្ត សូម្បីអស់ជន្ន
ក្រមន្តបោសបាន ៗ ហេតុនោះគួរគិត
គួររិះរកហិត ថ្នាំពិសឲ្យស្រាន្ត
ដ៏លោកនេះគួរ រកអ្នកខ្ទង់ញាណ

សេពសាធសីលទាន　ជាថ្នាំលោកិយ ៗ
រឺថ្នាំបរលោក　បៀសបាកទុក្ខសោក
បង់បញ្ចឥន្ទ្រិយ　គប្បីផឹកសត្តតិង្ស-
ពោធិបក្ខិយ　អាចនាំដល់ត្រី-
ពិធសម្បត្តិសារ ៗ　ពិដោរផ្កាបី
ពិដោរមេត្រី　សួសីហោតារ
ពិដោរបរិសុទ្ធ　កុសលសម្ភារ
ពិដោរនេះជាល　ដល់សួគិពុំស្បើយ ៗ
ពិដោរផ្កាបី　នៃក្រៃលែងក្លិនក្រី
ឥតឯល្ហែល្ហើយ　ដោយខ្យល់ច្រាសខ្យល់
ទៅត្រើយឆ្ងង់ត្រើយ　ពិដោរពុំស្បើយ
ហៅសេគន្ធា ៗ　ពិសាផ្លែប្រាំ
ពិសារសេធម៌　ពិសាសត្យា
ពិសាសីលទាន　ទ្រើសទ្រង់ករុណា
ពិសារសេក-　ពាបេញមគ្គ ៗ

ពិសាផ្លែប្រាំ | គិតជានាយនាំ
ឥន្ទ្រិយទៅចូល | ត្រិពិធសម្បត្តិ
ទិព្វរតនអនុកូល | បំណោរទៅចូល
មោក្ខមាគាល័យ ៗ | នេះជាច្បាប់ធម៌
ប្រសើរមហាគាប់ | ឧត្តមពេកក្រៃ
ក្រអ្នកណាបាន | ប្រាជ្ញាឈ្លាសវៃ
អាចដឹងដោយន័យ | សេធម៌គាថា ៗ
គួររេះគួរចាំ | គួរតាមបណ្ដាំ
ទូលទុកសិរសា | ធម៌នេះស្មើក្សីរ
អម្រឹតធារា | សម្ដេចភគវា
សាធុប្រុសប្រាណ ៗ | អ្នកណាបានស្ដាប់
អ្នកណាបានត្រាប់ | អ្នកណាបានធ្យាន
សេធម៌នេះគាប់ | ជាច្បាប់ខ្ជាន
អ្នកនោះស្មើបាន | ដល់ទិព្វានហោង ៗ

# ព្រហ្មចរិយកថា

# របស់ព្រះមហាសែស

(តនឹងចប់)

ឯសាវកភាសិត បានខាងធម៌ដែលសាវកពប់បញ្ចូលក្នុងបរិសទ្យ ទាំង ៤ បានសំដែងមានអនង្គណសូត្រ សម្មាទិដ្ឋិសូត្រ អនុមានសូត្រ ចុល្លវេទល្លសូត្រ មហាវេទល្លសូត្រ ជាដើម ។

ឯឥសិភាសិត បានខាងធម៌ដែលពាហិរបរិញ្ញាជក គឺអ្នកបួសខាងក្រៅបានសំដែង មានបរិញ្ញាជកវគ្គទាំងអស់ជាដើម ។

ឯទេវតាភាសិត បានខាងធម៌ដែលទេវតាបានសំដែង គឺធម៌មានទៅក្នុង ទេវតាសំយុត្ត ទេវបុត្តសំយុត្ត មារសំយុត្ត ព្រហ្មសំយុត្ត និង សក្កសំយុត្ត ជាដើម ។

តអំពីនេះទៅនឹងជ្រើសរើសយកគាថាផ្សេងៗ យកសំដែងដើម្បីញុំាងសាធុជនឲ្យជ្រាបក្នុងភាសិតទាំង ៤ នោះ ។

សេចក្ដីថា មានទេវតា ១ ចុះមកពោលគាថានេះក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

នន្ទតិ បុត្តេហិ បុត្តិមា
គោមិកោ គោហិ តថេវ នន្ទតិ
ឧបធី ហិ នរស្ស នន្ទនា
ន ហិ សោ នន្ទតិ យោ និរុបធិ ។

(ប្រែថា) អ្នកមានកូនច្រើនរមែងត្រេកអរនឹងកូនទាំងឡាយ អ្នកមានគោច្រើនរមែងត្រេកអរនឹងគោទាំងឡាយដូចគ្នា ឧបធិគឺកាមគុណទាំង ៥ ជាទីត្រេកអរនៃជន ជនឯណាគ្មានឧបធិ ជននោះមិនត្រេកអរឡើយ ។

(គាថានេះ ជាទេវតាភាសិត)

ព្រះដ៏មានព្រះភាគទ្រង់ភាសិតថា

សោចតិ បុត្តេហិ បុត្តិមា
គោមិកោ គោហិ តថេវ សោចតិ
ឧបធី ហិ នរស្ស សោចនា
ន ហិ សោ សោចតិ យោ និរូបធិ ។

អ្នកមានកូនច្រើនរមែងសោយសោកនឹងកូនទាំងឡាយ អ្នកមានគោច្រើនរមែងសោយសោកនឹងគោទាំងឡាយដូចគ្នា ឧបធិជាទីសោយសោកនៃជន ជនឯណាគ្មានឧបធិ ជននោះមិនសោយសោកឡើយ ។

(គាថានេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកពោលគាថានេះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

នត្ថិ បុត្តសមំ បេមំ　　នត្ថិ គោសមិតំ ធនំ
នត្ថិ សុរិយសមា អាភា　　សមុទ្ទបរមា សរា ។

(ប្រែថា) សេចក្ដីស្រឡាញ់អ្វី មិនស្មើនឹងសេចក្ដីស្រឡាញ់កូនឡើយ ទ្រព្យអ្វីមិនស្មើនឹងទ្រព្យគឺគោឡើយ ពន្លឺអ្វីមិនស្មើនឹងពន្លឺព្រះអាទិត្យឡើយ ស្រះទាំងឡាយមានសមុទ្រជាយ៉ាងក្រៃលែង គឺថាសមុទ្រដ៏ឧត្តមធំទូលាយជាងស្រះទាំងឡាយ ។

(នេះជាទេវតាភាសិត)

ព្រះដ៏មានព្រះភាគទ្រង់ភាសិតថា

នត្ថិ អត្តសមំ បេមំ　　នត្ថិ ធញ្ញសមំ ធនំ
នត្ថិ បញ្ញាសមា អាភា　　វុដ្ឋិ វេ បរមា សរា ។

(ប្រែថា) សេចក្ដីស្រឡាញ់អ្វីមិនស្មើនឹងសេចក្ដីស្រឡាញ់ខ្លួន ទ្រព្យអ្វីមិនស្មើនឹងទ្រព្យគឺស្រូវ ពន្លឺអ្វីមិនស្មើនឹងពន្លឺគឺបញ្ញា ស្រះទាំងឡាយមានភ្លៀងជាយ៉ាងក្រៃលែង គឺថាភ្លៀងដ៏ឧត្តមជាងស្រះទាំងឡាយ ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកពោលគាថានេះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

ខត្តិយោ ទិបទំ សេដ្ឋោ ពលិពទ្ទោ ចតុប្បទំ
កោមារី សេដ្ឋា ភរិយានំ យោ ច បុត្តាន បុព្វជោ ។

(ប្រែថា) ក្សត្រប្រសើរវិសេសជាងសត្វមានជើងពីរ សត្វគោប្រសើរវិសេសជាងសត្វមានជើង ៤ ភរិយាដែលយកអំពីក្មេងប្រសើរវិសេសជាងភរិយាទាំងឡាយ កូនឯណាកើតមុនគេ កូននោះប្រសើរជាងកូនទាំងឡាយ ។

(នេះជាទេវតាភាសិត)

ព្រះដ៏មានព្រះភាគទ្រង់ភាសិតថា

សម្ពុទ្ធោ ទិបទំ សេដ្ឋោ អាជានីយោ ចតុប្បទំ
សុស្សូសា សេដ្ឋា ភរិយានំ យោ ច បុត្តានមស្សវោ ។

(ប្រែថា) ព្រះសម្ពុទ្ធប្រសើរវិសេសជាងសត្វមានជើងពីរ សត្វអាជានេយ្យប្រសើរវិសេសជាងសត្វមានជើង៤ ភរិយាដែលស្តាប់បង្គាប់ស្វាមីប្រសើរវិសេសជាងភរិយាទាំងឡាយ កូនឯណាដែលស្តាប់បង្គាប់មាតាបិតា កូននោះប្រសើរជាងកូនទាំងឡាយ ។

(នេះពុទ្ធភាសិត)

មានទេវតា ១ ពុះបកពោលគាថានេះក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

និទ្ទា តន្ទី វិជម្ភិតា អរតី ភត្តសម្មទោ
ឯតេន នប្បកាសេតិ អរិយមគ្គោ ឥធ បាណិនំ ។

(ប្រែថា) សេចក្តីលក់ សេចក្តីខ្ជិលច្រអូស សេចក្តីមិតពត់កាយ សេចក្តីអផ្សុកនឹងសេចក្តីស្រវឹងបាយ. រមែងមាននៅក្នុងសន្តាននៃសត្វ អរិយមគ្គរមែងមិនរុងរឿង មិនប្រាកដដល់សត្វទាំងឡាយ ក្នុងលោកនេះ ក៏ព្រោះធម៌មានសេចក្តីលក់ជាដើមនេះឯង ។

(នេះជាទេវតាភាសិត)

ព្រះដ៏មានព្រះភាគទ្រង់ភាសិតថា

និទ្ទំ តន្ទឹ វិជម្ភិតំ អរតឹ ភត្តសម្មទំ
វីរិយេន នំ បណាមេត្វា អរិយមគ្គោ វិសុជ្ឈតិ ។

(ប្រែថា) អរិយមគ្គតែងបណ្តេញនូវកិលេសជាតិនោះៗ គឺសេចក្តីលក់ ១ សេចក្តីខ្ជិលច្រអូស ១ សេចក្តីមិតពត់កាយ ១ សេចក្តីអផ្សុក ១ សេចក្តីស្រវឹងបាយ ១ ហើយបរិសុទ្ធបាន ដោយសេចក្តីព្យាយាម ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកក្រាបទូលសួរព្រះអង្គថា

កតិ លោកស្មឹ បជ្ជោតា យេហិ លោកោ បកាសតិ
ភគវន្តំ បុដ្ឋុមាគម្ម កថំ ជានេមុ តំ មយំ ។

( ប្រែថា ) លោកវមែងភ្លឺច្បាស់ដោយពន្លឺឯណា ពន្លឺនោះមានប៉ុន្មាន ក្នុងលោក ខ្ញុំមកដើម្បីសួរព្រះអង្គ ដូចម្ដេចទើបដឹងរឿងនោះបាន ។

( នេះជាទេវតាភាសិត )

ព្រះអង្គទ្រង់ភាសិតថា

ចត្តារោ លោកេ បជ្ជោតា បញ្ចមេត្ថ ន វិជ្ជតិ
ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា
អថ អគ្គិ ទិវា រត្តិំ តត្ថ តត្ថ បភាសតិ
សម្ពុទ្ធោ តបតំ សេដ្ឋោ ឯសា អាភា អនុត្តរា ។

( ប្រែថា ) ពន្លឺមាន ៤ ក្នុងលោក ពន្លឺជាគំរប់ ៥ មិនមានក្នុងលោក នេះឡើយ ព្រះអាទិត្យភ្លឺក្នុងវេលាថ្ងៃ ព្រះចន្ទ្រភ្លឺក្នុងវេលាយប់ ចំណែក ភ្លើងភ្លឺទាំងយប់ទាំងថ្ងៃ ក្នុងទីនោះ ៗ ព្រះសម្ពុទ្ធប្រសើរវិសេសជាងពន្លឺ ទាំង ៣ នោះ នេះជាពន្លឺដ៏ប្រសើរ ។

( នេះជាពុទ្ធភាសិត )

មានទេវតា ១ ចុះមកក្រាបទូលសួរព្រះអង្គថា

ឧត្តុឧត្តំ នវហារំ ខុណ្ណំ ពេភាគេន សំយុត្តំ
បត្តជាតំ មហាវីរ កថំ យាត្រា ភវិស្សតិ ។

(ប្រែថា) បពិត្រព្រះអង្គមានព្យាយាមធំ សរីរៈនេះមានចក្កបួន គឺឥរិយាបថទាំងបួន មានទ្វារ ៩ ពេញដោយអសុចិ ប្រកបព្រមដោយលោភគឺតណ្ហា កើតអំពីភក់គឺកិលេស នឹងចេញទៅឲ្យផុតអំពីសរីរៈនេះដូចម្ដេចបាន ។

ព្រះអង្គទ្រង់ភាសិតថា

ឆេត្វា នទ្ធឹ វរត្តញ្ច ឥច្ឆាលោភញ្ច បាបកំ
សមូលំ តណ្ហំ អព្ពុយ្ហ ឯវំ យាត្រា ករិស្សតិ ។

(ប្រែថា) បុគ្គលកាត់នូវខ្សែបំណងនឹងខ្សែព្រ័ត្រ គឺការចងពៀរ កាត់នូវឥច្ឆាលោភដ៏លាមក ហើយដកនូវតណ្ហាព្រមទាំងឫសចោលចេញ នឹងចេញទៅឲ្យផុតអំពីសរីរៈនេះ ដោយប្រការដូច្នេះបាន ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកក្រាបទូលសួរព្រះអង្គថា

ឯណិជង្ឃំ កិសំ វីរំ   អប្បាហារំ អលោលុបំ
សីហំវេកចរំ នាគំ   កាមេសុ អនបេក្ខិនំ
ឧបសង្កម្ម បុច្ឆាម   កថំ ទុក្ខា បមុច្ចតិ ។

(ប្រែថា) ខ្ញុំចូលមកក្រាបទូលសួរព្រះអង្គ ដែលមានស្មងព្រះបាទមូលល្អដូចជាស្មងជើងសត្វម្រឹគទ្រាយ មានព្រះកាយស្គមល្មមល្អ មាន

ព្យាយាម មានអាហារតិច មិនមានសេចក្តីលោភ ត្រេចទៅតែ ១ ព្រះអង្គឯងដូចជាសត្វសីហទាំងដំរីដ៏ប្រសើរ មិនមានសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ព្រះបុគ្គលរួចចាកទុក្ខបាន ដោយប្រការដូចម្តេចទៅ ។

ព្រះអង្គទ្រង់ភាសិតថា

បញ្ច កាមគុណា លោកេ មនោឆដ្ឋា បវេទិតា
ឯត្ថ ឆន្ទំ វិរាជេត្វា ឯវំ ទុក្ខា បមុច្ចតិ ។

(ប្រែថា) កាមគុណទាំង ៥ មានចិត្តជាគំរប់ ៦ អ្នកប្រាជ្ញបានសំ-ដែងហើយក្នុងលោក បុគ្គលលះបង់នូវសេចក្តីប្រាថ្នា ក្នុងកាមគុណទាំងចិត្តនេះហើយ រមែងរួចចាកទុក្ខបានដោយប្រការដូច្នេះ ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកក្រាបទូលសួរព្រះអង្គថា

កេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា កេ ជនា សគ្គគាមិនោ ។

(ប្រែថា) បុណ្យតែងចំរើនសព្វ ៗ កាលទាំងយប់ទាំងថ្ងៃ ដល់បុគ្គលណាខ្លះ ជនដែលតាំងនៅក្នុងធម៌បរិបូណ៌ដោយសីល ទៅកាន់ស្ថានសួគ៌បានឬទេ ។

(នេះជាទេវតាភាសិត)

ព្រះអង្គទ្រង់ភាសិតថា

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។

(ប្រែថា) ជនឯណាជាអ្នកដាំច្បារ គឺឈើដែលមានផ្កាផ្លែជាប្រយោជន៍ ជាអ្នកថែទាំដើមឈើដែលដុះឡើងខ្លួនឯងក្នុងព្រៃ ជាអ្នកសាងស្ពាន មួយវិញទៀត ជនឯណាឲ្យនូវទឹក ឲ្យនូវរោងសម្រាប់ផឹកទឹកមានស្រះទឹងអណ្តូងជាដើម ទីជំរំនៅ បុណ្យតែងចំរើនសព្វ ៗ កាលទាំងយប់ទាំងថ្ងៃដល់ជននោះ ៗ ជនដែលតាំងនៅក្នុងធម៌បរិបូណ៌ដោយសីលនោះ រមែងទៅកាន់ស្ថានសួគ៌បាន ។

(នេះពាក្យភាសិត)

សម័យមួយ ព្រះមហាអានន្ទនិមន្តទៅបិណ្ឌបាតក្នុងនគរសាវត្ថីជាមួយនឹងវង្គីសភិក្ខុ ៗ ឯវង្គីសភិក្ខុ ក៏កើតមានសេចក្តីអផ្សុកឡើងមានរាគគ្របសង្កត់ចិត្ត ៗ វង្គីសភិក្ខុក៏ពោលគាថានេះនឹងព្រះមហាអានន្ទថា

កាមរាគេន ឌយ្ហាមិ ចិត្តំ មេ បរិឌយ្ហតិ
សាធុ និព្វាបនំ ព្រូហិ អនុកម្បាយ គោតម ។

(ប្រែថា) ឥឡូវនេះខ្ញុំក្តៅក្រហាយដោយកាមរាគ ចិត្តរបស់ខ្ញុំ ត្រូវកាមរាគដុតពេលឲ្យក្តៅក្រហាយ បពិត្រអានន្ទជាគោតមគោត្រ សូមលោកប្រាប់ឧបាយជាគ្រឿងរំលត់នូវកាមរាគដោយសេចក្តីអនុគ្រោះ ។

ព្រះមហាអានន្ទពោលឧទ្ទានថា

សញ្ញាយ វិបរិយេសា ចិត្តន្តេ បរិឌយ្ហតិ
និមិត្តំ បរិវជ្ជេហិ សុភំ រាគូបសញ្ហិតំ
សង្ខារេ បរតោ បស្ស ទុក្ខតោ មា ច អត្តតោ
និព្វាបេហិ មហារាគំ មា ឌយ្ហិត្ថោ បុនប្បុនំ
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ
សតិ កាយគតា ត្យត្ថុ និព្វិទាពហុលោ ភវ
អនិមិត្តញ្ច ភាវេហិ មានានុសយមុជ្ជហ
តតោ មានាភិសមយា ឧបសន្តោ ចរិស្សសិ ។

(ប្រែថា) ចិត្តរបស់លោកក្តៅក្រហាយ ព្រោះវិបល្លាសនៃសញ្ញា ចូរលោកលះបង់នូវនិមិត្តជាល្អ ដែលអាស្រ័យនូវរាគ ចូរលោកពិចារណានូវសង្ខារ ដោយថាជារបស់អ្នកដទៃ គឺថាជារបស់មិនទៀង ដោយថាជាទុក្ខ កុំពិចារណាដោយថាជារបស់ខ្លួនឡើយ ចូរលោករំលត់នូវរាគធំចេញ កុំក្តៅក្រហាយញយ ៗ ឡើយ ចូរចំរើនចិត្តដើម្បីអសុភ ចិត្តនោះក៏មានអារម្មណ៍តែមួយ តាំងនៅខ្ជាប់ខ្ជួនដោយប្រពៃ សតិ

របស់លោកចូរតាំងនៅក្នុងកាយ ចូរលោកធ្វើខ្លួនឲ្យជាបុគ្គលមានសេចក្តីព្យាយាមច្រើន ចូរចំរើននូវវិបស្សនា ដែលគេនិមិត្តគ្មាន ចូរលះបង់នូវអនុស័យគឺមានះ លោកនឹងបានជាបុគ្គលមានចិត្តស្ងប់រម្ងាប់ ព្រោះបានត្រាស់ដឹងដោយការឃើញ នឹងលះបង់នូវមានះ ក្នុងកាលជាខាងក្រោយមិនខានឡើយ ។

(នេះជាសាវកភាសិត)

ក្នុងកាលដ៏កន្លងទៅហើយ ព្រះបរមពោធិសត្វបួសជាតាបសឥសី នៅក្នុងប្រទេសព្រៃហិមពាន្ត មានកូនប្រុស ១ បួសជាតាបសនៅជាមួយដែរ ។ តាបសជាកូននោះ មានសេចក្តីអផ្សុកប្រាថ្នានឹងចេញអំពីព្រៃទៅនៅក្នុងស្រុក ហើយក៏លាពោធិសត្វជាបិតាទៅ ។ ព្រះពោធិសត្វក៏ទូន្មានតាបសជាកូនថា

យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កដំ
ឱរសីវ បតិដ្ឋាយ តំ ភជេហិ ឥតោ គតោ ។

(ប្រែថា) បុគ្គលឯណាគ្មានអំពើអាក្រក់ដោយកាយវាចាចិត្ត កូនឯងទៅអំពីព្រៃនេះ ចូរទៅដំកល់ខ្លួនទុកដូចជាកូនកើតចេញអំពីទ្រូង ហើយសេពគប់នឹងបុគ្គលនោះចុះ ។

យោ ច ធម្មេន ចរតិ ចរន្តោបិ ន មញ្ញតិ
វិសុទ្ធការី សប្បញ្ញំ តំ ភជេហិ ឥតោ គតោ ។

មួយវិញទៀត បុគ្គលឯណាប្រព្រឹត្តតាមធម៌ កាលដែលប្រព្រឹត្តដូច្នោះ ក៏មិនមើលងាយគេឡើយ កូនឯងទៅអំពីព្រៃនេះទៅ ចូរសេពគប់នឹងបុគ្គលនោះចុះ ព្រោះបុគ្គលនោះ ជាអ្នកធ្វើនូវកុសលកម្មបថដ៏បរិសុទ្ធ ជាអ្នកមានបញ្ញា ។

(នេះជាគិសីភាសិត)

ភាសិតទាំង ៤ ដូចបានសំដែងមកដោយសង្ខេបនេះ ជាសាសនាពាក្យប្រដៅ ៗ ដូចបានសំដែងមកនេះ ចាត់ជាព្រហ្មចរិយទី ១០ ហៅថាសាសនព្រហ្មចរិយ ។

ចប់ព្រហ្មចរិយកថា តែប៉ុណ្ណោះ ។

# រឿងព្រេង-គ្រូនិងសិស្ស

និយាយរឿងមួយ មានគ្រូសង្ឃ ១ អង្គគង់នៅវត្ត ១ មានកូនសិស្សតែម្នាក់ឈ្មោះអាផ្លូញ អាផ្លូញនោះខិលណាស់ គ្រូនោះល្ងង់ឆោតច្រើន ឯឧបាសកឧបាសិកា គ្មានអ្នកណាគប់អានយកចង្ហាន់ស្លាបព្រាទៅប្រគេនលោកនោះឡើយ ឬនិមន្តមកឆាន់ឯផ្ទះដល់មួយក៏គ្មាន លោកនោះក្រលំបាកពន់ពេក ។

តែលោកនោះមានដំរី ១ លោកពិចារណាថា សព្វថ្ងៃនេះគ្មានឧបាសកគេប្រគេនវត្ថុអ្វីឆាន់សោះ បើដូច្នោះគួរតែអញទិញវត្ថុផ្សេង ៗ យកមកទុកឆាន់កុំឲ្យលំបាក គិតដូច្នោះហើយក៏ប្រាប់កូនសិស្សថា អាផ្លូញឯងចាប់ដំរីមកហើយឯងទៅផ្សារនឹងអញទិញវត្ថុផ្សេង ៗ យកមកទុកឆាន់ កូនសិស្សក៏ទៅចាប់ដំរីបានមក នោះគ្រូនិងសិស្សក៏ឡើងជិះដំរីបរទៅផ្សារ លុះដល់គ្រូប្រាប់កូនសិស្សថា ឯងទិញវត្ថុអ្វីដែលទុកយូរបានមិនខូច អាផ្លូញជាកូនសិស្សក៏ទិញអំបិល ១ បុងប្រកការុងស្រែប គ្រូឃើញសួរថា អាឯងហេតុម្តេចក៏មិនទិញត្រីឆ្អើរត្រីងៀត ក៏ទិញឯអំបិលវិញ កូនសិស្សទូលគ្រូថា អំបិលទុកយូរបានមិនខូច បានជាខ្ញុំព្រះករុណាទិញ គ្រូឆោតល្ងង់ណាស់ក៏ស្ងៀម ។

ទើបគ្រូឡើងបរដំរីត្រឡប់មកវិញ សិស្សរែកអំបិលដើរពីក្រោយ ដល់ពាក់កណ្តាលផ្លូវគ្រូមើលទៅសិស្សហើយ ឮសូរដែលរែកដូចជាស្រួល

ក៏សួរសិស្សថា អាផ្អូញអញមើលទៅអាឯងរែកអំបិលដូចជាស្រួលប៉ុយ៉ាង
ណា សិស្សទូលគ្រូថា ខ្ញុំព្រះករុណារែកនេះស្រួលណាស់ហើយស្រាល
ផង លោកនោះក៏ប្រាប់សិស្សថា ឯងជិះដំរីវិញចុះ អញរែកអំបិលដើរពី
ក្រោយហើយចុះពីលើដំរីមក កូនសិស្សក៏ឡើងជិះដំរី នោះលោកប្រាប់ថា
ឯងបរដំរីទៅចាំអញនៅម្លប់ឈើឯមុខ សិស្សក៏បរដំរីទៅដល់ម្លប់ឈើ
ក៏មិនឈប់ចាំគ្រូបរហួសទៅដល់វត្ត ។

ចំណែកគ្រូ ក៏រែកអំបិលដើរតាមក្រោយដោយធុញណាស់ រែក
ហើយឈប់ ៗ ហើយរែកមើលទៅសិស្សមិនឃើញ លោកនោះគិតថា
អញរែកអំបិលនេះមិនរួចទេ ល្ហើយចុះ អញលាក់ទុកនៅទីនេះសិន ថ្ងៃ
ក្រោយសឹមនាំសិស្សមកយក គិតហើយក៏យកអំបិលទៅលាក់ក្នុងព្រៃ
លោកនោះគិតថា ទីនេះបើប្រសិនណាមានគេដើរមកត្រង់ គង់តែនឹង
ឃើញគេយកអស់មិនខាន គួរតែរកទីឯណាដែលកំបាំងភ្នែកអ្នកទាំងពួង
គិតឃើញតែក្នុងទឹកគេមើលមិនឃើញ ហើយក៏យកអំបិលទាំងពីរការុង
ទៅលាក់ទុកក្នុងទឹករួចដើរទៅ លុះដល់វត្តសួរសិស្សថា ហេតុម្តេចក៏អា
✓ ឯងមិនចាំអញ សិស្សនោះទូលថា ខ្ញុំព្រះករុណាបរដំរីមកប្រុងចាំលោក
គ្រូប្រាកដ តែដំរីវាមិនព្រមចាំ អង្វរវាដូចម្តេចក៏មិនព្រមវាប្រឹងដើរ
ដល់វត្តទើបវាឈប់ នោះសិស្សសួរគ្រូថា អំបិលលោកគ្រូទុកឯណា គ្រូ
ប្រាប់ថា អញលាក់ទុកនៅទីឯណោះអញកាប់ដើមឈូកដោតជាសំគាល់

លុះព្រឹកឡើងនាំកូនសិស្សទៅយកអំបិលវិញ លុះដល់ប្រាប់សិស្សថា អញលាក់ក្នុងទឹកត្រពាំងនេះ សិស្សលាន់មាត់ថា ឱប៉ើអើយរលាយអស់ហើយ ។ អាផ្លូញជាសិស្សក៏ចុះទៅយកអំបិលលើកការុងទាំងពីរឡើង រលាយអស់គ្មានសល់ ចំណងដែលចងមាត់ការុងជាប់អស់ ឃើញឯត្រីកញ្ចុះមួយនៅក្នុងការុងនោះ សិស្សទូលថា លោកគ្រូមានត្រីកញ្ចុះ ១ នៅក្នុងការុងវាស៊ីអំបិលអស់ទៅហើយ ។ យកត្រីនឹងការុងមកប្រគេនគ្រូមើល លោកនោះឃើញត្រីខឹងណាស់ក៏ទះកំផ្លៀងត្រីមុតដៃទឹងធ្ងងជាប់ ពិសត្រីក៏ចាប់ពើតឈឺពន់ពេកហើយថា ឯងចាប់ត្រីដកធ្ងងជាឆាប់ដ្បិតវាឈឺអញណាស់ សិស្សក៏ចាប់ដកទាញស្ទើរតែមិនរួច លុះដករួចឈាមហូរជាខ្លាំង ពិសរឹតតែឈឺខ្លាំងឡើង រួចនាំកូនសិស្សទៅវត្តវិញយកទាំងការុងនឹងត្រីកញ្ចុះទៅផង លុះដល់វត្តប្រាប់សិស្សថា អាផ្លូញឯងដាំបាយ ១ ឆ្នាំងត្រីកញ្ចុះនេះអាំងឲ្យឆ្អិនជាឆាប់អញទឹងធាន់ ពិសត្រីរឹតតែចាប់ពើតឈឺមិនបាត់ លោកនោះក៏សឹងលក់ទៅ ។

ឯអាផ្លូញក៏ដាំបាយអាំងត្រីឆ្អិនហើយបរិភោគអស់ ទុកតែបាយមួយពំនូតនឹងឆ្អឹងត្រីក្នុងចានមានគ្រប តែគ្របមិនឲ្យជិត លុះលោកគ្រូនោះភ្ញាក់ឡើងប្រាប់សិស្សថា ឯងយកបាយនឹងត្រីមកឆាន់ អាផ្លូញក៏ធ្វើកិរិយាដូចជាចូលទៅយកមកប្រគេនគ្រូ ក៏ចេញមកវិញទូលថា បាយនឹងត្រីរុយវាស៊ីអស់ទៅហើយ នៅសល់តែបាយមួយពំនូតនឹងឆ្អឹងត្រី លោកនោះក៏

ជឿតែសង្ស័យដោយភាពល្ងង់ ទើបគ្រូឲ្យរំពាត់ផ្តៅ ១ មកសិស្សថា ឯង វាយរុយកុំឲ្យវានៅលើកុដិ អាផ្លុញជាសិស្សក៏វាយរុយមិនឈប់ នោះរុយមួយវាទំចុងច្រមុះគ្រូ ៗ ប្រាប់ថា រុយវាទំច្រមុះអញ ឯងវាយឲ្យធាប់ កូនសិស្សក៏វាយតាមពាក្យគ្រូ វាយទៅៗមិនត្រូវរុយត្រូវឯច្រមុះគ្រូបែកឈាមហូរខ្លាយ សិស្សភ័យណាស់រត់ទៅផ្ទះនិយាយប្រាប់អាពុកម្តាយតាមរឿង អាពុកម្តាយប្រាប់កូនឲ្យបកវត្តវិញប្រកែកមិនព្រមមក លោកនោះទៅតាមក៏មិនបានមកដោយខ្លាចគ្រូវាយ ។

ថ្ងៃក្រោយគ្រូតាំងពិធីសូត្រមន្តអាគមស្នេហ៍បន្ទន់ចិត្តសិស្សឲ្យមកអា-ផ្លុញជាកូនសិស្សបានដឹងថាគ្រូតាំងពិធីមន្តអាគមស្នេហ៍ដូច្នោះហើយក៏មកវត្តវិញ ដើម្បីឲ្យគ្រូជឿថា ស្នេហ៍ពូកែ លុះដល់វត្តដើរលបចូលទៅឃើញគ្រូអង្គុយកំពុងតែសូត្រមន្តអាគមស្នេហ៍ក៏សួរថា លោកគ្រូធ្វើអ្វី គ្រូកុហកប្រាប់ថា អញសូត្រមន្តអាគមបំបាំងខ្លួនពីព្រោះអញទើបតែនឹងរៀនពីគេ ហើយលោកនោះគិតថា ស្នេហ៍អញពូកែមែន បានជាសិស្សអញវាមក លុះព្រឹកឡើងសិស្សដាំបាយធ្វើម្ហូបស្រេចទូលគ្រូថា បង្ហាន់ឆ្អិនហើយ លោកនោះថា បើដូច្នោះឯងលើកមកអញនឹងឆាន់ អាផ្លុញក៏លើកមកប្រគេនធ្វើជាមើលមិនឃើញដាក់ថាសទៅលើក្បាលគ្រូ ៗ ស្រែកថា អាផ្លុញហេតុម្តេចក៏ដាក់ថាសលើក្បាលអញ សិស្សទូលថា ខ្ញុំព្រះករុ-ណាមើលមិនឃើញ លោកនោះក៏ងាកចេញ អាផ្លុញក៏ដាក់ថាសលើ

ក្បាលគ្រូទៀត លោកនោះថា អាឯងដាក់ថាសលើក្បាលអញទៀតហើយ សិស្សថា ខ្ញុំព្រះករុណាសុំទោស ព្រោះមើលមិនឃើញ លោកនោះគិតក្នុងចិត្តថា អញរៀនស្នេហ៍ៗពូកែប្រាកដ ឥឡូវឃើញក៏ហាក់ថា តាំងពីពិធីមន្តអាគមបំបាំងខ្លួនវិញក៏ពូកែ គេមើលមិនឃើញប្រាកដមែន គួរទន្ទេញឲ្យចាំកុំឲ្យភ្លេច ។

ឯអាផ្លុញជាសិស្សក៏ប្រគេនចង្ហាន់គ្រូៗឆាន់រួចស្រេចសិស្សលើកមកបរិភោគតាមការ ។

ថ្ងៃក្រោយមានឧបាសកគេនិមន្តលោកទៅឆាន់ឯផ្ទះ នោះ អាផ្លុញទូលថា បើលោកគ្រូនិមន្តទៅឆាន់ឯផ្ទះគេកុំស្លៀកស្បង់ពាក់ខ្លួនឥតអំពើ ឃ្លុំតែចីពរបានហើយគេមើលមិនឃើញទេ ដ្បិតលោកគ្រូបេះមន្តអាគមបំបាំងខ្លួនពូកែណាស់ អ្នកណានឹងមើលឃើញ គ្រូក៏ជឿតាមពាក្យកូនសិស្ស ។

លុះព្រឹកឡើងលោកនោះប្រាប់សិស្សថា ឯងតាមអញទៅឆាន់ឯផ្ទះឧបាសករួចឃ្លុំចីពរតែស្បង់មិនស្លៀក ដោយគិតថាចីពរឃ្លុំហើយ ១ មន្តអាគមអញក៏ពូកែណាស់ផង នរណានឹងមើលកេរ្តិ៍ខ្មាសឃើញ រួចនាំកូនសិស្សទៅ ។

លុះដល់ឧបាសកនិមន្តឡើងទៅលើផ្ទះហើយ គេលើកចង្ហាន់មកដើម្បីប្រគេនឆាន់ លោកនោះដោយមិនបានស្លៀកស្បង់អង្គុយមិនស្រួល

ដាក់ឆ្នាំងដាក់ស្ពាក៏មិនស្រួល លេចក្ដីខ្មាសនៅកណ្ដាលវាល ឧបាសក គេឃើញដូច្នោះនាំគ្នាសើចហើយលាន់ លោកនោះពុំទាន់បានទាន់បង្អង់ មានចិត្តខ្មាសគេណាស់ក៏ចុះពីផ្ទះត្រឡប់មកដល់វត្តវិញហើយជេរបន្ទោស សិស្សថា អាឯងមិនឲ្យអញស្លៀកសំពត់ឡើងអញខ្មាសគេណាស់ អាផ្ញញជាសិស្សទូលថា លោកគ្រូកុំខ្ញាល់ទឹងខ្ញុំព្រះករុណា រឿងនេះប្រហែលជាខុសត្រណម គ្រូសួរថា ឯងឃើញអញធ្វើខុសត្រណមដូចម្ដេច នោះអាផ្ញញសួរថា កាលលោកគ្រូនិមន្តទៅឆាន់នៅផ្ទះឧបាសកនិមន្តទៅផ្លូវខាងណា គ្រូប្រាប់ថា អញកាលទៅចេញផ្លូវខាងកើត សិស្សថា ច្បាស់ជាលោកគ្រូខុសត្រណមមែនហើយ ថ្ងៃមុនលោកគ្រូប្រាប់ខ្ញុំព្រះករុណាថា បើរៀនមន្តអាគមទាំងពួងត្រូវឲ្យតមស៊ីផ្លែស្ពី សូម្បីតែមុបក្រោមដើមក៏មិនបានពិសាបមន្តអាគម ឥឡូវលោកគ្រូមុបក្រោមដើមស្ពីបានជាខុសត្រណមសាបមន្តអាគមអស់ ហេតុនេះបានជាគេឃើញក្ដីខ្មាសលោកគ្រូ គ្រូបានស្ដាប់ដូច្នោះហើយថា ឱអាផ្ញញរឿងតមនោះអញភ្លេចបានជាយ៉ាងនេះ ឯងថានោះពិតប្រាកដមែន លោកនោះដោយឆោតល្ងង់ក៏ជឿជាក់ឥតសង្ស័យ ឯអាផ្ញញជាសិស្សនៅបំរើគ្រូសុខសប្បាយតរៀងទៅ ។

រឿងគ្រូនឹងសិស្ស

ចប់តែប៉ុណ្ណេះ ។

ឧកញ៉ាប្រាជ្ញាធិបតីពាងហ្វាង ( យិន ) តែង

# ពិធីលើកភាសី

# ពិធីលើករាសី

វេលាដែលរាសីរបស់គេធ្លាក់អាប់ មានតែសេចក្ដីមិនស្រួលកើតឡើងញយ ៗ នឹងធ្វើអ្វីច្រើនតែមិនសម្រេចក្ដីប្រាថ្នា ឬកាលនឹងធ្វើការដែលសំខាន់ ៗ នោះចង់ឲ្យសម្រេចទុកឆាប់ទៅដូចបំណងក្ដី ឬប្រាថ្នានឹងឲ្យឡើងយសសក្ដិធំជាងប្រក្រតីនោះទៅក្ដី ពួកអ្នកដែលជឿក្បួនខ្នាតនេះ គេតែងរៀបចំធ្វើពិធីលើករាសីរបស់ខ្លួន ឲ្យរុងរឿងភ្លឺថ្លាឡើង ៗ ក៏តែការដែលធ្វើដូច្នោះនឹងយកជាពិតប្រាកដណាស់ពុំបាន ជួនកាលក៏ឃើញឲ្យផលមុតមែន ជួនកាលក៏សូន្យឈឹងទៅ តែនិស្ស័យមនុស្សយើងទេតើ កាលមានបំណងដូចម្ដេចហើយនឹងធ្វើខ្លួនឯងទៅតែម្ដងមិនកើត ក៏តាំងការរកនេះរកនោះមកជួយ ក្រែងលោសមប្រកប ក៏នាំគ្នាធ្វើត ៗ មក ទាល់តែជាប់ជាទំនៀម ត្រង់ពិតឬមិនពិតនោះទុកមួយអន្លើសិន ។

ក៏ឯរបៀបធ្វើនោះមានរបៀបផ្សេង ៗ ពីគ្នាតាមគតិរបស់អាចារ្យ អ្នកជាដើមការនាំឲ្យធ្វើ តែក៏មិនខុសឆ្ងាយពីគ្នាប៉ុន្មាន លើសខ្វះគ្នាត្រឹម ១ មុខ ២ មុខ ប៉ុណ្ណោះ កាលនឹងប្រមូលបែបអំបាលនោះមកសំដែងក្នុងទីនេះឲ្យអស់ដើងតែម្ដង ក៏ឃើញថា យឺតយូរណាស់ ឬថា ផុតវិស័យនឹងប្រមូលមកក៏បាន ។ ហេតុនោះ ទើបសូមនាំយកបែប ១ មកសំដែងទុកជាតួយ៉ាងតែល្មមសមគួរ ដូច្នេះ:

ឲ្យធ្វើបាយសីធំ ១ កំពស់ដំហរអ្នកសាម៉ីខ្លួន បាយសីប៉ាក់ឆាម ១ គូ, ស្លាធ័រ ១ គូ, ទឹកអប់ ១ គូ, ទៀន ៤, ធូប ៤, ផ្កា ៤, លាជ ៤, ថ្វាយជាតុរូបផ្កា ៗ ទឹងរៀបគ្រឿងសំណែន គឺរោកយប្រាំក្រុក ១. កន្ទោង ៤ ដាក់បាយមួបចំណីតាមទំនៀម, ធត្រូត ៤, ទឹងរូបស្នងខ្លួន ១, ដាក់ក្នុងតែនោះ(១) ទឹងរៀបស្លាធ័រ ៨ ទឹកអប់ឲ្យរៀបដាក់អមខាងខ្លួនអ្នកសាម៉ីម្ខាងប្អូន ៗ ។

ឲ្យរៀបសែនហើយ ទិមន្តលោកចំរើនបរិត្តលើកកសីទៅតាមទំនៀម ដែលធ្លាប់ស្ប្រតរៀងមក ដូចគ្នានឹងពិធីស្ត្រមន្តរំដោះគ្រោះ ។

ចប់អស់សេចក្តីតែប៉ុណ្ណោះ ។

---

១ ដូចកាលគេធ្វើពែមឈ្មួស ១ ទៀតផង ដូចពោលហើយក្នុងរឿងបណ្តោះគ្រោះ ។

# បញ្ជីរឿង


១ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . . . ៨៧

២ — រឿងកុទ្ធប្រវត្តិរៀបរៀងតាមលំដាប់ ន មោ. ក ១. . . . . . . . . . . . ៩៣

៣ — ប្រជុំពាក្យកាព្យ ភាគទី ២ (តទី ៥). . . . . . . . . . . . . . . ១០៣

៤ — វយប្បកាសិនី (តនឹងចប់). . . . . . . . . . . . . . . . ១១៩

៥ — កុសលកម្មបថ ១០ (ពាក្យកាព្យ) របស់អាចារ្យ ហ.ឈា . . . . . . ១៣៧

៦ — រឿងព្រេង — បុរសពីរនាក់ . . . . . . . . . . . . . . . . . . ១៤៧


## រូបក្រៅរឿង


ប្រទេសលាវ - ស្រុកវៀងចន្ទន៍ វត្តអិនប៉ែង រូបហោត្រៃ . . . . . . . . ៨៥

# TABLE DES MATIÈRES


| | Pages |
|---|---|
| 1. Informations diverses | 87 |
| 2. La vie du BOUDDHA Poème alphabétique | 93 |
| 3. Recueil de Poèmes; 2e partie par Préas Bat Samdach Préas SREYTHAMMARÉACHÉA (suite) | 103 |
| 4. Vayappakâsini par Achar HIM (suite et fin) | 119 |
| 5. Kusalakaminapatha par Achar H. CHHÉA | 137 |
| 6. Contes populaires cambodgiens inédits : L'aventure de deux hommes | 147 |


HORS TEXTE :


LAOS : VIENTIANE, Vat IN-PÉNG, la Bibliothèque ............ 85



ប្រទេសលាវ-ស្រុកវៀងចន្ទ វត្តអិនប៉ែង រូបហោត្រៃ

ដំណឹងផ្សេង ៗ

# អំពីសារប្រយោជន៍នៃសៀវភៅ

✓ នៅឱកាសដែលព្រះរាជិនីនិងសម្តេចព្រះរាជជននីនៃប្រទេសអង់គ្លេស ស្តេចមកប្រពាតមហានគរបារាំងសែស ៗ ក្រុងប៉ារីសបានទទួលព្រះនាង ក្រុងអង់គ្លេសដោយគ្រឿងបណ្ណាការសុទ្ធតែមានដំឡៃថ្លៃថ្លា ហើយបាន ថ្វាយសៀវភៅភាសាបារាំងសែស ដែលមានប្រយោជន៍ជាអនេកដល់ព្រះ រាជកុមារីជាព្រះរាជបុត្រី គឺសៀវភៅនិទានមានរូបប្រកប, ពង្សាវតារ, វិ- ទ្យាសាស្ត្រ, មគ្គុទ្ទេស ប៉ារីស (guides sur Paris) សៀវភៅរូប, ឃ្លោង កាព្យជាដើម សុទ្ធសិងបោះពុម្ពដោយក្រដាសយ៉ាងល្អ ៗ ហើយមាន ពាក្យឧទ្ទិសរបស់អ្នកតែងអស់នោះគ្រប់រូប ៗ សៀវភៅអស់នេះហើយ ដែលចុះឲ្យឃើញគំនិតនឹងប្រាជ្ញានៃមហានគរបារាំងសែស ៗ ដំណើរ នេះសំដែងឲ្យយើងយល់ថា សៀវភៅអស់នោះទុកជារបស់ដែលមាន សារត្ថប្រយោជន៍ដ៏សំខាន់ ក្នុងជីវិតជនជាតិឧរុបក្នុងសម័យបច្ចុប្បន្ននេះ សៀវភៅអស់នេះទុកស្មើមាសពេជ្រដែលមានដំឡៃ ហើយជារបស់គួរ ថ្វាយដល់ព្រះរាជកុមារីនៃប្រទេសដ៏សំខាន់បំផុតមួយក្នុងលោកនេះ ៗ

យើងមានសង្ឃឹមទុកថា មិនយូរប៉ុន្មានទេ នៅស្រុកខ្មែរយើងនេះ លោកអ្នកកល់គ្នាគង់នឹងមានសេចក្តីយល់ច្បាស់អំពីសារត្ថប្រយោជន៍ នៃ

សៀវភៅ ដែលជារបស់ជួយបំភ្លឺសតិបញ្ញារបស់ប្រជាជន ក្នុងស្រុកយើងនេះតាមទំនងនោះដែរ ។

## អំពីសភាពរុក្ខជាតិ

មានអ្នកតែងសៀវភៅម្នាក់ឈ្មោះ លោកអេហេរេគូស (Ehé recusl) តាំងអំពី ៦០ ឆ្នាំមកហើយ លោកនេះបានស្លាប់ទៅចំនួន ៣០ ឆ្នាំមកហើយ ប៉ុន្តែកេរ្តិ៍ឈ្មោះសៀវភៅលោកមិនបាស់ស្លាប់ទៅផងទេ ដ្បិតសៀវភៅរបស់លោកមានប្រយោជន៍ជាអនេកដល់មកសព្វថ្ងៃនេះ ព្រោះមានសេចក្ដីពន្យល់អំពីសេចក្ដីពិតដ៏ទៀងទាត់ ។

សៀវភៅនេះមិនបានពន្យល់អំពីព្រឹក្សាស្ត្រដូចជាឈ្មោះខាងលើនេះទេ គឺជាសៀវភៅនិយាយអំពីចរិយាដ៏ល្អនិងបរមត្ថវិជ្ជាជាន់ខ្ពស់ទុកស្មើរុក្ខជាតិដែលលូតលាស់បំរើនឡើងនៅស្រុកបារាំង ។

មានអ្នកប្រាជ្ញធំម្នាក់ទៀតនៅស្រុកបារាំងមានសេចក្ដីសរសើរគុណសៀវភៅរបស់លោកអេហេរេគូសណាស់បានបញ្ចេញវាចាថា "អ្នកដែលមិនបានជួបនឹងលោកអេហេរេគូសនេះ ទុកជាមនុស្សឥតភ័ព្វសំណាងមួយជាតិ" ។

ឯសត្វលោកដែលកើតមកក្នុងលោកមិនទាន់ពុទ្ធកាល ឬទាន់ជំ-បុន្មានព្រះពុទ្ធ ក៏ទុកជាមនុស្សឥតភ័ព្វសំណាង ឃ្លាងចាកប្រយោជន៍

ដែលខ្លួនត្រូវបានទទួលកម្មបច្ចុប្បន្ននេះដែរ ។ ការប្រៀបធៀបសេចក្តីបែបនេះ នាំឲ្យយើងឃើញដំឡៃដ៏ធំអស្ចារ្យរបស់លោកអ្នកតែងសៀវភៅនោះ

សេចក្តីឧបមារបស់អ្នកប្រាជ្ញឧរុបនោះ យើងជាពុទ្ធសាសនិកជនមិនបាច់យល់ស្របតាមយោបល់នេះទេ ដ្បិតយើងយល់ច្បាស់ជឿជាក់ថាព្រះពុទ្ធជាម្ចាស់នោះព្រះអង្គបរិសុទ្ធស្អាតចាកគ្រឿងសៅហ្មងគ្រប់ប្រការ មានព្រះខន្ធសន្តានស្អាតហ្មត់ចត់មិនប្រឡាក់ដោយកិលេសតណ្ហាទាំងពួងឡើយ ទ្រង់ជាសព្វញ្ញូត្រាស់ដឹងញេយ្យធម៌ទាំងពួងដោយព្រះអង្គឯង មានដំឡៃក្រៃលែងលើសសត្វលោកទាំងត្រៃភព ដោយធម្មចរិយា ដោយបំណេះវិជ្ជា ដោយសេចក្តីប្រព្រឹត្តបរិសុទ្ធគ្រប់ប្រការ ។

ការដែលអ្នកប្រាជ្ញឧរុបនាំយកលោកអេហេវេគុសមកប្រៀបផ្ទឹមនឹងព្រះពុទ្ធជាម្ចាស់នេះ ដោយគេយល់ថា ព្រះពុទ្ធជាអ្នកប្រាជ្ញមួយ ដូចជាអ្នកប្រាជ្ញស្រុកឧរុបដែរ ឯយើងកល់គ្នាជាពុទ្ធសាសនិកជនមិនបាច់យល់ស្របតាមយោបល់របស់គេឡើយ យើងមិនបាច់គិតវែងឆ្ងាយទេ តែត្រឹមប៉ុណ្ណេះបានហើយ គឺអនុសាសនីរបស់ព្រះពុទ្ធកន្លងមកជិត ២.៥០០ ឆ្នាំហើយ ឯអនុសាសនីរបស់អ្នកប្រាជ្ញនោះទើបមានអាយុបាន ៦០ ឆ្នាំប៉ុណ្ណោះ ។ អនុសាសនីព្រះពុទ្ធផ្សាយចេញទៅស្ទើរពេញលោក មានចំនួនពុទ្ធបរិសទ្យរាប់ដោយកោដិលាន ៗ ឯអនុសាសនីអ្នកប្រាជ្ញនោះមិន

ប្រាកដស្តែងក្នុងលោក ដូចជាសាសនាទាំងឡាយទៀត បើមានដំឡៃខុសគ្នាឆ្ងាយដូច្នេះតើគួរនាំមកប្រៀបធៀបគ្នាដែរឬអ្វី ?

# អំពីការសិក្សានៅស្រុកចិន

## ក្នុងខណៈដែលមានចម្បាំង

នៅស្រុកចិននោះ មានខេត្តមួយជាខាងជើងស្រុកចេនសី ពួកចិនបានសាងសាលាបង្រៀនជាច្រើនសម្រាប់រៀនសូត្រ ហើយពួកសិស្សនៅក្នុងរូងថ្មដែលគេវាត់បែងជីកឡើងដោយខ្លួនឯងនៅក្បែរជើងភ្នំ ។

នៅទីនោះមានសាលាបង្រៀនបែបថ្មី, សាលាបង្រៀនបទល្ខោន និងមន្ទីរពេទ្យ ។ ឯចំនួនសិស្សស្រីមានច្រើនជាងសិស្សប្រុស ។ ហើយពួកស្រី ៗ អស់នេះនៅក្នុងកន្លែងដូចជាក្មេងប្រុស ៗ ដែរ ។

មន្ទីរពេទ្យនោះ មានអ្នកជម្ងឺចូលមកដេកថែរក្សាជម្ងឺចំនួន ៥០០ នាក់ រាល់ ៗ ថ្ងៃ ហើយជីករូងថ្មក្នុងភ្នំនៅដូចគ្នាដែរ ។

នៅសាលាអស់នោះ ដល់ពេលរៀនគោរពចេញទៅរៀនកណ្ដាលវាល មានរោងពុម្ពសម្រាប់បោះពុម្ពសៀវភៅ ហើយឃើញមានតែពួកស្រី ៗ ធ្វើការងារក្នុងរោងពុម្ព ហើយមានកាសែតដែលបោះផ្សាយចេញដោយគ្រឿងរោះដោយដៃផង ។

មានពួកចិនដែលមកអំពីទិសខាងត្បូងស្រុកចិន , អំពីទ្វីបអាមេរិក មកនៅក្នុងស្រុកចិនត្រង់ចំណែកនោះ មានចំនួនទាំងពាន់ដើម្បីសិក្សារៀនសូត្រនឹងធ្វើការបម្រើប្រទេសរបស់ខ្លួន ។ បានចំនួនសំបុត្រសុំចូលរៀនដល់ទៅ ៥០.០០០ ច្បាប់ កំពុងរង់ចាំសេចក្តីអនុញ្ញាត ដើម្បីឲ្យបានធ្វើជានិស្សិត ( សិស្ស ) ក្នុងមហាវិទ្យាល័យដ៏ចំឡែកនេះ សូម្បីមនុស្សអស់នោះជាមនុស្សសម័យថ្មីមកហើយក៏ដោយ (ប៉ុន្តែការបង្រៀនក្នុងសាលានោះមិនមែនធ្វើឲ្យកាន់តែថ្មីឡើងទៀតទេ ) គឺជាកន្លែងសិក្សាធ្វើឲ្យមនុស្សវិលត្រឡប់ទៅរកសម័យបុរាណវិញ កាលពីសម័យមនុស្សដីករូងថ្មចូលជ្រកអាស្រ័យនៅតាមរអាងភ្នំហ្នឹងឯង ។

( នេះហើយដែលហៅថា សំសារចក្រមានទំនងដូចជាកាំត្រាបកាំជួនកង់រទេះ កង់របស់សំសារវដ្ត តែងបង្វិលសត្វឲ្យវិលវល់ក្រឡាប់ផ្កាប់ផ្ការជាធម្មតា នៅក្នុងមហាសមុទ្រពោលគឺសំសារវដ្តៈនេះ ឥតមានអាការទ្រឹងនៅឬឈប់សម្រាកដល់មួយស្របក់សោះឡើយ ) ។

# រឿងពុទ្ធប្រវត្តិ

## រៀបរៀងតាមលំដាប់អក្សរ " ង អោ, គា ១ ".

### វន្ទនប្បណាមគាថា

យុត្តោ ធាតុនគរេ ពុទ្ធំ លោកគ្គំ នាយកំ
សទ្ធម្មញ្ច សុធម្មំ សង្ឃគណំ នមាមិហំ ។

## បទនមស្សការពាក្យ ៧

នាមខ្ញុំគួ "យ" ដាក់ស្រៈ "ុ" ខ្សល់ "ត" នៅមុខតម្រួតពីរ.
ស្រុកស្រែកំណើតកើតនៅទី ធារីខណ្ឌពួកខេត្តសៀមរាប ។
ឯនាមបិតាអក្សរ "ម" ស្រៈ "អា" ខ្សល់ "ស" ល្អសុភាព
លោកបានឆ្លុះយល់ផ្លូវបុណ្យបាប ស្គាល់កិច្ចខ្ពស់ទាបល្អិតសុខុម ។
ខ្ញុំម្ចាស់សូមថ្លែងបែបកាព្យ សំដែងពណ៌នាដោយនិយម.
រឿងពុទ្ធប្រវត្តិល្អិតឧត្តម តែងតាមលំនាំបបមត្រាស់ ។
ព្រមទាំងរៀបរៀងគួរគ្នាក ទុកជាដើមយ្យាដើមយោងល្អះ
តាំងពី "ង អោ" ដល់ "អាំ អះ" ពណ៌នារួតរះកាត់ខ្ញី ៗ ។
រួបថ្លែង "គាថា ១" ដល់ "ឡអំ" កាលមារចូលច្បាំងព្រះជិនស្រី
ព្រះអង្គទ្រង់ឈ្នះដោយបារមី ស្ដេចមារបរាជ័យចាញ់បេក្ខា ។

ហេតុដល់អគ្គព្រះលោកនាថ　ទ្រង់មានអាពាធក្នុងកាយា
ទ្រង់ផ្ទុំលើថ្មខែនសិលា　ផ្តាំផ្ញើសាសនាទឹងបរិសុទ្ធ ។
មានព្រះអានន្ទជាដើមអាទិ៍　ឲ្យខំសង្វាតឃ្លាតប្រតិបត្តិ
កុំបីប្រមាទត្រូវប្រយ័ត្ន　ព្យាយាមដុសខាត់ប្រាជ្ញាញាណ ។
លុះទ្រង់ត្រាស់ផ្តាំស្រេចកាលណា　ទើបពិចារណានូវអគ្គឈាន
រំលត់សង្ខារឧបាទាន　យាងចូលនិព្វានស្ថានសុខា ។

ន. នឹកដល់គុណព្រះបរមគត　ព្រះអង្គជាម្ចាស់លើសលោកា
ជាទីជ្រកកោនមនុស្សទេវតា　តែងតឹងដោយសារបុណ្យបារមី ។
មោ. មានមនោនឹកមមៃ　ដល់ព្រះធម៌ថ្លៃព្រះជិនស្រី
ជាទីស្រោចស្រង់ជនប្រុសស្រី　ឲ្យផុតកពីអស់ទុក្ខា
ពុ. សូមពណ៌នាគុណព្រះសង្ឃ　លើកករកំបង់នមស្ការ
ចំពោះព្រះសង្ឃទ្រង់សិក្ខា　លះកាត់តណ្ហានឹងមានះ ។
ទ្ធា. ធៀបដូចគុណឧបជ្ឈាយាចារ្យ　ប្រដៅធម៌អាថិការជ្រៅក់
ប្រាប់កិច្ចខុសត្រូវផ្លូវតែលក្ខណ៍　ខ្ញុំសូមគារវៈដោយចិត្តស្មោះ ។
យ. យោគដល់គុណលោកមាតា　ជាគុណអស្ចារ្យប្រសើរខ្ពស់
នឹងគុណបិតាឥតហ្មងមោះ,　សគ្រោះថាគុណធ្ងន់ឧត្តម ។
សិ. សូមសិរីជ័យតេជះ　ដែលខ្ញុំសំពះថ្វាយបង្គំ
សូមកំចាត់បង់សត្រូវធំ　អន្តរាយក៏កុំកើតមាន ។

ឳ. ជួនជូនចប់នមស្សការ    ប្រាំពីរអក្ខរដើមទិទាន

តទៅថ្លែងរឿងព្រះទ្រង់ញាណ    តាមបែបលំអានពុទ្ធប្រវត្តិ ។

### ថ្លែងរឿងពុទ្ធប្រវត្តិកាលព្រះអង្គចុះចាកភពតុសិត

អ. ថ្លែងកាលអង្គព្រះទ្រង់ជោគ    អន្ទោលទៅមកក្នុងលោកា
អញ្ជើញចុះចាកស្ថានតុសិតា    ហើយចូលកាន់មហាឧរេត្ន ។
នៃនាងមាយាជាមហេសី    សុទ្ធោទន៍ធិបតីបរមក្សត្រិយ៍
ជាស្តេចទ្រង់សោយរាជសម្បត្តិ    ក្នុងបុរីរដ្ឋកបិលពស្តុ ។
អា. កាលស្តេចគាប់គាន់បារមី    ប្រសូតចាកផ្ទៃតាមចន្លោះ
ចំឡែកជាងសព្វសត្វទាំងអស់    ហាក់ដូចទ្រង់ចុះចាកសយនា ។
ឥ. ទាំងព្រះឥន្ទ្រឥតអត់បាន    ចុះចាកសួគ៌ស្ថានមកម្នីម្នា
ព្រមទាំងពពួកទេពកញ្ញា    មកជួយរក្សាមហាបុរស ។
ឦ. អង្គព្រះពង្សពោធិសត្វ    ទ្រង់សោយសម្បត្តិកបិលពស្តុ
ជាមួយពិម្ពាស្រីល្អស្រស់    ព្រះទ័យស្មើស្មោះឥតទោសា ។
ឧ. ក្សត្រិយ៍ឧត្តមបរមនាថ    ជាសក្យជាតិដ៏ថ្លៃថ្លា
ព្រះជន្មបាន ២៩ វស្សា    យាងទតព្រឹក្សាច្បារមង្គល ។
ឩ. ទ្រង់ទតឃើញរូបជរា    នឹងមនុស្សព្យាធាឈឺទុព្វល
មនុស្សស្លាប់បព្វជិតសក្តិសិទ្ធសល់    ដែលទេពពន្យល់ដល់ក្សត្រា ។

ឬ.រំងរែងរំតគិតសង្វេគ ព្រះទ័យបែរបែកបាកកាមា
ទឹកភ្នែកបង់លះបោលវង្វា ចេញសារឧបត្ថម្ភបំពេញព្រឹត្តិ ។

ឬ្ក.រួបរួសកន់បន្ទាន់ណាស់ យាងចូលហ៍សកាន់រាំងស្នូខ
ដល់ហើយទ្រង់ផ្ទុំពីងគិត ដកបដល់ដិតអគ្គាត្រស្វាត់ ។

៣. លាន់រាចាហាហៅឆន្ន អនាគតណាន់ឲ្យឡើងប្ញាត់
បង្គាប់ឲ្យរៀបគ្រឿងសេះរត្ន ទ្រង់ទឹងលះកាត់ចេញបព្វជ្ជា ។

៣្ក.លុះរៀបស្រេចស្តេចឡើងគង់ សេះស្នះចេញស្នូងចាកតាក
ពេលនោះដឹងដល់ព្រះឥន្ទ្រា ចុះចាកសួគ៌ាមកងាប់ក្រែ ។

១.អស់ពពួកទេពនិកាយ នាំគ្នាប្រញាប់ហោះប្រៀវប្រែ
ខ្វះកាន់ភ្ញីផ្កាកាន់ទង់ជ័យ ថ្លយហែកក្រិតប៉ៃថ្ងមីត្រៀបត្រា ។

៣.ច្រើនតាន់តាប់ពេញអាកាស ហោះម៉េដេរដាសពាសសរមយា
ព្រមទាំងមហាព្រហ្មឈ្មោះឃដិការ ក៏កាន់បរិក្ខារចុះមកថ្វាយ ។

៦.លុះដល់ស្ទឹងអនោមា មានទឹកគេថ្លាគ្គាសប្បាយ
ជាទីព្រៃព្រឹក្សាទឹកឆ្ងាយ ទើបស្តេចទ្រង់ផាយចុះមកឃ្មុំ ។

៦. ស្រេចទើបស្តេចត្រាស់ហៅឆន្ន ឲ្យលាមកកាន់កាដបុរី
ជាមួយកណ្ឋស្សអាជានេយ្យ ដំណាលសេចក្តីទូលបិតា ។

៦ុ. ព្រះបរមទ្រង់ព្រះខ័ន ប្រុងកាន់កៀនកាត់ព្រះកេសា
លុះកាត់រួចស្រេចហើយតាពេល ហើយទ្រង់បព្វជ្ជាបួសជាស្រមណ៍ ។

អំ. ទ្រង់អំណរត្រេកអរពេក　　ក្នុងភេទបព្វជិតយ៉ាងរម្យទំ
ទើបទ្រង់ឧហាតសង្វាតខំ　　ប្រព្រឹត្តយ៉ាងសមនឹងព្រហ្មចារ្យ ។
អាំ. អាចព្យាយាមយ៉ាងតឹងរ៉ឹង　　សង្វាតឃ្លាតប្រឹងខំឧស្សាហ៍
ទ្រង់ផ្ដើមធ្វើទុក្ករកិរិយា　　ប្រាំមួយវស្សាទើបសម្រេច ។
អះ. ត្រាស់ក្រោមម្លប់ពោធិព្រឹក្ស　　ស្មារតីទ្រង់នឹករំពឹងកិច្ច
កប់ខ្យល់ចេញ-ចូលមិនមានដាច់　　ទាល់បានសម្រេចពោធិញ្ញាណ ។

ថ្លែងរឿងពុទ្ធប្រវត្តិតាមលំដាប់អក្សរ "នមោ" ពីត្រឹមប្រសូតរហូតបានត្រាស់ ។

ចប់តែប៉ុណ្ណេះ

ថ្លែងរឿងពុទ្ធប្រវត្តិពីត្រឹមបានត្រាស់
ដល់ចូលនិព្វានតាមលំដាប់អក្សរ "ក ១"

វគ្គទី ១

ក. ថ្ងៃនាលអង្គព្រះគោតម　　ទ្រង់ផ្ចាញ់ស្ដេចមារចិត្តសាម៉ាវ
លើកពលយោធាប្រឹនសែនលាន　　ចិត្តទ្រង់ស្ថិតក្លាហានបូលតតាំង ។
ខ. ខំខ្វល់ខ្វាយប្រញាយញាក់　　លាន់ឮសន្ធឹកពន្ធឹកខ្លាំង
ពលខ្លះកាន់ដាវខ្មៅចិត្តខ្លាំង　　ខ្ចីឃ្លាតចូលច្បាំងតាំងប្រឡង ។
គ. ខ្លះគ្រឹកគ្រឹកពន្ទឹកពេក　　សូរសព្ទសំរែកឮគឹកកង
ពលខ្លះហោះខ្ទាំងលីដំបង　　ស្ទុះចូលប៉ុនប៉ងនឹងពាធា ។

ឃ. ឃើញព្រះអង្គគង់ឯកឯង    ឥតមានកោតក្រែងដល់ក្រុងមារ
ទ្រង់អាងបារមី ១០ ប្រការ    ជាពលបរិវារជួយជ្រោមជ្រែង ។
ង. ងោងងឹតអន្ធការ    ភាសពេញមេឃាអ័ព្ទបែកផ្សែង
តែទ្រង់អង់អាចឥតស្ញប់ស្ញែង    ស្តេចមារក៏ក្រែងខ្លាចបារមី ។

វគ្គទី ២

ច. ពាលចុះចាញ់បុណ្យស្តេច    ក្រួញក្រាបវន្ទាដោយសិរសី
ពលមារក៏បបខ្ចប់ខ្លាចជ័យ    បាក់ទ័ពបរាជ័យរត់ខ្ចាយខ្ចាត់ ។
ឆ. តពីនោះព្រះទ្រង់ញាណ    ត្រាស់ដឹងនិព្វានស្ថានស្ងប់ស្ងាត់
កិលេសតណ្ហាទ្រង់កាប់កាត់    កំចាយកំចាត់ចាកសន្តាន ។
ជ. ជួយសង្គ្រោះសត្តនិករ    ទ្រង់សំដែងធម៌ប្រោសសព្វស្ថាន
ប្រឹតប្រៀនប្រដៅតាមលំអាន    ដឹកនាំឲ្យបានស្ថានសុខា ។
ឈ. ឈានចាប់ដើមពីសហម្បតី    ព្រហ្មាធិបតីលើសលោកា
ចុះមកបង្គំអារាធនា    ឲ្យត្រាស់ទេសនាប្រដៅសត្វ ។
ញ. ព្រះទ្រង់ញាណមានមេត្តា    ទទួលពាក្យមហាព្រហ្មថ្វាត់
រួចទ្រង់យាត្រាត្រេចយាងកាត់    ទៅកាន់ព្រៃស្ងាត់ឈ្មោះមិគទាយ៍ ។

វគ្គទី ៣

ដ. ទ្រង់ដាស់តឿនពួកឥសី    គឺបញ្ចវគ្គិយ ៥អង្គ
ឲ្យប្រុងចាំស្តាប់ព្រះធម្ម    ទ្រង់នឹងទេសនាព្រះធម្មចក្រ ។

ឋ. គឺព្រះធម៌ជាបឋម ដូចកង់ចក្រធំយ៉ាងឯកអគ្គ
ជាធម៌ប្រព្រឹត្តទៅតាមថ្នាក់ ប្រកាសសច្ចៈ ៤ ប្រការ ។
ឌ. ក្នុងមណ្ឌលសាសនៈវង្ស ជាធម៌ត្រង់ត្រចះថ្លា
ជាទីលះបង់នូវទុក្ខា ជាផ្លូវយាត្រាទៅនិព្វាន ។
ឍ. ឲ្យវិញ្ញូនាការបេះដឹង ដុសខាត់សំរឹងប្រាជ្ញាញាណ
ដុតបង់កិលេសដោយអគ្គិឈាន ចូលកាន់និព្វានស្ថានស្ងប់ស្ងាត់ ។
ណ. លុះចប់ធម៌ស្រេចកាលណា មនុស្សនឹងទេព្ដាច្រើនពេកក្ដាត់
បានលុះមគ្គផលដល់អរហត្ត ត្រាស់ដឹងបរមត្ថធម៌ជ្រៅល្អិត ។

## វគ្គទី ៤

ក. តាំងពីនោះព្រះសាស្ដា តែងទំទេសនាច្រើនពេកពិត
ប្រឹតប្រៀនប្រោសសត្វឲ្យប្រព្រឹត្ត តាមដោយកំរិតពាក្យបណ្ដាំ ។
ខ. ព្រះលោកនាថជាតិសព្វជ្ញ បំពេញពុទ្ធកិច្ចគ្រប់ទាំង ៥
ប្រឹងប្រែងប្រោសសត្វអស់ច្រើនឆ្នាំ គ្រប់ ៤៥ ព្រះវស្សា ។
គ. ទើបទ្រង់យាងកាត់ដំរង់ ទៅកាន់ទីក្រុងកុសិនារា
ទ្រង់ផ្ទុំលើថ្មទ្រនសិលា នៃមល្លក្សត្រាក្រោមរាំងភ្នំ ។
ឃ. ទ្រង់ប្រឈួនធ្ងន់ក្នុងកាយ សាវកទាំងឡាយតោមជិតជុំ
សោកាអាល័យព្រះបរមេ ក្សត្រក្សត្រអ្នកនំកុងឃរ ។

២. ព្រះអានន្ទអនុជថ្លៃ    សរសើរសៅរ៉ៃក្រៃខ្លាចផុត
យំត្អូញរៀបរាប់គុណអស្ចារ្យ    ស្តាយព្រះសាស្តាជាម្ចាស់ថ្លៃ ។

វគ្គទី ៥

៣. ព្រោះធ្លាប់បានស្តាប់ទេសនា    នៃព្រះគតរាកលយប់ថ្ងៃ
ឥឡូវបែរប្រាសព្រះបរមត្រៃ    ទ្រង់កាត់អាល័យចូលនិព្វាន
៤. ផុតវែងបានគប់ព្រះអង្គ    ព្រោះទ្រង់លះបង់ឧបាទាន
ព្រះទ័យផូរផង់ផ្ទង់ព្រះញាណ    យាងចូលនិព្វានថ្ងៃនេះហើយ ។
៥. ព្រះទសពលយល់អានន្ទ    យំសោកអួលអន់ឥតមានស្បើយ
ទើបទ្រង់ត្រាស់ថាអានន្ទអើយ    ប្អូនបោះស្បើយពាក្យទុក្ខា ។
៦. ព្រោះកុងភពគ្រប់មនុស្សសត្វ    តែងមានវិបត្តិជាធម្មតា
សេចក្តីព្រាត់ប្រាសសត្វសង្ខារ    នេះជាធម្មតាកុងលោកិយ ។
៧. មានតែស្ថាននិព្វានមួយ    ទើបផុតទុក្ខព្រួយបាបអប្រិយ
ប្អូនបាប្រឹងប្រែងប្រុងស្មារតី    គាំងខ្ជាប់កុំបីភ្លេសគំនិត ។

សេសវគ្គ

៨. ចូរអ្នកយកធម៌ជាយាន    ជាគ្រឿងនាំនប្រសើរចិត្ត
គឺជាគតនេះនិព្វានពិត    តាមដោយកំរិតសង្ខេប ។

រ. រីព្រះធម៌ល្អបរិសុទ្ធ ដែលតថាគតបានទេសនា
បានថ្លែងសំដែងច្រើនឧទ្ធារ នេះជាសាស្ដារ្កកល់ប្រាណ ។
ល. លុះអំណើះទៅថ្ងៃក្រោយ ចូរអ្នកកុំធ្លោយក្នុងសន្តាន
នាំគ្នាប្រតិបត្តិតាមលំអាន ធ្វើខ្លួនឲ្យក្សាន្តចាកទុក្ខា ។
វ. ព្រះភគវ៉ាជាលោកនាថ ទ្រង់ឲ្យឱវាទច្រើនប្រការ
ប្រកាសផ្ដាំផ្ញើព្រះសាសនា ទុកជាសាស្ដាស្នងព្រះអង្គ ។
ស. គ្រាន់សង្គ្រោះដល់មនុស្សសត្វ ជាផ្លូវប្រតិបត្តិដ៏ត្រូវត្រង់
ជាគ្រឿងធ្វើចិត្តឲ្យផូរផង់ ដើម្បីលះបង់កតណ្ហា ។
ហ. ព្រះអរហំជាបរមគត ត្រាស់ផ្ដាំសព្វគ្រប់ស្រេចកាលណា
ទើបទ្រង់បញ្ឈប់ព្រះវាចា ផ្ចង់ព្រះចិន្ដាចាកអារម្មណ៍ ។
ឡ. លុះវេលាទៀបនឹងព្រឹក សូរសព្ទសន្ធឹកសត្វយាសយំ
នឹងសព្ទទំនួញទួញយោបំ ទូគិមគួរឲ្យព្រឺពេមា ។
អំ. ព្រះអរហំតាំងព្រះញាណ បំពោះអង្គឈានបានអប្បនា
រួចចូលនិរោធស្ងប់សង្ខារ យាងចូលកាន់មហានិព្វានហោង ។

ចប់តែប៉ុណ្ណេះ

សរសេរ មាស-យុត្ត

កូនសិស្សសាលាបាឡីជាន់ខ្ពស់ថ្នាក់ទី ១

# ប្រជុំពាក្យកាព្យ

## ភាគទី ៣

## ជារបស់ផ្សេងរោហារគ្នា

(តទី ៥)

# ពាក្យនាំ

ខ្ញុំប្រារព្ធឃើញថាពាក្យកាព្យបុរាណពួកដែលតែងយ៉ាងជា គួរគប្បីរក្សាសំនួនទុក ខ្ញុំមានបំណងនឹងបោះពុម្ពមកជាយូរហើយ ដូចបានពណ៌នាក្នុងពាក្យនាំប្រជុំពាក្យកាព្យភាគទី ១ មករួចហើយ ។

អំពីពាក្យកាព្យរបស់ស្តេចទាំងប៉ុន្មានព្រះអង្គ សឹងខ្ញុំនាំមកបោះពុម្ពក្នុងទីប្រជុំពាក្យកាព្យទី ២ នេះដោយយល់ឃើញថា ត្រូវទុកសំនួនឲ្យពួកខ្មែរជាន់ក្រោយដឹងថា ស្តេចខ្មែរ មានស្តេចដែលចេះតែងរឿងតែងកាព្យនោះខ្លះដែរ មិនមែនដូចពាក្យមនុស្សខ្លះនិយាយថា ស្តេចខ្មែរ មិនដែលតែងរឿងអ្វីសោះ ថាស្តេចខ្មែររើសយកតែរបស់ក្រស្ត ថាមកជារបស់ខ្លួនធ្វើ ។

អំពីក្សត្រិយ៍ខ្មែរបុរាណជាមានព្រះប្រីជាដូចម្តេចខ្លះ ខ្ញុំមិនហ៊ានអាងអួតជាប្រាកដ តែជាន់ក្រោយត្រឹមព្រះបរមរាជាព្រះជៃយចេស្តា មកដល់កាលឥឡូវនេះខ្ញុំដឹងច្បាស់ថា ព្រះជៃយចេស្តាទ្រង់តែងច្បាប់សំរាប់ព្រះនគរដូចមានព្រះកេរ្តិ៍ទុកដល់សព្វថ្ងៃនេះ ។

ព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសម្ភារ, (ចៅពញាតូ) ជាស្តេចប្រាជ្ញខាងសាស្ត្របាឡី-កាព្យឃ្លោង ។

ព្រះបាទសម្តេចព្រះនារាយណ៍រាជា (ព្រះអង្គតន់) ក៏ជាប្រាជ្ញខាងពាក្យកាព្យឃ្លោង ខ្ញុំរាជការប្រុសស្រីក៏ចេះកាព្យឃ្លោងជាច្រើន ។

ព្រះបាទសម្តេចព្រះហរិរក្សរាមាក៏ជាស្តេចប្រាជ្ញខាងតែងរឿងដូចមានរឿងទុកមកដល់កាលឥឡូវនេះ ។

ពួកព្រះរាជបុត្រព្រះបាទសម្តេចព្រះនរោត្តម ក៏មានស្តេចចេះតែងពាក្យកាព្យជាច្រើន, ស្តេចព្រះរាជបុត្រជាន់តូច ៗ មានព្រះអង្គកេតសរា (កេសរា) ១ ព្រះអង្គក្រៃសរស្សរីវង្ស ១ ជាស្តេចប្រាជ្ញខាងតែងកាព្យ ។

១ ឱសំឡាញ់អញពេកដេកមិនលក់
សែនជាទុក្ខមុខជាទៀបហៀបមរណា
ក្រាំពេកទឹកលេងហូរនេត្រា
សូមទេពជួយជីវិតគិតប្រណី ។
ធ្វើម្តេចគេលួចបានព្រាណថ្លៃរមិត្រ
មាសមកផ្តិតមិត្រមកផ្តួលមូលមេត្រី
ពោះគេកាប់ស្លាប់បង់ទៅសូវបានស្រី
ប្តូរជីវិតផ្តាច់ជីក៏មិនស្តាយឡើយ ។

ព្រះរាជនិពន្ធ ព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមាព្រះអង្គ (ដួង) ជាសេចក្តីយ៉ាងនេះ ឲ្យទៅនាងកេនឡុង ។

៙ សាពទុសារផ្ញើផ្កាអ្នក
ពេញស្ម័គ្រស្មោះស្មើត្រួយទ័យា
ដូចដួងនៃនេត្រទាំងទ្វីហា
វនិតាកុំរេពសន្ធិះគិត
អាសូរកុំឲ្យរៀមវិយោគ
សែនសោយសោករកគូមិត្រ
ផ្ដុំក្រៀមត្រៀមអង្គផ្សិតរមិត្រ
មិនជិតជួបចូលមូលទ័យា

៙ សែនស្ដាយកាយកាលឃើញគោមយន៍
មិនគួរលះបង់ឲ្យឯកា
ទ្រូងទ្រាំផ្សាជាំពល់វេលា
គ្មានស្រាន្តចិន្តាមួម៉ងសៅ

៙ ពីកាលដែលប្អូនចូលទៅបាត់
សែនស្វាត់ស្រមៃហាក់ថ្ងៃហៅ
បែរកក្រមើលផុតមិនឃើញហៅ
ទ្រះក្ដៅឧកក្ដួលរំជួលអង្គ ៗ

៙ នានាគេដឹងអស់សាយសព្វ
អារម្មណ៍ថ្មីគ្រប់ណាគោមយន៍

អញ្ជើញអណ្ដុជាកុំរង់
មកគន់ឥតឯបង់សោះអាល័យ ។
⊙ បើអ្នកមិនប្រោសព្រមប្រតិព័ទ្ធ
ពោលសត្វឲ្យលង់នកាល័យ
រៀមរ៉ែកសូមស្លាប់នឹងអ្នកថ្ងៃ
មិនប្រែដោះដៃកុំសង្ក ។
⊙ ពាក្យដែលប្រាយប្រាប់ស្រីវល័ក្សណ៍
ដៀងជាក់ពិតពុំមានមុសា
ជាអ៊ីខន្ដីដូចកាថា
កន្សាអាណិតចិត្តខ្វះអើយ ។
⊙ កាខ្នងថាបងអ្នកជ្រើមក
ចូរគិតរិះរកកុំស្ងៀមនៅ
អាសូរដេជ្ជាដែលម៉ងសៅ
កុំទៅជាម្ដេចណាថ្ងៃអើយ ។

ព្រះអង្គម្ចាស់យុគន្ធរ

⊙ អនិច្ចាចិត្តអើយសែនចំបែង
ថ្វាថ្ងៃក្រាបទូលព្រះឆោមស្និទ្ធ
គ្រានេះប្រថុយជន្មជីវិត

មិនគិតក្រែងមនុស្សគេនិន្ទា ។

◎ បើមិនយល់ជាព្រះទ័យស្នេហ៍

ប្អូនមិនគិតគ្នេរជ្រើកាយោ

ព្រោះជឿហរិវង្សទ្រង់មេត្តា

បានជាកនិដ្ឋាប្រថុយប្រាណ ។

◎ បើទ្រង់បានជ្រាបសព្ទអក្សរ

សូមលាយព្រះករតបប្រទាន

ឲ្យបានអណ្ដុដដ៏ងដើមដាន

ដោយពិតពណ៌ដ៏មានពីព្រះទ័យ ។

ស្ដេចក្សត្រី ល. អ. ខ.

◎ នេះសារពសូរិវង្សពង្សត្រៃប័ក្រ

ទ្រង់បានស្ដាប់សព្ទពចាស្រីណុគ្គលក្សណ៍

គិតព្រួកទឹករលែកហេតុស្មោះស្ម័គ្រ

ទុកអាក់កក្រក្ដួលអួលទ័យា ។

◎ សែនមានោទោម្នេញពេញតាំងប្រាណ

ព្រោះយោ"មា"ណាទៅរង្វៀសក្ដិក្ខា

ហាក់ដូចរៀមគ្មានសុចរិតពិតសត្យា

ទុកាលណាទើបឃើញត្រង់ដូចអង្គបង ។

៙ គិតសព្វថ្ងៃក្រែងគិតរឿងមិត្រមូល
បុណ្យមិនបានជួបពិតចូលមូលដូចប៉ង
គ្រានេះបូរអ្នកត្រិះរិះការមើលលង
ដ្បិតបំណាងទាន់គ្រាក្រក្រំចលៅ
៙ កុំសង្ស័យថ្ងៃទិម្ពលមង្គលសក៏ត
រៀមមិនឃ្លាតឃ្លាមេត្រីស្រីឆោមឆ្ងៅ
លុះគ្រាក្ស័យប្រល័យជីពទើបឃាតទៅ
កុំសោកសៅក្ដៅចរណា ណុជអើយ ។

ព្រះអង្គម្ចាស់ក្សត្រា យុគន្ធរ
តបព្រះអង្គម្ចាស់ក្សត្រី ល. អ. ន.

ពាក្យកាព្យនេះមើលចាំមាត់មកជាអង្វែងឆ្នាំហើយ នាំយកមកបោះពុម្ព ដើម្បីរក្សាសំនួនទុក ។

ព្រះអង្គណាជាម្ចាស់របស់ ឃើញថាមានសេចក្ដីលើសលស់ខុសដូចម្ដេច សូមអភ័យដល់ខ្ញុំផងចុះ ។

៙ គឺអំបុតកើតអំពីដល់វៀត
បៀតតែក្ដិតដ្បិតតែខ្លួនប្រក្លួនមាណ់
មិនជាតខ្វង់មិនចង់ឃ្លាតពីចរន
ស្នូតប្រាកានស្នានប្រកបតែប្របអឹង ។

៙ រពុកនង់លង់នេត្រផ្កាសង្កែន
សុតស្រយែនសែនស្រយាកតាកលំបឹង
លំបិតតាកលំបាកចាំតាំតែតឹង
ខេចដូចម្ដឹងខឹងដូចម្ដាមិនបាថាន ។

ព្រះអង្គម្ចាស់ក្រៃសរត្សូរវង្ស

៙ លុះបានឃើញលាយការទអូនដល់
បងអរសែនសល់គ្មានអ្វីស្មើ
ទទួលមើលសព្វគ្រប់ដំណើរ
ជាអូនកែវផ្ញើជីវិតផង ។

៙ ព្រលឹងអើយសូមត្រួយកុំព្រួយចិត្ត
រៀមនឹងស្នេហ៍ស្និទ្ធពិតជាម្ដង
នឹងថ្នមឲ្យផុតស្ត្រីផង
ទួនល្អជាឯកប្រយូរវង្ស ។

៙ បើប្អូនមេត្តាឥកពិត
ជីវិតសូមផ្ញើលើតោមយង់
ខុសគាប់ម្ដេចម្ដាចូរកិសវង់
មេត្តាឲ្យគង់ជាមេត្រី ។

រ. ណ. រ.

◎ អង្គអញជាតិជាក់ជាត្រកូល
កំពស់កំពូលកម្ពុជា
បុត្រព្រះហរិរក្សរាជពមា
ស្តេចជាឥស្សូរអស់ក្រស្ដផង ។
◎ ព្រះរៀមនៃអញព្រះបមកព
ស្តេចគ្រប់គ្រងក្រុងឡើងជាថ្មី
នាមនរោត្តមបក្រី
ស្តេចនាំសារស្រីទឹងសេនា ។
មកគង់នៅកំងចតុមុខ
ភូមិស្រុកក្នុំពេញរដ្ឋសីមា
ជាសុខនិរភ័យឥតទុក្ខា
ដោយតេជក្សត្រាទ្រើសទ្រង់បុទ្ធី ។

ពាក្យកាព្យបទនេះ ព្រះអង្គម្ចាស់ច័ន្ទវង្សទ្រង់ព្រះនិពន្ធជាពាក្យនាំកុងរឿងដេតពនចាំបានតែប៉ុណ្ណេះ ។

សិននាំយកមកបោះពុម្ព ដើម្បីរក្សាសំទួនទុក ។

ម៉ោងប្រាំបួនជូនរពួកទឹកទៅដល់
ទុសមមិត្រស្និតៈនៅស្ថានបានសុខស្កល់
ប្អំពល់ខ្វល់អំពីនិពសគ្នា

ឬជាលក់ស្កលើទៅហើយស្បើយចិត្តទឹក ។

៙ រីរពុកទឹកលែកខបេក្ខា

គិតសង្ស័យម៉ែថាខ្ញុំពុំមេត្តា

ចិត្តអាល័យរើងម៉ែមមាញឹក

គិតពុកទឹកមិនភ្លេចរាល់វេលា ៗ

ពាក្យកាព្យបទនេះជាបានដារបស់

ឧកញ៉ាសុន្ទរាភិហារ (ម៉ុក)

៙ ក្នុងសារថាព្រះចមម្កុដកត

ព្រះនាមទេព្វរ័តនប្រក័តសរ

សូមចង់មេត្រីស្រីបវរ

បើមេត្តាបងអរដល់អស់ផន្ទ ៗ

៙ សព្វថ្ងៃក្រពង់ប្រំរុងលោក

សែនវិយោគសោយសោកទុក្ខពេកពន់

តាំងតែពីស្នេហ៍ដួងសោវគន្ធ

មិនដែលហៅអន់ចិត្តត្រង់ណា ៗ

៙ បើមិនដឹងការថ្នបថ្ងៃនេះ

សមគួរប្រេះព្រោះកន្សា

មរណាំភ្លេចទាំងធ្វើភផការ

កស្ត្រីនរណា ៗ តែខ្ញុំ ៗ
៙ ព្រះអណ្ដុដលុឃុនមេសាលា
ទ្រង់តែងសាកតាមព្រះទ័យ
សូមជួមឃូអែវកែប្រែពៃ
អាណិតក្រៃថ្ងៃណាថ្ងើមអើយ ៗះ៚—

ព្រះអង្គម្ចាស់នពរ័ត្ន

ក្នុងពាក្យកាព្យនេះតាំងអង្គជាចមមកុដកពហើយថាជាបំរុងលោក ៗ ពាក្យនេះមើលចាំមាត់មកយូរផ្លែងឆ្នាំមកហើយ បើអ្នកឯណាមើលឃើញនឹងជាឃ្លាតខុសពីពាក្យដើម សុំអភ័យដល់ខ្ញុំផង សុំកុំឲ្យត្មះតិះដៀលឡើយ ៗ

៙ សាកសារៀមសូមសួរចិត្ត
ឲ្យអ្នកអាណិតពីចិន្តា
និយាយផ្ដាច់សំរេចការ
ជានឹងស្នេហារៀមឬទេ ៗ
៙ ឬមួយសូមចិត្តជ្រៀតបងក្រ
រូបមិនសូវល្អដូចអស់គេ
បានជាមាសមិត្រម៉ឺនស្ងួនស្នេហ៍
ច្រាប់បងឲ្យថៃសោះថប់ពេក ៗ

៙ រៀមរកតាំងចិត្តមិត្រមេត្រី
ព្រោះតែអ្នកថ្លៃទ្រូងស្មើរបែក
អាល័យរឭកនឹកពន់ពេក
រលង់ទឹកភ្នែកកល់កត្រី ។
៙ ទ្រូងជាំក្រំចិត្តបែកពីរបី
ដោយចិត្តស្រឡាញ់ជាប់និស្ស័យ
បងទ្រាំព្រួយចិត្តមកយូរថ្ងៃ
ចាំស្តាប់សេចក្តីវិល័យល័ក្ខណ៍ ។

## មិនស្គាល់ឈ្មោះ

៙ ទឹងថ្ងៃងវិតក្កុកកន្ទប្រាណ
ទូរសេឆ្ងាយស្ពានឲ្យតែព្រួយ
សព្វថ្ងៃកុំរ៉ៃទឹងថ្ងៃមួយ
សែនព្រួយទ្រូងទ្រាំក្រំស្មើរបែក ។
៙ ពេលដើរក៏ដើរតាំងវេទនា
ពេលទឹងនិទ្រាគិតវិវេក
ពេលសោកទ្រាំស៊ុំទាំងទឹកភ្នែក
ពេលត្រែកសើចលេងតាំងខ្លាចផ្សា ។
៙ ប្រះខ្លួនដេកទៅនៅផ្ញឹង

រំពៃរំពឹងលើស័យនា
ក្រំក្រៀមឈឹងស្ងៀមពុំបរោ
ទុក្ខអើយៗបយាប្រៀបពុំបាន ។
៙ វៀរតែដេកលក់បាត់ស្មារតី
ភ្លេចថ្ងៃដោយសារបាត់វិញ្ញាណ
បើដឹងស្មារតីឡើងថ្ងាម៉ោណ
រំខានទឹកថ្ងៃទាំងប៉ុណ្ណោះ ។

នាយទុំទឹមក្រុមហាត់ឡើក

៙ ឱសែនស្រណោះចម្ប៉ាខែក
ក្លិនជាប់ចម្លែកជាងអស់ផ្កា
ប្រសិនបានមកសៀតកាលណា
សមក្លិនចម្ប៉ាប៉ូលជាប់ប្រាណ ។
៙ កម្មអើយដើមផ្កាក៏ឆ្ងាយសល់
ទស្សនាមិនយល់ពេញរំខាន
ធ្វើម្តេចនឹងទៅថ្នមផ្កាបាន
ផ្កានៅក្នុងស្ថានគេក្រា ។
៙ ខ្វល់អើយសែនខ្វល់អំពល់គិត
ព្រោះបាននែបជិតដួងបុប្ផា

ទ្រូងក្រំផ្សាផាំពល់វេលា
ក្នុងទ្រូងអួលផ្សាមិនមានក្សាន្ត ៗ
ឱ ប្រសិនផ្កានេះជាកុសល
នៅក្នុងមណ្ឌលឆ្ងាយប៉ុន្មាន
សូមទេពអមរិន្ទ្រឥន្ទ្រសួគ៌ស្ថាន
ជួយខ្ញុំឲ្យបានផ្កាសៀតអើយ ៗ

មិនស្គាល់ឈ្មោះ

វេយ្យាករណ៍

# របស់អាចារ្យ ហឹម

( តចប់ )

## ៤៦ សង្វេគ

សង្វេគ មានសង្វេគនៅក្នុងកងសង្ខារឲ្យឃើញច្បាស់ថា សង្ខារប្រកបដោយត្រៃលក្ខណ៍ដូចបានពណ៌នារួចមកហើយ គប្បីរំឭកនូវវ័យឲ្យឃើញប្រាកដថា វ័យរបស់យើងអស់៤ទៅហើយនៅតែ ១ទេ ១នេះសោតដឹងជាស្មើដោយភាគដើមឬមិនស្មើ ព្រោះធ្លាប់ឃើញបុគ្គលដទៃដែលមានដំណើរដើរទៅមុនៗនោះខ្លះទៅក្នុងបឋមវ័យ ខ្លះទៅក្នុងមជ្ឈិម-វ័យ ខ្លះចូលក្នុងបច្ឆិមវ័យដែរ ប៉ុន្តែគ្រាន់តែចូលមិនគ្រប់ភាគដើមក៏មានច្រើនណាស់ បុគ្គលដែលដល់កំណត់អាយុក្ស័យឬលើសបន្តិចបន្តួចនោះមានតិចណាស់ បុគ្គលដទៃក៏ដូចខ្លួនយើងៗក៏ដូចបុគ្គលដទៃដែរ មិនកន្លងឡើយ ឥឡូវនេះខ្លួនយើងនៅក្នុងវ័យខាងចុងបំផុតហើយ ប្រៀបទីដំណើរព្រះអាទិត្យថា រសៀលទាបប្រព្រះទៀបនឹងអស្តង្គតលិចហើយ ពុំនោះសោតខ្លួនយើងជាអ្នកអង្គុយបេប្រហោងក្បែរប្រឆានមាត់នៃមច្ចុរាជ ឬដូចសត្វកង្កែបប្រហោងនៅទៀបមាត់ច្រាំង ងាយណាស់នឹងលោតចុះទៅក្នុងទឹក នឹងប្រហែសធ្វេសមិនបានឡើយ ។

## ៤៧ តេ សុចរិតា

តេ សុចរិតា សេចក្តីប្រព្រឹត្តសុចរិត ៣ ប្រការនោះគឺ កាយសុចរិតមានប្រភេទ ៣ វចីសុចរិតមានប្រភេទ ៤ មនោសុចរិតមានប្រភេទ ៣

ដែលជា សុចរិត ៣ ប្រការដូច្នេះ តែបើរួបរួមទៅជាសុចរិត ១០ ប្រការឬ កុសលកម្មបថ ១០ នោះដដែល កុសលកម្មបថមិនបាច់ដំណាលទៀតទេ ព្រោះបានសំដែងក្នុងទេព្យប្រសើរឯនោះរួចហើយ ខ្ញុនយើងចាស់ហើយ ប្រុងប្រយ័ត្នកុំឲ្យមានអំពើទុច្ចរិតឲ្យសោះ ខំខ្វល់ខ្វាយតែក្នុងអំពើសុចរិតឲ្យ បានល្អគ្រប់ផ្លូវកុំបីធ្វេសប្រហែសឡើយ ។

## ៤៨ សង្វេគកថា

សរីរកាយរបស់យើងនេះប្រជុំព្រមដោយអាការ ៣២ ប្រការ ពេញពាសដោយសាកអសុភ មិនមែនជាទេវតានិម្មិត មិនមែនជាព្រហ្មនិម្មិត មិនមែនហើយដោយមាស មិនមែនហើយដោយកែវ · មិនមែនហើយដោយខ្ទឹមបន្ទូរក្រហម មិនមែនកើតក្នុងផ្ទៃនៃផ្កាឈូកសឈូកក្រហមនិងផ្កាព្រលឹតទាំងឡាយ ពោរពេញទៅដោយមូត្រលាមកស្មោកគ្រោក អា-ក្រក់មិនមែនជាទឹកអម្រឹត ម្យ៉ាងទៀត កំណើតដែលកើតអាស្រ័យមាតាបិតាជាកំណើតកើតក្នុងអសុភ មានកិរិយាប្រែប្រួលលុបលាងគក់ច្របាច់ បែកធ្លាយទីងខ្ចាត់ខ្ចាយជាធម្មតា បំរើនជ័យងំទះកើតឡើងពីតណ្ហា មានសេចក្តីសោកខ្សឹកខ្សួលជាវត្ថុ ជាលំនៅនៃរោគទាំងពួង ជាទីនៅរបស់ត្រ-កូលនៃសត្វដង្កូវទាំងឡាយ កាន់យកនូវកម្មករណ៍ជាប្រក្រតី ខាងក្នុងស្អុយតែងហូរចេញមកខាងក្រៅជានិច្ច សរីរកាយនេះមានប្រក្រតីបម្រះទ-

ទៀត ក្នុងគន្លងចក្ខុនៃសត្វលោក ប្រព្រឹត្តទៅកាន់ទីប៉ាឆាគឺសេចក្តីស្លាប់ ជាទីបំផុត សរីរកាយនេះប្រកបដោយធ្អឹងសរសៃ បូកប៉ាន់ទៅដោយសាច់ ហើយនិងស្បែកគ្របដណ្តប់ ខាងក្នុងពេញទៅដោយពោះវៀនតូចពោះវៀនធំ ថ្លើមសួតបេះដូងក្រពះប្លោកនោមទឹកសម្បុរទឹកញើសទឹកប្រមាត់ ខ្លាញ់ពកជាដើម សរីរកាយនេះមានក្លិនអសោចិ៍ស្អុយឆ្អេះឆ្អាបអាក្រក់ វត្ថុទាំងនេះប្រសិនបើបារកកាយយកចេញមកខាងក្រៅដាក់ដោយដុំៗ ក្រែងតែកាន់ដំបងព្រនង់ដេញបក្សីក្អែកទីងត្មាតទើបបាន បើដល់អស់អាយុទៅ ដួលដេកស្តូកស្តឹងលើផែនដី តែហួសខួបទៅហើយ ហើមប៉ោងឡើងមានពណ៌ខៀវអសុភអសោចិ៍តែងហូរចេញតាមទ្វារទាំង៩ ញាតិសាច់សាលោហិតរមែង [illegible] យកទៅបោះបង់ចោលក្នុងព្រៃស្មសាន ឥតមានអាឡោះអាល័យឡើយ មនុស្សពាលដែលត្រេកត្រអាលចំពោះសរីរកាយនេះ ដល់កៀកនុបថើបប្រឡែងក៏ព្រោះតណ្ហា គឺសេចក្តីបំណង់ដែលកើតអំពីអាយតន ១២ នោះឯង សរីរកាយនេះលុះតែព្រះពុទ្ធឬសាវករបស់ព្រះពុទ្ធទើបបានដឹងច្បាស់ថា ជាគ្រឿងស្មោកគ្រោកស្អុយអាក្រក់គ្រប់យ៉ាងមិនគប្បីត្រេកត្រអាល គប្បីតែខ្ពើមរអើមធុញទ្រាន់សង្វេគនឿយណាយក្នុងសរីរកាយនេះជានិច្ចកាលទៅ ៗ

# ៤៩ សុភាសិតសូត្រ

កាលបើលោកសន្និវាស គឺភ្លើងមានរាគៈជាដើម ឆេះរុងរឿងអស់កាលជានិច្ចហើយ តើនឹងសើចដូចម្តេចបាន នឹងត្រេកអរដូចម្តេចបាន (អ្នក) នាងទាំងឡាយគឺងងឹតគ្របសង្កត់ហើយ ម្តេចឡើយក៏មិនស្វែងរកប្រទីបជាគ្រឿងបំភ្លឺ ។

សេចក្តីយឺតយូរ (ក្តី) សេចក្តីមាំមួន (ក្តី) តែងមិនមានដល់អត្តភាពណា អ្នក (ទាង) ចូរមើលចុះ អត្តភាពនោះមានវិចិត្រគឺកម្មធ្វើហើយ ជាកាយពាសពេញទៅដោយដំបៅដែលឆ្អឹងបីរយកំណាត់សង់ចូលគ្នាឡើង ហើយជាកាយក្តៅក្រហាយគឺឈឺជានិច្ច ដែលជនច្រើនគ្នាប្រាថ្នាហើយ ។

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគ (ទាំងពួង) ជារបស់ពុកផុយរលួយ ពនិកាយនៃខ្លួនជារបស់ស្អុយ តែងបែកធ្លាយទៅ (ជាធម្មតា) ព្រោះថាជីវិតរបស់សត្វ មានសេចក្តីស្លាប់ជាទីបំផុត ។

ឆ្អឹងទាំងឡាយឯណា មានសម្បុរដូចសម្បុរនៃសត្វព្រាប ដូចផ្លែឃ្លោកដែលគេចោលហើយក្នុងរដូវសរទកាល សេចក្តីត្រេកអរដូចម្តេចបាន ព្រោះតែឃើញនូវឆ្អឹងទាំងឡាយនោះ ។

សេចក្តីគ្រាំគ្រាក្តី សេចក្តីស្លាប់ក្តី សេចក្តីប្រកាន់ខ្លួនក្តី សេចក្តីលុបគុណក្តី ប្រជុំចុះហើយក្នុងសរីរណា សរីរនោះគឺកុសលាកុសល-

កម្មធ្វើហើយឲ្យទៅជានគររបស់ខ្មឹងទាំងឡាយ ដ៏បូកបាត់ហើយដោយសាច់និងឈាម ។

រាជរថទាំងឡាយ ដែលជាងធ្វើវិចិត្រហើយដោយល្អស្អាត គង់តែចាស់គ្រាំគ្រាទៅបានពិត មិនត្រឹមតែរាជរថប៉ុណ្ណោះ សូម្បីសរីរក៏គង់ចូលទៅជិតដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា មានតែធម៌របស់សប្បុរសទាំងឡាយ ទើបមិនចូលទៅជិតដល់នូវសេចក្តីគ្រាំគ្រាបាន ឯលោកសប្បុរសទាំងឡាយ តែងពោលនូវពាក្យដោយសប្បុរសទាំងឡាយតែប៉ុណ្ណោះ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តនូវព្រហ្មចរិយធម៌ មិនបានទ្រព្យធនក្នុងកាលនៃខ្លួននៅក្មេង តែងជ្រប់នៅដូចសត្វក្រៀលចាស់ទាំងឡាយ កាលជ្រប់នៅលើភក់ដែលមានត្រីអស់ហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តនូវព្រហ្មចរិយធម៌ មិនបានទ្រព្យធនក្នុងកាលនៃខ្លួននៅក្មេង កាលសោកស្តាយអំពើដែលខ្លួនធ្វើអំពីមុនទាំងឡាយ រមែងដេកនៅដូចកូនសរទាំងឡាយ ដែលអស់ស្រឡះហើយចាកបន្ទោះ ។

ឥឡូវនេះខ្លួនអ្នកដូចស្លឹកឈើទុំហើយ មួយទៀត ឯបុរសរបស់យមរាជទាំងឡាយ មានប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅហើយក្នុងប្រធាននៃសេចក្តីស្លាប់សាបសូន្យ សូម្បីស្បៀងអាហារគឺកុសលសោតក៏មិនមានដល់អ្នកឡើយ ។

អ្នកឯងចូរធ្វើវីរិយរបស់ខ្លួន ចូរធ្វើព្យាយាមឲ្យឆាប់ ចូរធ្វើជាអ្នកប្រាជ្ញទៅ បើអ្នកធ្វើយ៉ាងនេះហើយ អ្នកនឹងកំចាត់បង់មន្ទិលបាន មិនមានទីរួញពោលគឺកិលេសហើយ គង់នឹងដល់នូវទីជាអរិយបុគ្គលដ៏ជាទិព្វមិនខានឡើយ ។

បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងមិនទៀងដូច្នេះក្នុងកាលណាហើយ គង់នឿយណាយចំពោះសេចក្ដីទុក្ខ ក្នុងកាលណោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីហ្មត់ចត់ ។

បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងនាំមកនូវសេចក្ដីទុក្ខក្នុងកាលណាហើយ គង់នឿយណាយចំពោះសេចក្ដីទុក្ខ ក្នុងកាលណោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីហ្មត់ចត់ ។

បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងមិនមែនជារបស់ខ្លួនដូច្នេះក្នុងកាលណាហើយ គង់នឿយណាយចំពោះសេចក្ដីទុក្ខ ក្នុងកាលណោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីហ្មត់ចត់ ។

ធម៌ដែលឈ្មោះថាអនិច្ចតាធម៌ គឺសភាពប្រែប្រួលមិនទៀងទាត់ អនិច្ចតាធម៌នេះមិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយ ៗ ទេ មិនមែនជា

ធម៌សម្រាប់អ្នកនិគមតែមួយ ៗ ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយ ៗ ក៏មិនមែនទេ  អនិច្ចតាធម៌នេះជាធម៌សម្រាប់មនុស្សព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។

ធម៌ដែលឈ្មោះថាទុក្ខតាធម៌ គឺសភាពជាទុក្ខ ទុក្ខតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយ ៗ ទេ មិនមែនជាធម៌សម្រាប់អ្នកនិគមតែមួយ ៗ ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយ ៗ ក៏មិនមែនទេ ទុក្ខតាធម៌នេះជាធម៌សម្រាប់មនុស្ស ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។

ធម៌ដែលឈ្មោះថាអនត្តាធម៌ គឺសភាពមិនមែនជារបស់ខ្លួន អនត្តាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយ ៗ ទេ មិនមែនជាធម៌សម្រាប់អ្នកនិគមតែមួយ ៗ ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយ ៗ ក៏មិនមែនទេ អនត្តាធម៌នេះជាធម៌សម្រាប់មនុស្សព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។

គង្វាលគោកៀងគោទាំងឡាយដោយអាជ្ញា គឺដម្បងនឹងរំពាត់យ៉ាងណាមិញ ជរាគឺសេចក្តីគ្រាំគ្រា និងមច្ចុរាជគឺសេចក្តីស្លាប់ ក៏កៀងនាំទៅនូវអាយុរបស់សត្វទាំងឡាយយ៉ាងនោះឯង ។

អាយុនឹងក្តៅនឹងធាតុនឹងវិញ្ញាណ លះបង់នូវរាងកាយនេះកាលណាហើយ រាងកាយនេះជាសភាពគួរអ្នកផងបោះបង់ចោល តែងតែដេកស្តូក

ស្តឹងលើផែនដីក្នុងកាលណោះឯងដូចជាអគ្គិឆេះសម្ភុកកំណាត់ឈើ ដែលគេបោះបង់ចោល ។

សេចក្តីសោកកើតមានព្រោះសេចក្តីស្រឡាញ់ សេចក្តីភិតភ័យកើតមានព្រោះសេចក្តីស្រឡាញ់ កាលបើបុគ្គលរូបស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏មិនមាន សេចក្តីភិតភ័យនឹងមានមកពីណា ។

អាយុរបស់សត្វទាំងឡាយ រស់នៅតិចតួចពេកណាស់ គឺជរាតែងនាំចូលទៅរកសេចក្តីស្លាប់ កាលសត្វឯណាដែលត្រូវជរានាំទៅហើយ នឹងរកអ្វីជាទីឃាត់ខាំងកំងក នឹងជាទីពឹងពួនកោនជ្រកមិនមានឡើយ ។ កាលបើសាធុជនបានសំឡឹងឃើញភ័យក្នុងសេចក្តីស្លាប់នេះហើយ គួរតែសំឡឹងរំពឹងយកសេចក្តីស្ងប់រម្ងាប់ គឺព្រះនិព្វានហើយលះបង់នូវអាមិសគ្រឿងបញ្ឆោតចិត្ត ក្នុងលោកចោលចេញឲ្យបានកុំខានឡើយ ។

កាលទាំងឡាយតែងកន្លងផុតទៅ រាត្រីទាំងឡាយតែងចូលហួសទៅ ជំនាន់វ័យទាំងឡាយតែងលះបង់ជាលំដាប់ទៅ កាលបើសាធុជនបានសំឡឹងឃើញភ័យ ក្នុងសេចក្តីស្លាប់នេះហើយ គួរតែសំឡឹងរំពឹងយកសេចក្តីស្ងប់រម្ងាប់ គឺព្រះនិព្វានហើយលះបង់នូវអាមិសគ្រឿងបញ្ឆោតចិត្ត ក្នុងលោកចោលចេញឲ្យបានកុំខានឡើយ ។

## ៥០ សតិបដ្ឋាន ៤

១ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយហើយ ប្រុងតាំងស្មារតី ។

២ ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយហើយ ប្រុងតាំងស្មារតី ។

៣ ពិចារណាឃើញរឿយៗនូវចិត្តក្នុងចិត្តហើយ ប្រុងតាំងស្មារតី។

៤ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយហើយប្រុងតាំងស្មារតី ។

## ៥១ កាយេ កាយានុបស្សនាសតិបដ្ឋានំ

ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយថា (មិនទៀង មានទុក្ខ[1] មិនជារបស់ខ្លួនហើយផ្ចង់ស្មារតីចំពោះថា កាយនេះគ្រាន់តែជាកាយ មិនមែនសត្វមិនមែនបុគ្គល មិនមែនស្ត្រីនឹងបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនបានអាស្រ័យនៅដោយតណ្ហានឹងទិដ្ឋិ[2] ប្រព្រឹត្តនៅផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ (ឃើញដូច្នេះហើយ) ប្រព្រឹត្ត

---

១ មិនទៀង ជាទុក្ខមិនមែនរបស់ខ្លួន នេះគ្មានក្នុងសតិបដ្ឋានទេ តែធម៌នេះជាធម៌ពេញចិត្តរបស់ខ្ញុំ សូមបញ្ចូលជាធម៌ពិចារណា ។ ២ តណ្ហា សេចក្ដីចំណង់កើតអំពីអាយតន ១២ ទិដ្ឋិសេចក្ដីយល់ឃើញខុស ១០ យ៉ាង ។

ទៅ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្ដេញបង់នូវអភិជ្ឈា[១] និងទោម-នស្សក្នុងលោក ។

## ៥២ វេទនាសុ វេទនានុបស្សនាសតិបដ្ឋាន

ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយថា (មិនទៀងមានទុក្ខមិនមែនជារបស់ខ្លួនហើយ) ផ្ចង់ស្មារតីចំពោះថា (វេទនានេះគ្រាន់តែជាវេទនា មិនមែនសត្វមិនមែនបុគ្គល មិនមែនស្ត្រីនិងបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនបានអាស្រ័យទៅដោយតណ្ហា និងទិដ្ឋិប្រព្រឹត្តទៅផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ (ឃើញដូច្នេះហើយ) ប្រព្រឹត្តទៅ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វមានស្មារតីជាគ្រឿងកំណត់បណ្ដេញបង់ នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

## ៥៣ ចិត្តេ ចិត្តានុបស្សនាសតិបដ្ឋាន

ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តថា (មិនទៀង មានទុក្ខមិនមែនជារបស់ខ្លួនហើយ) ផ្ចង់ស្មារតីចំពោះថា (ចិត្តនោះគ្រាន់តែជាចិត្ត មិន

១ អភិជ្ឈា លោភបង្អោនយកទ្រព្យអ្នកដទៃ ទោមនស្ស សេចក្ដីអាក់អន់ចិត្ត ។

មែនសត្វមិនមែនបុគ្គលមិនមែនស្ត្រីនិងបុរសជាដើម ) ល្មមតែកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនបានអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិប្រព្រឹត្តទៅផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ (ឃើញដូច្នេះហើយ) មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដ៏ងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

## ៥៤ ធម្មេសុ ធម្មានុបស្សនាសតិបដ្ឋានំ

ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយថា (មិនទៀង មានទុក្ខមិនមែនជារបស់ខ្លួនហើយ) ដំកល់ស្មារតីចំពោះថា ធម៌នេះគ្រាន់តែជាធម៌ មិនមែនសត្វមិនមែនបុគ្គល មិនមែនស្ត្រីនិងបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះផង មិនបានអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិប្រព្រឹត្តទៅផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ (ឃើញដូច្នេះហើយ) ប្រព្រឹត្តទៅ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដ៏ងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់ នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

## ៥៥ សតិបដ្ឋានវិធី

ផ្លូវគឺសតិបដ្ឋានទាំងឡាយ ៤ នេះ ជាផ្លូវមូលតែមួយប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្អាតវិសេសដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោក និងខ្សឹកខ្សួលរំជួលចិត្តទាំងឡាយ ដើម្បីដល់នូវអរិយមគ្គ ជាធម៌សម្រាប់ស្រោចស្រង់សត្វ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន (ជាស្ថានក្សេមផុតលោក) ។

## ៥៦ សារូបកថា និដ្ឋិតា

ធម៌អាថ៌ដែលខ្ញុំរៀបរាប់ឲ្យសមរម្យនឹងវ័យ ៣ ប្រការនេះ មិនមែនមានតែប៉ុណ្ណេះទេ នៅមានច្រើនជាអនេកទៅទៀត មិនឈ្នះនឹងយកមកថ្លែងឲ្យអស់ឡើយព្រោះគ្មានពេល សំដែងយកប៉ុណ្ណេះគ្រាន់តែជាប្រដាប់ប្រាជ្ញារបស់លោកអ្នកសិក្សា ពណ៌នាមកនេះមិនបានជាចប់សព្វគ្រប់ទេ តែសន្មតថាចប់ដោយសង្ខេបតែប៉ុណ្ណេះហោង ។ ៚—

កំណត់សាងព្រះត្រៃបិដកបាលីនិង
សេចក្តីប្រែតាំងពីព្រះពុទ្ធសករាជកន្លង
ទៅពីរពាន់បួនរយចិតសិបពីរ ឆ្នាំក្នុង
ថ្ងៃព្រហស្បតិ៍បីកើត ខែបុស្ស ឆ្នាំមមី
ទោស័កគឺថ្ងៃពីរបហាំងវិយេរឆ្នាំមួយពាន់
ប្រាំបួនរយសាមសិប ចប់ព្រះវិនយបិ-
ដកក្នុងព្រះពុទ្ធសករាជកន្លងទៅពីរ
ពាន់បួនរយចិតសិបប្រាំបី ក្នុងថ្ងៃអង្គារ
ប្រាំបីកើតខែមិគសិរឆ្នាំកុរសប្តស័ក គឺ
ថ្ងៃបីដេសម ឆ្នាំមួយពាន់ប្រាំបួនរយ-
សាមសិបប្រាំ ក្នុងព្រះរាជបណ្ណាល័យ
កម្ពុជានេះ ។

ខ្ញុំចូលមកធ្វើការជំនួយពិនិត្យបាលីព្រះត្រៃបិដក ក្នុងព្រះរាជបណ្ណាល័យកម្ពុជាក្រុងភ្នំពេញ តាំងពីថ្ងៃ ១ ខែយូអាំងឆ្នាំ ១៩៣០ ដោយអំណាចសម្តេចចក្រីលោកបង្គាប់ឲ្យចូលធ្វើក្នុងពេលដែលត្រឡប់មកអំពីដើរត្រួតត្រាការសិក្សាដល់ថ្ងៃ ៤ អ៊ូតឆ្នាំ ១៩៣១ នោះព្រះតេជព្រះគុណលោកគ្រូព្រះសិរីសម្មតិវង្សអធិបតីក្រុមជំនុំ ប្តឹងទៅរាជការសូមឲ្យធ្វើជំនួយការដដែល ដោយបៀវត្សអាំងស្ប៉ិកទ័រ ដល់ថ្ងៃ ១ អ៊ូតឆ្នាំ ១៩៣៣ រាជការដាច់ថាក្រប្រាក់ បញ្ឈប់បៀវត្សអាំងស្ប៉ិកទ័រខ្ញុំធ្វើការនេះ៦ខែឥតមាន បៀវត្ស លុះដល់ថ្ងៃ១ យ៉ាំងវិយេរឆ្នាំ ១៩៣៤ នោះលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យលោកប្តឹងទៅរាជការជាធំសូមឲ្យមានអាររតេតាំងខ្ញុំស៊ប់ជាក្រុមជំនុំព្រះត្រៃបិដកក្នុងក្រុមពុទ្ធសាសនបណ្ឌិត្យរហូតមក ។ ដែលខ្ញុំដំណាលមកប៉ុណ្ណេះដោយសេចក្តីប៉ុនប៉ងនឹងប្រកាសឧប្បត្តិហេតុ ដែលចាប់ផ្តើមកសាងព្រះត្រៃបិដកបាលីនឹងសេចក្តីប្រែ ទុកខាងចុងនៃធម្មិកាថានេះ កំណត់ដែលតាំងសាងមកដល់ចប់ព្រះវិនយបិដក ដូចមានក្នុងភាគឯខាងលើនេះហើយនឹងសេច-

ក៏យ៉ គន់សិក្ខាបទក្ខន្ធក ទាំងបរិវារ គន់ក្នុងព្រះវិន័យបិដកទាំងស្រុង ដូចមានខាងក្រោមនេះ ៗ

# ព្រះវិនយបិដក

១ មហាវគ្គ បឋមភាគ វេរញ្ជកណ្ឌ សេចក្ដីដំណាលរឿងវេរញ្ជព្រាហ្មណ៍ ទាំងបារាជិកកណ្ឌ កណ្ឌសំដែងអំពីបារាជិក ៤ ៗ

២ មហាវគ្គ ទុតិយភាគ តេរសកណ្ឌ កណ្ឌសំដែងអំពីសង្ឃាទិសេស ១៣ ទាំងអនិយតកណ្ឌ កណ្ឌសំដែងអំពីអនិយត ២ ៗ

៣ មហាវគ្គ តតិយភាគ និស្សគ្គិយកណ្ឌ កណ្ឌសំដែងអំពីនិស្សគ្គិយ ៣០ ទាំងបាចិត្តិយកណ្ឌ កណ្ឌសំដែងអំពីបាចិត្តិយ ១៥ សិក្ខាបទ ៗ

៤ មហាវគ្គ ចតុត្ថភាគ បាចិត្តិយកណ្ឌ កណ្ឌសំដែងអំពីបាចិត្តិយ បាដិទេសនីយកណ្ឌ កណ្ឌសំដែងអំពីបាដិទេសនីយ ៤ សេខិយកណ្ឌ កណ្ឌសំដែងអំពីសេខិយ ៧៥ ទាំងអធិករណសមថកណ្ឌ កណ្ឌសំដែងអំពីអធិករណសមថ ៧ (ចប់បាតិមោក្ខ) ៗ

៥ ភិក្ខុនីវគ្គ បច្ចេកភាគ សំដែងពីសិក្ខាបទភិក្ខុនី បារាជិក ៨ សង្ឃាទិសេស ១៧ និស្សគ្គិយ ៣០ បាចិត្តិយ ១៦៦ បាដិទេសនីយ ៨ សេខិយ ៧៥ អធិករណសមថ ៧ ជា ៣១១) ៗ

៦ មហាវគ្គ បឋមភាគ មហាខន្ធក សំដែងអំពីបព្វជ្ជា នឹងឧបសម្បទាជាដើម ឧបោសថក្ខន្ធក សំដែងអំពីឧបោសថ នឹងវិធីសម្មតិសីមាជាដើម ។

៧ មហាវគ្គ ទុតិយភាគ វស្សូបនាយិកក្ខន្ធក សំដែងអំពីចូលវស្សា នឹងសត្តាហកិច្ចជាដើម បវារណាខន្ធក សំដែងអំពីបវារណាជាដើម ចម្មក្ខន្ធក សំដែងអំពីសមណបរិក្ខារជាដើម នឹងភេសជ្ជក្ខន្ធក សំដែងអំពីគ្រឿងអរក្នុងចតុប្បច្ច័យដែលកើតអំពីរូបិយជាដើម ។

៨ មហាវគ្គ តតិយភាគ កឋិនក្ខន្ធក-សំដែងអំពីក្រាលគ្រងអនុមោទនាកឋិនជាដើម ចីវរក្ខន្ធក សំដែងអំពីទឹកជ្រលក់ ៦ យ៉ាងជាដើម ចម្បេយ្យក្ខន្ធក សំដែងអំពីសង្ឃកម្មជាដើមនឹងកោសម្ពិកក្ខន្ធក សំដែងអំពីទាស់ទែងគ្នាជាដើម ។

៩ ចុល្លវគ្គ បឋមភាគ កម្មក្ខន្ធក សំដែងអំពីតជ្ជនីយកម្មជាដើម បរិវាសិកក្ខន្ធក សំដែងអំពីគរុកាបត្តិត្រូវធ្វើបរិវាសកម្មជាដើម សមុច្ចយក្ខន្ធក សំដែងអំពីបរិវាសកម្ម ៣ យ៉ាងនឹងអព្ភានកម្មជាដើម ។

១០ ចុល្លវគ្គ ទុតិយភាគ សមថក្ខន្ធក សំដែងអំពីអធិករណ ៤ យ៉ាង មានវិវាទាធិករណជាដើម ខុទ្ទកវត្ថុក្ខន្ធក សំដែងអំពីសមណសារុប្បជាដើម សេនាសនក្ខន្ធក សំដែងអំពីសាមគ្គីនៃសង្ឃ នឹងគរុភណ្ឌរបស់សង្ឃជាដើម ។

១១ ចុល្លវគ្គ តតិយភាគ សង្ឃភេទក្ខន្ធក សំដែងអំពីសាមគ្គីនៃសង្ឃជាដើម វត្តក្ខន្ធក សំដែងអំពីអាគន្តុកវត្តជាដើម បាតិមោក្ខឋបនក្ខន្ធក សំដែងអំពីអច្ឆរិយព្ភូតធម៌ ៨ យ៉ាងជាដើម ភិក្ខុនីខន្ធក សំដែងអំពីឧបសម្បទានៃភិក្ខុនី មានគរុធម៌ ៨ ប្រការជាដើម បញ្ចសតិកក្ខន្ធក សំដែងអំពីបរិនិព្វានហើយត្រឹម ៣ ខែធ្វើបឋមសង្គាយនា និងសត្តសតិកក្ខន្ធក សំដែងអំពីរឿងធ្វើទុតិយសង្គាយនា វត្ថុ ១០ យ៉ាងជាដើម ។

១២ បរិវារ បឋមភាគ មហាវិភង្គ សោឡសមហាវារ ភិក្ខុនីវិភង្គ សោឡសមហាវារ សមុដ្ឋានសីសសង្ខេប កតិបុច្ឆាវារ និងវីសតិវារ ។

១៣ បរិវារ ទុតិយភាគ ខន្ធបុច្ឆា ឯកុត្តរិក ឧបោសថាទិបុច្ឆាវិសជ្ជនា អត្ថវសបករណ គាថាសង្គណិក និងអធិករណភេទជាដើម ។

ចប់ ព្រះវិន័យបិដក ១៣ សៀវភៅ ។

# កុសលកម្មបថ ១០

សង្ខេប

អាចារ្យ ហ. ឈា ក្រុមជំនុំព្រះត្រៃបិដក

ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យនៅព្រះរាជបណ្ណាល័យ

ក្រុងភ្នំពេញ

បានតែងជាពាក្យកាព្យ

បទព្រហ្មគិត

## គម្រុសលការម្ហូបជ ១០

### សង្ខេប

# តែងជាពាក្យកាព្យ

### បទព្រហ្មគីត

១ ខ្ញុំសូមលើកហត្ថា ទុនសិរសា ថ្វាយបង្គំ
រំលឹកដល់ប្រជុំ គុណព្រះស្រីរត្នៈត្រ័យ ៗ
ជាកែវវិសេសឯក ល្អចំឡែកផុតវិស័យ
ត្បូងពេជ្រកែវចរណៃ ថ្លៃយ៉ាងណា ផ្ទឹមពុំបាន ៗ
ព្រះត្រៃរត្នវិសុទ្ធ ខ្ពស់បំផុតក្នុងភពឋាន
កម្រនឹងរកបាន ក្រៅខែត្រស្ថានពុទ្ធកាល ៗ
ពួកមនុស្សនឹងទេវតា តែងប្រាថ្នាស្វែងត្រអាល
រកកែវថ្លៃត្រកាប ទុកជាទីពឹងក្នុងប្រាណ ៗ
ដោយអំណាចប្រណម្យ ត្រៃឧត្តមថ្លៃថ្កើងថ្កាន
គ្រោះថ្នាក់ទាំងប៉ុន្មាន កុំបីបានក្តីយាយី ៗ
ដល់ខ្លួនខ្ញុំអ្នកតែង កាព្យកិច្ចថ្លែងដោយភក្តី
ភាសិតព្រះមុនី តាមវិធីពុទ្ធសាស្នា ៗ
ហៃសប្បុរសទាំងឡាយ ចូរប្រែងកាយផ្ចង់សោតា
ខាត់ចិត្តឲ្យភ្លឺថ្លា ស្តាប់អត្ថាធិប្បាយថ្លែង ៗ

អំពីកម្មៈបថ
ព្រះពុទ្ធទ្រង់សំដែង
ជាកាយៈកម្មបី
ឯមនោកម្មលោកចាត់
រួមត្រូវជា ១០ គត់
ចែកជាកុសលបាន
ប៉ែកខាងអកុសល
បំនួនដប់ៗម្នាង

ទឹងពោលតាមបរិយាយ

កុសលទុកដម្រូវ
ដែលមានចិត្តសទ្ធា
ស្ម័គ្រក្នុងច្បាប់គ្រហស្ថ
ទី ១ គឺបាណា
សត្វតូចជាលំដាប់
ទី ២ អទិន្នា
ទ្រព្យគេទោះតូចធំ
ទី ៣ វៀរប្រព្រឹត្ត
លបលួចរួមសង្វាស

ដប់ប្រាកដដោយជាក់ស្តែង
ញែកចែកតាមថ្នាក់សង្កាត់ ។
ជាបីកម្មបួនម៉ាត់
ជាពាក្យអត្ថមានបីហាន ។
ចូរកំណត់កត់ក្នុងប្រាណ
តាមលំអានមាន ១០ យ៉ាង ។
ដប់រៀងកល់ជាតឹកតាង
ដូចតួយ៉ាងមានតទៅ ។
បកប្រែស្រាយអំពីផ្លូវ
ដល់ពួកជនជាសប្បុរស ។
គ្មានរួញញាកទទឹងទាស់
ព្រះទ្រង់យសសំដែងប្រាប់ ។
លោកហាមជាកុំសំឡាប់
ដកបដល់សត្វធំៗ ។
លួចទ្រព្យាគួរតែកុំ
ត្រូវវៀរលែងកុំផ្តេសផ្តាស ។
ទុច្ចរិតបិត្តឡេះឡាស
សេពមេថុនទឹងកិរិយា ។

បុត្រានឹងបុត្រី ទាំងស្វាមីជននានា
សប្បុរសលោកតែងលា លះលែងធ្វើមួយជីវិត ។
ចប់កាយកម្មបី ដោយសេចក្ដីវិសុទ្ធិ
អស់លោកអ្នកស្ម័គ្រចិត្ត ចូរប្រព្រឹត្តឲ្យត្រឹមត្រូវ ។
ឯវចីកម្មបួន មានចំនួនដូចតទៅ
រៀងលេខតាំងទុកនៅ ជាលំដាប់តាមទីស្ថាន ។
ទី ១ វៀរមុសា ពោលពាថាស្មាន ។
កូតករបង្វែងដាន យកមិនបានជាការពិត ។
ទី ២ វៀរវាចា បិសុណាបំបែកមិត្រ
ញុះញង់ជនឆ្ងាយជិត ឲ្យវិបរិតកើតជំលោះ ។
ទី ៣ វៀរវាចា ផរុសាពោលទ្រគោះ
ប្រទេចដេរពេរឈ្លោះ ជៀលពូជពង្សម៉ែឪគ្នា ។
ទី ៤ វៀរសំផី ពាក្យអប្រិយស្ដីខ្វីខ្វា
ឡេះឡោះរកគ្នីគ្នា តុកកំប៉ុងលេងរកីរ ។
ចូលក្នុងពាក្យតិរច្ឆាន មានប្រមាណសាមសិបពីរ
ពិស្ដារក្នុងគម្ពីរ ប្រាប់សេចក្ដីស្អាតជ្រៅជ្រះ ។
វចីកម្មទាំងបួន គ្រប់ចំនួនមិនលើសខ្វះ
បញ្ចប់ចុះស្រឡះ នឹងពោលផ្ទាស់សេចក្ដីប្លែក ។

ឯមនោកម្មទាំងបី ជាសេចក្តីដោយញែក
ព្រះពុទ្ធសំដែងបែក តាមបំណែកចិត្តខុសគ្នា ៗ
ទី ១ កុំរំពឹង គិតសំឡឹងក្នុងទ្រព្យ
របស់ជននានា បង្អោនមកដើម្បីខ្លួន ៗ
ទី ២ អព្យាបាទ កុំអាឃាតចងគុំគួន
គំនិតចិត្តល្អមាំមួន មិនបំផ្លាញសត្វាសេត្វ ៗ
ទី ៣ យល់ឃើញត្រូវ ចុះក្នុងផ្លូវធម៌បរមត្ថ
មិនខុសមិនវិបត្តិ តាមសច្ចៈធម៌បួនយ៉ាង ៗ
ឬមួយយល់ឃើញថា ចិត្តជ្រះថ្លាចង់កសាង ៗ
កុសលអ្វីម្យ៉ាង ៗ មានផលគាងដោយទៀងទាត់ ៗ
មនោកម្មទាំងបី ចប់សេចក្តីជាកំណត់
សង្ខេបតាមបែបបទ ដោយសង្ខតែប៉ុណ្ណោះ ៗ
សប្បុរសទាំងប្រុសស្រី គួរគប្បីរៀនឲ្យចេះ
ឲ្យចូលចិត្តទុកគ្រឹះ រិះថ្លឹងឲ្យស្គាល់ផល ៗ
ហើយខំកាន់ប្រព្រឹត្ត សុចរិតក្នុងកុសល
ទាំង ១០ ទុកជាថ្នល់ ដើរទៅកាន់សួគ៌និព្វាន ៗ
ទើបបានអានិសង្ស ដែលគួរគ្រែព្រះទ្រង់ញាណ
សំដែងប្រាប់ថាមាន ប្រាំប្រការពិតប្រាកដ ៗ

អានិសង្សទី ១ ថា
រក្សាកម្មបថ
អ្នកនោះផុតកំហា
នឹងរួចផុតស្រឡះ
គឺគ្មានក្ដៅក្រហាយ
ធ្វើខ្លួនឲ្យក្សេមក្សាន្ត

អានិសង្សទី ២ ថា
ទាំង ១០ ដោយប្រពៃ
ព្រោះលោកពិចារណា
អ្នកប្រាជ្ញលោកតែងដើរ
អានិសង្សគំរប់បី
ខ្ពង់ខ្ពស់ពិសិដ្ឋ
អានិសង្សគំរប់បួន
ក្រហល់ខ្វល់ក្នុងកាយ
គឺមានស្មារតីរឹង
តាំងក្នុងគុណដ៏មាំ

អានិសង្សទី ៥ ថា
យល់ឃើញថាចាស់ក្មេង

អ្នកឯណាចិត្តម៉ត់ចត់
ឲ្យគត់មត់មិនឲ្យខ្វះ ៗ
ខ្លួនស្ដីថាពោលជៀសគ្រះ
ខ្លួនជៀសខ្លួនឯងពុំបាន ៗ
ស្រពោះស្ដាយក្រោយក្នុងប្រាណ
សុខសម្រានឥតកិតភ័យ ៗ
អ្នកឯណាកាន់វិន័យ
វិញ្ញូជនតែងសរសើរ ៗ
ដោយបញ្ញាតាមដំណើរ
ថ្លែងទៅរកកន្លែងសុខ ៗ
ផ្សាយសិរីល្បីសព្វស្រុក
ពួកេរ្ដិ៍ឈ្មោះពីរោះឆ្ងាយ ៗ
ស្លាប់ដ៏ខ្លួនមិនក្រហាយ
ពោលកាយមាយកាន់ប្រឡំ ៗ
ចិត្តទឹងដឹងក្នុងអារម្មណ៍
ពេលទៀបស្លាប់មិនវង្វេង ៗ
ព្រះសាស្ដាស្ដេចទ្រង់ឈ្មេង
ណាមានចិត្តស្អាតបរិសុទ្ធ ៗ

ស្រឡាញ់ថែរក្សា　　កាន់សាស្នាព្រះសម្ពុទ្ធ
អ្នកនោះនឹងបានផុត　　ពីទុក្ខភ័យក្នុងអាត្មា ។
លែងស្គាល់ស្ថាននរក　　ស្គាល់តែសុខក្នុងមនុស្សា
សុខដល់ស្ថានទេវតា　　ឆកាមាទាំងប្រាំមួយ ។
រុងរឿងថ្កើងអស្ចារ្យ　　សោយអាហារទិព្វមិនព្រួយ
ព្រោះផលកុសលជួយ　　សួយឲ្យទៀងជាទេវតា ។
សម្បត្តិទិព្វទាំង ១០　　ជាកំណប់នៃបណ្ដា
ប្រុសស្រីដែលសិក្សា　　រៀនទន្ទេញកម្មបថ ។
ប៉ែកខាងអកុសល　　នឹងកុសលឲ្យប្រាកដ
ប្រតិបត្តិមិនឲ្យឃ្លាត　　ដាច់ធ្លុះធ្លាយសៅហ្មងឡើយ ។
ទៀងតែនឹងបានដល់　　សុខថ្កើងថ្កល់សម្រានស្បើយ
សម្បត្តិទិព្វនេះហើយ　　ជាកំរៃផលកសាង ។
សន្សំធម៌សុចរិត　　ទុកក្នុងចិត្តជាគ្រឿងអាង
ទុច្ចរិតទាំង ៣ យ៉ាង　　ត្រូវកុំសាងឲ្យមានសោះ ។
អ្នកប្រាជ្ញពីបុរាណ　　លោកមិនបានស្ដាយស្រណោះ
ព្រះវ័យខំលោតផ្លោះ　　ឲ្យផុតបាកអកុសល ។
ទាំង ១០ បេញស្រឡះ　　ហើយខំស្វះស្វែងកុសល
ទាំង ១០ ទុកជាផល　　សម្រាប់សោយសុខពល់ជាតិ ។

ដូចុះផនទាំងក្បាយ　　គួរតាំងកាយកុំឲ្យឃ្លាត
អំពីពុទ្ធោវាទ　　ដែលទ្រង់ប្រោសប្រទានទុក ។
ដល់សត្វក្នុងសាស្នា　　ឲ្យសិក្សាមិនរើសមុខ
សត្វណាប្រាថ្នាសុខ　　តែងបានសោយបុណ្យសម្បត្តិ ។
ក្នុងស្ថានមនុស្សទេវតា　　ជើងថ្លៃថ្លាចាកវិបត្តិ
ដរាបសោយបរមត្ថ　　សុខសម្បត្តិក្នុងនិព្វាន ។
និរាសអំពីជាតិ　　ជរាព្យាធិទុក្ខគ្មាន
មរណៈទុក្ខមិនហ៊ាន　　តាមផ្ដន្ទាបៀតបៀនឡើយ ។
ឯកម្មជាកុសល　　តែងឲ្យផលសុខឥតស្បើយ
កុំច្រល់ណាជនអើយ　　ចូរសិក្សាឲ្យស្ទាត់ចុះ ។
ពោលតែខាងកុសល　　អកុសលគង់ក្ដីដុះ
បើពោលថែមចម្រុះ　　នាំឲ្យសុះសាំសេចក្ដី ។
ប៉ែកខាងអកុសល　　ត្រូវសំគាល់ថាអប្រិយ
អាក្រក់មិនគប្បី　　ដែលប្រុសស្រីប្រព្រឹត្តធ្វើ ។
តាំងតែពីបាណា　　អទិន្នាសព្វអះទ្វើ
ដរាបគ្រប់អំពើ　　ធ្វើទាំង ១០ ឥតសល់មួយ ។

ឯបាបទាំង ១០ នេះ ឲ្យផលឆេះឆុយល្ហួយ
នាំសត្វឲ្យកើតព្រាយ ក្ដៅខ្លោចផ្សាក្នុងអបាយ ៗ
សោយទុក្ខគ្រប់ប្រការ ជួនអស្ចារ្យអន្ទ្រងធ្លាយ
កម្មបានប្រកាយ ឲ្យក្លាយជាមនុស្សប្រុសស្រី ៗ
ទសកម្មបថា និដ្ឋិតាសង្ខេបខ្លី
បញ្ចប់អស់សេចក្ដី ដោយវេលានេះឯងហោង ៗ

អាចារ្យហុង-ឈា

ក្រុមជំនុំព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត្យ
នៅព្រះរាជបណ្ណាល័យ ក្រុងភ្នំពេញ

ព.ស. ២៤៨១

# រឿងព្រេង — បុរសពីរនាក់

និយាយរឿង ១ មានបុរសពីរនាក់នាំគ្នាដើរទៅផ្លូវឆ្ងាយដល់ព្រៃដូន យប់ងងឹតដើរទៅមិនរួចបបួលគ្នាដេកក្នុងព្រៃ ឯបុរសពីរនាក់នោះផ្តើមគ្នាដេកកណ្តាល់ ប៉ុន្តែមិនដឹងគិតធ្វើដូចម្តេចនឹងបានដេកកណ្តាល អ្នកទាំងពីរគិតព្រមគ្នាថា បើដូច្នោះ យើងដេកយកជើងទល់គ្នាទើបស្រួល បុរសទាំងពីរនាក់ក៏ដេកយកជើងទល់គ្នាដណ្តប់សំពត់ជិតលក់ទៅ ។

លុះយប់ជ្រៅមានសត្វខ្លាដើរមកបានឃើញមនុស្សពីរនាក់ដេក ក៏មើលមិនស្គាល់ជាសត្វអ្វី ខ្លាឆ្ងល់ណាស់ដ្បិតមិនដែលឃើញ ក៏បបួលអស់សត្វឯទៀតច្រើនមកជួយមើលឲ្យស្គាល់ច្បាស់ប្រាកដ សត្វទាំងនោះក៏នាំគ្នាមកមើលគ្មានសត្វណាមួយដឹងស្គាល់សោះ ទើបសត្វទាំងអម្បាលនោះប្រឹក្សាគ្នាថា សត្វនៅក្នុងព្រៃនេះប៉ុន្មានមកមើលអស់ហើយនៅសល់តែសត្វទន្សាយពុំបានមក មួយទៀត ឮល្បីថា សត្វទន្សាយជាអ្នកមានប្រាជ្ញាចេះនិយាយក្បួនច្បាប់ទំលាប់ ចេះកលមាយាចេះចាំទំនិមទំនៀមច្រើន បើដូច្នេះ យើងប្រើបងដំរីឲ្យទៅអញ្ជើញបងទន្សាយមកឲ្យមើលទើបស្គាល់សត្វនេះ ឯទន្សាយនោះបើមាននរណាទៅពឹងការអ្វីៗ កាន់ខ្ជួនណាស់ សត្វទាំងនោះប្រឹក្សាគ្នាព្រមហើយ ក៏ឲ្យដំរីទៅអញ្ជើញទន្សាយ ដំរីក៏ទៅឃើញទន្សាយអង្គុយនៅលើក្បាលដំបូក ទន្សាយឃើញដំរីដើរយោកយោកមកក៏សួរថា បងដំរីមកមានការអ្វីបានជាដើររលះរលាំងម្ល៉េះ

ដំរីប្រាប់ថា បងទន្សាយអើយ ដ្បិតមានសត្វមួយគ្មាននរណាស្គាល់សោះ គង្វាលសត្វទាំងអស់ឲ្យខ្ញុំមកអញ្ជើញបងទៅមើល បើបងទៅមើលទើង ស្គាល់ប្រាកដ ទន្សាយសួរថា សត្វនោះដូចម្តេចតូចធំវែងខ្លី ដំរីនោះ ប្រាប់ថា សត្វនោះធំប៉ុនដើមត្នោតកណ្តាលហើយវែងប្រមាណ ៨ ហត្ថ ទន្សាយថា បើដូច្នោះ បងដំរីកុំព្រួយខ្ញុំព្រមទៅមើលឲ្យស្គាល់សត្វនោះ ប៉ុន្តែឲ្យជិះលើក្បាលបងឯង ដំរីក៏ឱនក្បាលឲ្យទន្សាយជិះរួចដើរទៅ ទន្សាយក៏ធ្វើពាក្យសំដីជាក្អេងក្អាង លុះដល់ហើយទន្សាយចុះពីក្បាលដំរី យកស្លឹកឈើដែលមានស្នាមដង្កូវស៊ីដូចជាអក្សរ កាន់លើកឡើងធ្វើជា សំបុត្រថា អស់បងប្អូនស្តាប់ខ្ញុំដ្បិតខ្ញុំជាបំរើព្រះឥន្ទ្រ ។ លោកប្រើឲ្យនាំ សំបុត្រមក ហើយទន្សាយឡើងលើដំបូកធ្វើជាមើលសំបុត្រថា សត្វនេះ ព្រះឥន្ទ្រលោកប្រើមក ឈ្មោះសត្វយោគីយោគា ឲ្យមកយកទាំងអស់ គ្នា ទាំងអញទាំងឯង សត្វទាំងនោះបានស្តាប់ទន្សាយមើលសំបុត្រព្រះ ឥន្ទ្រថា ឲ្យមកយកទាំងអស់គ្នាភ័យណាស់ក៏ស្ទុះបោលជាន់គ្នាស្រែករំពង ព្រៃ សត្វខ្លះបាក់ជើងស្លាប់នៅទីនោះច្រើន ឯបុរសទាំងពីរនាក់បានដឹង ថា សត្វទាំងនោះផ្អើលភ្ញាក់តែជាន់គ្នាស្លាប់ដូច្នោះហើយក្រោកឡើងលើក ដៃសំពះទន្សាយថា អ្នកទន្សាយមានគុណនឹងយើងច្រើន បើប្រសិន

ណា មិនបានអ្នកទន្សាយមកធ្វើកលឧបាយប្រាជ្ញជួយយើងទេ សត្វខ្លាទឹងខាំយើងស៊ីជាអាហារពុំមិនខាន អ្នកទន្សាយនេះមានបញ្ញា ល្មមធ្វើជាសុភាបាន ហើយបុរសទាំងពីរនាក់មើលទៅឃើញអស់សត្វជាន់គ្នាស្លាប់ពាសពេញព្រៃក៏បបួលគ្នាអារយកសាច់រែកត្រឡប់មកផ្ទះវិញ ។

រឿងបុរសពីរនាក់ចប់តែប៉ុណ្ណោះ ។

ឧកញ៉ា ប្រាជ្ញាធិបតីហាងហ្វាង ( យិន ) តែង ៕

# បញ្ជីរឿង


១ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . ១៥៧

២ — ព្រះមហាវិហារពុទ្ធគយា . . . . . . . . . . . . . . . . . . . ១៦៣

៣ — ប្រជុំពាក្យកាព្យ ភាគទី ៣ (តទី ៦) . . . . . . . . . . . . . . . . ១៨១

៤ — ហិតោបទេស ភាគទី ១ . . . . . . . . . . . . . . . . . . . ១៩៧

៥ — រឿងព្រេង — រឿងបុរសផ្កាប់ត្រឡោក . . . . . . . . . . . . . . . ២០៧

៦ — លទ្ធិទំនៀមទម្លាប់ខ្មែរ — ពិធីសូត្របន្ទួលដោះគ្រោះ . . . . . . . . . . ២១៥


## *រូបក្រៅរឿង*


ប្រទេសលាវ-សៀម ស្រុកឆៀងហ្មៃ វត្តឆៀងទង រូបគ្រែទេវតា . . . . ១៥៥

# TABLE DES MATIÈRES

Pages

I- Informations diverses ....................I57

2- Le Préas Maha Vihara BODDHIGAYA par Maha Krasém........ I63

3- Recueil de poèmes, 3e partie, par Préas Bat Samdach Préas Thammaréachéa(suite)I8I

4- Hitopadesa Ire partie (suite)............I97

5- Contes populaires cambodgiens inédits :

L'homme à la noix de coco renversée (Boros phkab Tralôk)............207

6- Moeurs & coutumes cambodgiennes :

Formules pour écarter les malheurs......2I5

HORS TEXTE :

Laos-Siamois - Chieng-Mai - Vat Xieng-Khong - Chaire à prêcher ....... I55



ប្រទេសលាវ-សៀម ស្រុកជៀងហ្មៃ វត្តជៀងខង រូបគ្រែទេសនា ។

## សុភាសិតនេះគួរទន្ទេញភាវនាទុក

"យើងមិនត្រូវសោយទុក្ខទោមនស្ស នឹងពាក្យអាក្រក់ដែលគេនិយាយពីយើង មានតែសេចក្ដីល្អដែលគេមិននិយាយពីយើង បើចិត្តយើងល្អស្រាប់ហើយ ពាក្យផ្សេងៗដែលលោកទាំងមូលពោលពីយើង ក៏ពុំអាចធ្វើសន្ដានចិត្តយើងឲ្យល្អអាក្រក់បានឡើយ ឬធ្វើកុសលធម៌ទាំងឡាយដែលយើងបានធ្វើហើយឲ្យវិនាសទៅវិញពុំបានឡើយ" ។

ដំណាំដង្រូវ ។

## អំពីបុណ្យតាំងពិពិធភណ្ឌគ្រប់ប្រទេស
## នៅក្រុងប៉ារីស ក្នុងឆ្នាំ១៩៣៧

សព្វថ្ងៃនៅសល់តែសេចក្ដីរំឭកនឹកដល់បុណ្យមហាឧឡារិកនេះដែលជនជាតិខ្មែរយើងខ្លះបានទៅឃើញនឹងគេដែរ ។

ក្នុងកាលនោះមានអ្នកប្រាជ្ញបារាំងសែសម្នាក់អធិប្បាយអំពីសេចក្ដីប្រាថ្នាដែលបង្កើតឲ្យមានបុណ្យតាំងវត្ថុទាំងឡាយឡើង មានបុណ្យដែលធ្វើនៅក្នុងប៉ារីស កាលពីឆ្នាំ ១៩៣៧ជាដើម អ្នកប្រាជ្ញនោះនិយាយថា បុណ្យអស់នោះ គឺមហាសន្និបាតនៃពួកអ្នកស្រុកទាំងអស់ក្នុងលោកនាំគ្នា

យកបំណោះវិជ្ជាការមកប្រៀបផ្ទឹមគ្នា ៗ ឯសេចក្តីប្រឹងប្រែងព្យាយាមទាំងនេះ មិនគ្រាន់តែបង់តាញ់ឈ្នះគ្នាប៉ុណ្ណោះទេ គឺចង់ជួយគ្នាទៅវិញទៅមកទៀតផង មហាជនដែលបានទៅឃើញពិធីបុណ្យនោះហើយទើបដឹងថា ក្រៅអំពីវត្ថុដែលកើតឡើងដោយកំឡាំងចិត្ត នឹងកំឡាំងកាយមនុស្សក្នុងលោកយើងនេះមានសេចក្តីព្រមព្រៀងគ្នាគិតការមួយយ៉ាងធំ ដែលនាំឲ្យមនុស្សទាំងអស់រួបរួមគ្នាបានមិនថាប្រទេសណា ៗ ទេ តែមិនមែនថាស្រុកទាំងអស់គោងប្រព្រឹត្តដូចគ្នានោះក៏ទេ ពីព្រោះស្រុកនីមួយ ៗ ធ្វើឬគិតការអ្វី ៗ ទៅតាមវិជ្ជាការរបស់ខ្លួន តែថានគរទាំងអស់មានសេចក្តីប្រាថ្នាចំពោះតែសេចក្តីសុខក្សេមក្សាន្តមួយមុខ ហេតុនេះហើយបានជានៅលើជញ្ជាំងសារមន្ទីររចនាបែបសម័យថ្មីមួយ គេមានសរសេរសេចក្តីទុកថា "មនុស្សទាំងអស់ដែលនៅក្នុងលោកនេះមានចិត្តគិតតែចង់ធ្វើឲ្យប្រទេសទាំងអស់បានសេចក្តីសុខក្សេមក្សាន្តដោយការរួបរួមគំនិតគ្នា" ហើយនៅក្នុងបន្ទប់មួយទៀត គេមើលឃើញសេចក្តីមួយថា សិល្បសាស្ត្រទាំងឡាយនឹងទៅជារបស់សាធារណៈមានដកសំរាប់លោកទាំងមូល ទុកជាមានដំឡៃយ៉ាងណាក៏ដោយ សិល្បសាស្ត្រទាំងនោះលែងចែកដាច់មុខជារបស់សម្រាប់ក្រុមមួយ ៗ ទៀតហើយ" ។

# អំពីបុណ្យតាំងពិពិធភណ្ឌ នៅក្រុងប៉ារីស

កាលពីឆ្នាំ ១៩៣៧ មានបុណ្យតាំងពិពិធភណ្ឌ នៅក្រុងប៉ារីស គេទើបនឹងបានបោះពុម្ពសៀវភៅមួយឈ្មោះ "សេចក្ដីប្ដូរគំនិតរបស់មនុស្ស-លោក" ដើម្បីជាទីរលឹកដល់បុណ្យនោះ ។

នៅទំព័រមុខបង្អស់ មានរៀបរាប់ឈ្មោះអ្នកប្រាជ្ញធំៗនៅក្នុងលោកនេះដែលមានគំនិតប្រហែលៗគ្នា គំនិតអស់នោះពិតមែនតែកើតឡើងក្នុងវេលាខុសគ្នា នឹងមានបែបផ្សេងៗគ្នា តែបានសេចក្ដីតែមួយយ៉ាងគឺ "អ្នកនគរទាំងអស់គ្នាចេះរៀនរាប់អានស្គាល់គ្នាចេះកោតខ្លាច-ស្រឡាញ់គ្នាទៅវិញទៅមក នេះជាហេតុនាំមិនឲ្យកើតសឹកសង្គ្រាមតទៅទៀតឡើយ" ។

មានជនជាតិអាមេរិកាំងមួយនាក់ កាល ព. ស. ២២០០ បានអធិប្បាយថា "ខ្ញុំយល់ថា វេលានេះគួរប្រជុំពួកបណ្ឌិតនឹងពួកអ្នកមានគំនិតល្អគ្រប់ប្រទេសតាំងបង្កើតជាក្រុមមួយហៅថា "សប្បុរិសក្រុម" ។

កាល ព.ស. ២៣៧០ មានអ្នកប្រាជ្ញជាតិអាល្លឺម៉ង់មួយនាក់បានអធិប្បាយថា "គួរឲ្យមនុស្សក្រោមលោកចេះស្គាល់រាប់អានគ្នាទៅវិញទៅមក ក្នុងខណៈនោះសេចក្ដីស្អប់ខ្ពើមគ្នាទៅវិញទៅមកនឹងត្រឡប់ទៅជាមានសាមគ្គីសមគ្គគ្នាទៅវិញ" ។

សេចក្តីរិះគិតអស់នេះបានស្មើគំនិតព្រះសម្មាសម្ពុទ្ធដែលមានសំដែងក្នុងគម្ពីរធម្មបទចងជាគាថា ថា "ស្អប់មិនដែលចាញ់ស្អប់ ស្អប់ចាញ់តែស្រឡាញ់" ។

មានជាតិអង់គ្លេសម្នាក់ កាលពុទ្ធសករាជ ២៣០០ បាននិយាយថា "ត្រូវបង្កើតសមាគមមួយ ដោយប្រមូលពួកនិកាយគ្រប់ប្រទេសទាំងអស់ ដើម្បីនឹងតាក់តែងបង្កើតច្បាប់ទំលាប់ សម្រាប់លោកជាថ្មីមួយឡើង ។

នៅក្នុងសៀវភៅនេះ មានកន្លែងមួយនិយាយពីសេចក្តីចម្រើន ដែលកើតឡើងដោយពួកយុវកុមារទាំងឡាយ គ្រប់ជាតិគ្រប់ប្រទេសបានប្រមូលគ្នា និងនិយាយពីការធ្វើដំណើរទៅកាន់ស្រុកដទៃ នាំឲ្យកើតសតិបញ្ញាច្រើនឡើង គេបានទាំងទាញយកពាក្យអ្នកប្រាជ្ញបារាំងសែសម្នាក់ឈ្មោះ "ម៉ុងតែញ" កើតកាល ព. ស. ២២០០ មកពោលថា ការដើរទៅមើលប្រទេសក្រៅជាប្រយោជន៍នាំឲ្យយើងដឹងគតិ យោមារយាទនិងរបៀបប្រទេសអស់នោះ នាំឲ្យយើងចេះរៀបចំចិត្តគំនិតយើងដើម្បីប្រព្រឹត្តទៅកាន់ជនដទៃ ។

ហេតុនេះបានជានៅប្រទេសទុរុបមានយុវសាលាច្រើនពេញពាស យើងសង្ឃឹមថា នៅស្រុកខ្មែរយើងគង់តែនឹងមានយុវសាលានេះបរិបូណ៌ដូចប្រទេសទុរុបដែរ ។

យើងសព្វថ្ងៃបានស្គាល់ប្រទេសជាច្រើន ព្រមទាំងបណ្ដាក្សត្រនឹងគំនិតរបស់បណ្ដាក្សត្រនៅក្នុងប្រទេសអស់នោះ ដោយយើងបានស្ដាប់ថាសម៉ាស៊ីនច្រៀង បានមើលកុន មើលសៀវភៅ បានស្ដាប់ដំណឹងនានាតាមខ្សែលួសវិទ្យុ តាមរបៀបក្នុងគំនូរនឹងអក្សរសាស្ត្រនាំឲ្យយើងចេះយល់ឃើញដូចលោកមហាចិន្ដកវីនៃប្រទេសឥណ្ឌាឈ្មោះរពិន្ទ្រនាថគោរ ដែលនៅរស់សព្វថ្ងៃនេះថា “គ្មានរបងអ្វីខាំងមិនឲ្យស្រុកបូព៌ាប្រទេសទឹងបច្ចិមប្រទេសមិនឲ្យទៅកាន់គ្នាទៅវិញទៅមកទេ” ។

ពាក្យដែលព្រះពុទ្ធទ្រង់បានសំដែងចំនួន ២៥០០ ឆ្នាំ មកហើយនៅតែថ្មីរហូតមកដល់សព្វថ្ងៃនេះ សេចក្ដីត្រិះរិះរបស់ព្រះអង្គពុំមានចាស់ទៅឡើយ ពីព្រោះពាក្យប្រដៅក្នុងសាសនាព្រះអង្គទាំងប៉ុន្មានសុទ្ធតែជាពាក្យពិតហើយស្ថិតស្ថេរចិរកាលផង សំរាប់ឲ្យសត្វលោកក្នុងវដ្ដសង្សារនេះប្រព្រឹត្តតាមកល់ពេលកល់វេលាបាន ។

ព្រះមហាវិហារពុទ្ធគយា

ព្រះមហាពិទូរ ក្រសេម គន្ថរបនបណ្ឌិត

ប្រែនិងរៀបរៀង

# ព្រះមហាវិហារពុទ្ធគយាក្នុងឥណ្ឌា

(ប្រែចេញពីសៀវភៅពុទ្ធសាសនាសៀមភាគទី ២ ខែវិច្ឆិកម ២៤៨១

ដែលប្រែចេញពីទស្សនាវដ្ដីមហាពោធិ ១ ត មកទៀត)

បណ្ដាសាសនាធំៗក្នុងលោកនេះ មាន៤ សាសនាផងគ្នា គឺសាសនាព្រាហ្មណ៍, សាសនាពុទ្ធ, សាសនាគ្រិស្ត, សាសនាមហាម៉ុត ។ សាសនាព្រាហ្មណ៍ នឹងសាសនាពុទ្ធ ជាសាសនារបស់ជនជាតិអារ្យ៉ន, ចំណែកឯសាសនាគ្រិស្តនឹងសាសនាមហាម៉ុត ជាសាសនារបស់ជនជាតិសេមីតិក (Semetic) ទីកំណើតរបស់សាសនាព្រាហ្មណ៍នឹងសាសនាពុទ្ធ នោះនៅក្នុងប្រទេសឥណ្ឌា, ទីកំណើតរបស់សាសនាគ្រិស្តនឹងសាសនាមហាម៉ុតនៅត្រើយខាងលិចរបស់ទ្វីបអាស៊ី ។

សាសនាព្រាហ្មណ៍នោះ ចំណែកចេញជាពីរនិកាយ គឺនិកាយ «សៃវៈ» កប់អានព្រះសិវៈ, នឹងនិកាយ «វិស្ណុ» កប់អានព្រះវិស្ណុ, ពារាណសី ឬដែលហៅក្នុងកាលឥឡូវនេះថា «បេនណារេស» នោះជាស្ថានទីដ៏សក្តិសិទ្ធិ សម្រាប់ពួកឥណ្ឌានិកាយសៃវៈ, របស់ពួកនិកាយវិស្ណុ នោះនៅស្រុក «មធុក» ឬបរិណ្ដាវ័ន ស៊ីងនៅក្នុងប្រទេសឥណ្ឌាប៉ែកខាងត្បូង ។ ពួកឥណ្ឌាដោយច្រើន តែងនាំគ្នាទៅថ្វាយបិណ្ឌៈ នឹងធ្វើបុណ្យទានទៅស្រុកគយា ។ ពួកមហាម៉ុតក៏នាំគ្នាដើរផ្ទាល់ព្រះពាចបសគ្គ ផ្សេងៗ ក្នុងទន្លេខ្សាច់ ទៅនមស្ការនៅស្រុក «មេកៈ» ដែលជាស្រុក

កំណើតរបស់ព្រះមហាម៉ុត ។ ពួកគ្រិស្ដ៍ននាំគ្នាទៅនមស្ការឯស្រុក « យេរុសាលេម » ដែលជាស្រុកកំណើតយេស៊ូគ្រិស្ដ សិនជាទីគោរព បូជារបស់គេ ។

ចំណែកឯពុទ្ធសាសនិកជន ក៏មានបូជនីយស្ថាន ៤ តំបន់ ដែលទាក់ទាមដោយរឿងពុទ្ធប្រវត្តិ គឺ ១ ទីប្រសូត ២ ទីត្រាស់ដឹង ៣ ទីសំដែងព្រះធម្មចក្រ ៤ ទីពុទ្ធបរិនិព្វាន ។ ទីប្រសូតនោះក៏គឺសួនលុម្ពិនី ស្ថិតនៅក្នុងប្រទេសនេប៉ាល់ជិតជួរភ្នំហិមពាន្ត, ទីត្រាស់ដឹងក៏គឺពុទ្ធគយា, ទីសំ-ដែងព្រះធម្មចក្រដល់បញ្ចវគ្គិយទាំង ៥ ក៏គឺព្រៃឥសិបតនមិគទាយវ័នប្ ដែលហៅថា សារនាថ ក្នុងកាលឥឡូវនេះ, ទីនទីដែលព្រះអង្គបរិនិព្វាន គឺកុសិនាក ស្ថិតនៅជិតស្រុកគោរក្ខបុរៈ សម្រាប់នមស្ការបូជាតាមទំនៀម ។

កាលគ្រាព្រះអង្គគង់នៅ បានត្រាស់នឹងសាវកទាំងឡាយទាំងបព្វជិតទាំងឡាយថា អ្នកដែលមានចិត្តជ្រះថ្លាសទ្ធាទៅនមស្ការបូជនីយស្ថានដ៏សក្តិសិទ្ធិ៍ទាំង ៤ អន្លើនេះ ពិចារណាឲ្យកើតធម្មសង្វេគហើយ ក្រោយដែលស្លាប់ទៅនឹងបាននៅកើតក្នុងសុគតិ [1] ។ បូជនីយ-ស្ថានអំបាលនេះ គេបានស្រាវជ្រាវកេះឃើញជាការពិតប្រាកដអស់ហើយ អ្នកប្រាថ្នានឹងនមស្ការអាចនឹងទៅនមស្ការបានដោយងាយ ។

ដើមព្រះស្រីមហាពោធិព្រឹក្ស ជាស្ថានទីដែលព្រះអង្គត្រាស់ដឹង

---

១ មើលមហាបរិនិព្វានសូត្រ ។

ចាត់ជាស្ថានដ៏សក្តិសិទ្ធិ៍ សំខាន់ សម្រាប់ពុទ្ធបរិសទ្យទាំងឡាយនឹងនមស្សការបូជា ៖ រាប់វេលាតាំងអំពី ២៤០០ ឆ្នាំដែលកន្លងមក មានពួកពុទ្ធមាមកៈពល់ៗ មណ្ឌលនៃលោក បាននាំគ្នាដើរផ្លូវទៅនមស្សការជាញយៗ ពុំដែលដាច់ៗ ក្នុងរជ្ជសម័យនៃព្រះបាទធម្មាសោករាជ ព្រះមហាពោធិព្រឹក្សនេះបានត្រូវផ្សាំយកទៅដាំ នៅក្រុងអនុរាធបុរៈក្នុងលង្កាទ្វីប ដោយសេចក្តីចាត់ចែងរបស់ព្រះភិក្ខុនី សង្ឃមិត្តា ដែលជាព្រះរាជធីតារបស់ព្រះអង្គនឹងជាអ្នកដែលបានតាំងភិក្ខុនីសង្ឃ ទុកនៅលង្កាទ្វីបកាលប្រមាណ ២២២២ ឆ្នាំដែលហើយមកៗ ព្រះបាទធម្មាសោករាជបានទ្រង់សាងចម្រឹងថ្មជុំវិញព្រះវិហារនោះ ជាអនុស្សាវរីយគ្រឿងសំគាល់នៃសេចក្តីរលឹក ក្នុងកាលដែលស្តេចបានយាងទៅនមស្សការដើមព្រះមហាពោធិព្រឹក្ស ដែលនាយហ្វើរគស្សុនកត់ក្នុងសៀវភៅ “ប្រវត្តិសាស្ត្រការកសាងរបស់ពួកឥណ្ឌា” ទំព័រ ៨៦ គេបានសរសេរទុកថា “ជាថាវរត្ថ ដែលមានចម្លាក់ក្បាច់រចនាសឹងជាស្នាដៃចាស់បំផុតក្នុងប្រទេសឥណ្ឌា” ។ អ្នកដំណើរចិនឈ្មោះ “ហ្យួនទាង” បានបរិយាយរឿងទុកយ៉ាងច្បាស់លាស់ ក្នុងសៀវភៅរាយការដើរផ្លូវរបស់គេ អំពីសភាពនិងហេតុការផ្សេងៗ ដែលគេបានឃើញនៅពុទ្ធគយា, ទាំងបានសរសេរសរសើរដល់លំអរបស់ព្រះវិហារកាលសម័យ ១២០០ ឆ្នាំដែលហើយមកផង (៦៨០A.C.) ព្រះរាជាក្រុងភូមាបានទ្រង់ជួសជុល

ព្រះវិហារនោះក្នុងឆ្នាំ គ.ស. ១២០០ ខាងក្រោយដែលព្រះពុទ្ធសាសនាក្នុងមណ្ឌលពិហារ បានត្រូវវិនាសបំផ្លាញបង់ ដោយស្នាដៃស្តេចរបស់ពួកមហាម៉ុត នាមព័ក្តបិយារខិលយ៍ក្នុងឆ្នាំគ.ស.១២០០ អ្នកសរសេរដើទ្រង់ទ្រូវសេចក្តីនេះដឹង មានសេចក្តីយល់ឃើញថា "សេចក្តីអប្បរុទព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌានោះ ដោយហេតុត្រូវរុករានទន្ទ្រានដ៏កំណាចរបស់ពួកមហាម៉ុតៗ ដ.រ.កិដន បានសរសេរក្នុងសៀវភៅ "សិក្សាសាសនាក្នុងប្រទេសបូព៌ា" ទុកថា "ការរុករានរបស់ពួកមហាម៉ុតចូលទៅប្រទេសឥណ្ឌាក្នុងសតវត្សរ៍ទី១១ គ្រានោះពេញទៅដោយការចំបាំងកាប់សម្លាប់គ្នាឥតល្ហែក ហើយក្នុងវេលាព្រមគ្នានោះសង្គ្រាមដើម្បីសាសនាយ៉ាងក្រពុលមុខក៏ផ្សាយខ្លួនទៅក្នុងដែនឥណ្ឌាភាគខាងលើ ៗ ព្រះពុទ្ធ-សាសនាទើបរៀវរោយចុះ ៗ ការជួសជុលព្រះវិហារក្នុងគ្រាក្រោយ ដោយព្រះបាទមិនដុនបានបញ្ជូនដាំងរបស់ព្រះអង្គទៅត្រួតត្រាមើលការជួសជុល តែដោយហេតុការសុគតរបស់ព្រះអង្គដោយបច្ចុប្បន្នទាន់ហន់ ទើងការខូចព្រះរាជាណាចក្រទាំងអស់ដល់អង់គ្លេសក្នុងឆ្នាំ គ.ស. ១៨៨៥ សេចក្តីប៉ុនប៉ងដែលនឹងគិតជួសជុលព្រះវិហារ ក៏ព្យួរសូន្យទៅផង ៗ តែមកដល់ក្នុងឆ្នាំ គ.ស. ១៨៨០ រាជការអង់គ្លេសក៏បានជួសជុលឡើងជាថ្មីម្តងទៀត ដូចបានប្រាកដដែលយើងឃើញក្នុងកាលសព្វថ្ងៃនេះ ៗ

ក្នុងចុងឆ្នាំ គ.ស. ១៨៩០ ស៊ើរគ្រៀសាន់ គោលឡិកត័រ នៃស្រុកគយា បានឃើញសភាពដ៏ទ្រុឌទ្រោមប្រាសចាកអ្នកយកចិត្តទុកដាក់មើលថែទាំ ទើបបានប្ដឹងទៅរដ្ឋការអង់គ្លេស សូមបញ្ជូនព្រះវិហារនោះឲ្យនៅក្នុងស្ដេចមើលថែទាំរបស់ក្រុមជួសជុលបុរាណវត្ថុ ក្នុងប្រទេសឥណ្ឌា ហេតុការទាំងនេះ បានកើតឡើងក្នុងដើមឆ្នាំ គ.ស. ១៨៩១ ។

ក្នុងខែយ៉ាំងវីយេរ គ.ស. ១៨៩១ លោកអនាគារិកធម្មបាលបានដើរផ្លូវទៅនមស្ការស្ថានទីដ៏សក្ដិសិទ្ធិនេះ កាលលោកឃើញសភាពបាក់បែកនៃព្រះវិហារក៏កើតសេចក្ដីសង្វេគស្លុតចិត្តជាច្រើន លោកបានសម្រេចក្នុងចិត្តថា នឹងនៅក្នុងទីនោះ ដើម្បីនឹងរក្សាថែទាំព្រះវិហារហើយនឹងដឹកនាំភិក្ខុក្នុងប្រទេសផ្សេង ៗ មកនៅផងក្នុងឆ្នាំ គ.ស. ១៨៧៣ ស្ដេចភូមាបានបញ្ជូនពេជ្រទីលបិន្ទាទៅថ្វាយជាគ្រឿងសក្ការបូជាព្រះស្រីមហាពោធិព្រឹក្ស ព្រមដោយរបស់ដ៏មានដំឡៃជាច្រើនយ៉ាង ទៅប្រទានជាផ្ញើន់ដល់មហន្ត ដែលមាននាមថា "ហេមនារាយណគិរិ" ធង់, ព្រះអង្គបានធ្វើសេចក្ដីព្រមព្រៀងចុះសម្រុងនឹងពួកមហន្តថា "ត្រូវអនុញ្ញាតឲ្យភិក្ខុសង្ឃក្នុងពុទ្ធសាសនាទៅនៅប្រចាំក្នុងទីពុទ្ធគយា បានជានិច្ច ក្រោយដែលបានធ្វើសេចក្ដីចុះសម្រុងគ្នាហើយ ភូមាបានសាងមន្ទីរឃ្លាំងជាទីទុកដាក់គ្រឿងសក្ការបូជាដ៏មានដំឡៃ ដែលស្ដេចភូមាថ្វាយព្រះស្រីមហាពោធិព្រឹក្ស និងសាងវត្តជាទីសម្រាប់ភិក្ខុសង្ឃអាស្រ័យនៅផង ។

តែទាំងខាងកងការទាំងខាងពួកមហន្ត មិនបានយកចិត្តទុកមើលថែទាំព្រះវិហារនោះឡើយ ទាល់តែដល់គ្រាសាន់ បានប្ដឹងទៅដល់កងការ ៗ ពួកភិក្ខុលង្កាបានអាស្រ័យក្នុងវត្តភូមា (នៅពុទ្ធគយា) ដែលភូមាសាងឡើងនោះ គ្រាដំបូងតាំងពីខែជូយែត គ.ស. ១៨៩១ ដល់ខែហ្វេវ្រីយេរ គ.ស. ១៨៩៣ លើកទីពីរ តាំងពីខែហ្វេវ្រីយេរ គ.ស. ១៨៩៥ ដល់ខែហ្វេវ្រីយេរ គ.ស.១៩១០ ដ៏ជាខែដែលពួកភិក្ខុអំបាលនោះ ត្រូវបង្គាប់ឲ្យចេញចាកបរិវេណស្ថានទីពុទ្ធគយា ដោយសារដីការបស់សាលាជាន់ខ្ពស់នៃស្រុកបង្កាល ។

ពួកពុទ្ធសាសនិកជន ដែលអាស្រ័យពុទ្ធគយាក្នុងវេលានោះមិនដែលធ្វើសេចក្ដីក្ដៅក្រហាយដល់អ្នកឯណាទីមួយឡើយ ក្នុងឆ្នាំ គ.ស. ១៩០២ យ៉ីពុនម្នាក់ឈ្មោះឧកាគុរៈ ព្រមដោយស្វាមី វិវេកានន្ទនិងនាងនិវេទិត បានដើរផ្លូវទៅមើលស្ថានទីពុទ្ធគយា ហើយបានធ្វើការប្រជុំនឹងពួកមហន្ត និយាយអំពីលំនៀងនឹងតាំងសាលាសមាគមឥណ្ឌូ-យ៉ីពុន ឡើងនៅពុទ្ធគយា. រដ្ឋបាលបានលុបដឹងដំណឹងនោះភ្លាម, ហេតុនោះក្នុងឆ្នាំ គ. ស. ១៩០៦ ក្រមការស្រុកប៉េតនា ទើបមានបង្គាប់ទៅពួកមហន្ត ឲ្យនាំសេចក្ដីឡើងប្ដឹងអំពីពុទ្ធសមាគមនៅពុទ្ធគយា (សមាគមដែលលោកធម្មបាលបានសាងឡើង) ដើម្បីនឹងបានដេញពុទ្ធ-សាសនិកជនឲ្យឃ្លាតឆ្ងាយចេញអំពីស្ថានដ៏សក្ដិសិទ្ធិឲ្យអស់ទៅ សេចក្ដី

ពិត រឿងនេះ មិនមែនជាហេតុដែលរដ្ឋបាលនឹងគប្បីសន្ទិះសង្ស័យឡើយ តែដួបដួនវេលានោះរដ្ឋបាលឥណ្ឌៀសង្ស័យក្នុងសេចក្ដីយកចិត្តទុកដាក់ក្នុងការរំគាយនយោបាយរបស់ពួកយ៉ីពុនដែលនៅក្នុងឥណ្ឌៀ ដោយច្រើនហេតុនោះកាលបានឮដំណឹងយ៉ីពុននឹងបើកសមាគមឥណ្ឌៀ - យ៉ីពុនរែកទីរិទីនៅពុទ្ធគយាផងហើយ ក៏រឹតតែធ្វើឲ្យរដ្ឋបាលសង្ស័យ ព្រួយបារម្ភណាស់ឡើង ទើបមិនអាចនឹងទ្រាំមើលការដែលយ៉ីពុនធ្វើតទៅទៀតបាន ក្នុងទីបំផុតក៏គឺពួកមហន្តបានត្រូវបង្ខំចិត្តឲ្យចាប់រឿងប្ដឹងតវ៉ា ដល់សាលាជំនុំ ដោយសេចក្ដីបំណងនឹងបរពួកពុទ្ធបរិស័ទ ឲ្យចេញចាកពុទ្ធគយាទាល់តែអស់ សេចក្ដីបានដំណើរទៅតាំងអំពីឆ្នាំ គ.ស. ១៩០៧ រហូតដល់ខែហ្វេរិយេរ គ.ស. ១៩១០ ផលក្នុងទីបំផុតពុទ្ធសមាគមរបស់លោកធម្មបាលក៏តោងចាលចាញ់ ហើយនឹងត្រូវចេញចាកទីត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធនៃខ្លួន ដោយសេចក្ដីទើសទាល់ព្រោះហេតុការនៃស្រុកទេស តាំងអំពីនោះមក គ្មានពុទ្ធសាសនិកជនរូបណានឹងទៅសំណាក់អាស្រ័យនៅ ៗ ពុទ្ធគយាបានឋិតថេរឡើយ ។

ក្រោយអំពីសង្គ្រាមសាសនាកើតឡើង ទីសក្ដិសិទ្ធិ គឺយេរុសាលេមបានធ្លាក់ទៅក្នុងកណ្ដាប់ដៃពួកមហាម៉ាត់ ទោះបីដូច្នោះ ពួកគ្រិស្ដាំងពល់ ៗ និកាយ ក៏នូវបានអនុញ្ញាតឲ្យអាស្រ័យនៅ ៗ ទីយេរុសាលេមទាំងមានអំណាចសាងវត្តវិហារបានតាមលទ្ធិរបស់ខ្លួន ដោយមិនមាន

ទើសទែងអ្វីឡើយអំពីពួកមហាម៉ាត់, តែការមើលថែទាំទីនោះធ្លាក់ទៅក្នុងកណ្ដាប់ដៃពួកគេ ដើម្បីនឹងចៀសចាកការឈ្លោះវិវាទ ដែលអាចនឹងកើតមានឡើងនោះ រដ្ឋបាលមហាម៉ាត់ក៏សំដែងទឹកចិត្តអើពើដល់គណៈគ្រិស្ដាំង ដោយអនុញ្ញាតឲ្យនៅនឹងសាងវត្តវិហារបានតាមគាប់ចិត្ត ចំណែកឯពួកគ្រិស្ដាំងក៏មានចិត្តសន្តោសតាមនោះ ហើយនឹងពេញចិត្តក្នុងការអើពើនោះពន់ប្រមាណ រដ្ឋបាលមុសលេមឲ្យអំណាចដ៏តាប់តាមគន្លងធម៌ដល់ពួកគ្រិស្ដាំង ទោះបីទីយេរុសាលេមធ្លាក់ទៅក្នុងកណ្ដាប់ដៃគេក៏ដោយ គេនៅអើពើដល់ម្ល៉េះ តែរដ្ឋបាលអង់គ្លេស បដិសេធការធ្វើជុំប្ចោះដល់ពួកពុទ្ធសាសនិកជនក្នុងឥណ្ឌា ប្រហែលជារដ្ឋបាលអង់គ្លេសមានក្ដីបារម្ភទៅថា ពួកយីពុននឹងកាន់យកពុទ្ធគយា ទុកជាទីផ្សាយការស្រុកទេសរបស់ខ្លួនក្នុងឥណ្ឌា, ដើម្បីការពារខ្លួន ឲ្យផុតចាកការស្រុកទេសដ៏ស្មុកស្មាញដូចពោលមកនេះ រដ្ឋបាលអង់គ្លេសទើបគិតថា ការដែលនឹងបិទទ្វារមិនឲ្យពួកយីពុនទៅធ្វើមុកឡុកនៅទីពុទ្ធគយាពេញជាស្រួល ហើយក៏បិទមែនតាមដែលគិតនោះ ។

ការដែលរដ្ឋបាលអង់គ្លេសធ្វើដូច្នេះ មិនបានឲ្យសេចក្ដីយុត្តិធម៌ដល់បណ្ដាប្រជារាស្ត្ររបស់ខ្លួនដែលកាប់កានព្រះពុទ្ធសាសនាឡើយ ដ្បិតក្នុងប្រទេសភូមា អារ៉ាកាន ចិត្តកុង នឹងស៊ិកកិម មានអ្នកស្រុកដែលកាប់អាន

ព្រះពុទ្ធសាសនាប្រមាណ ១២ លាននាក់ ក្នុងលង្កាមានប្រមាណ ២ លាននាក់អំពាលនេះសុទ្ធតែជាពស្ត្ររបស់អាណាចក្រអង់គ្លេសដោយត្រង់ ។

✓ សង្គ្រាមលោកដែលហើយមកនោះ បានធ្វើឲ្យការស្រុកទេសរបស់លោកប្រែប្រួលទៅជាច្រើន សេចក្តីខ្លាចការរុករានរបស់អាល័ម៉ង់ក៏ថយទៅ យេរុសាលេមក៏ត្រឡប់បានមកនៅក្នុងអំណាចរបស់ពួកគ្រិស្តាំងត៍ដូចដើម ពួកយីពុនអ្នកដែលត្រូវសង្ស័យមកអំពីមុន ក៏ត្រឡប់ក្លាយជាមិត្រនឹងពួកអង់គ្លេស ហើយបានអំណាចអំពីអង់គ្លេសឲ្យជាអ្នកមើលថែទាំមហាសមុទ្រឥណ្ឌា សេចក្តីឧបការជួយជ្រោមដែនផ្សេងៗ ដែលពួកយីពុនសំដែងឲ្យប្រាកដដល់អង់គ្លេសក្នុងកាលសង្គ្រាមលោកនោះធ្វើឲ្យពួកអង់គ្លេសឃើញចិត្តនឹងអំណរគុណបុណ្យយីពុនជាច្រើន ។

យេរុសាលេមដែលបាត់ទៅយូរណាស់ហើយ ក៏ត្រឡប់មកនៅក្នុងដៃពួកគ្រិស្តាំងត៍តាមដើមវិញ មេកះក៏នៅក្នុងអំណាចរបស់មហាម៉ាត់ បេនណារេស (ពារាណសី) នឹងពុទ្ធគយាក៏នៅក្នុងសេចក្តីគ្រប់គ្រងរបស់ពួកសៃវៈ នឹងពួកវិស្ណុ ៗ ចំណែកតែពុទ្ធគយារបស់យើងប៉ុណ្ណោះដែលនៅក្នុងកណ្តាប់ដៃរបស់ពួកអ្នកកាន់សាសនា សឹងត្រូវគេបោះបង់ចោល ដោយឥតអ្នកណាយកចិត្តទុកដាក់មើលថែទាំ កំពុងតែត្រូវពួកបរិវារនៃសៃវៈ មហន្តធ្វើឲ្យថោកទាបកិត្តិយស ម្តេចពួកយើងក៏ព្រមឲ្យគេធ្វើផ្តេសផ្តាសយ៉ាងព្រៃផ្សៃដូច្នេះ , ពួកមហាម៉ាត់គេសុខចិត្តឲ្យពួកគ្រិស្តាំងត៍សាងវត្តវិហារ

ទីងអាស្រ័យនៅក្នុងស្រុកយេរុសាលេម តាមសេចក្ដីគាប់ចិត្តរបស់ខ្លួន តែបែរមកមើលខាងពួកយើង ឲ្យកើតសេចក្ដីស្លុតចិត្តជាបំផុតដែលមិនបាន ទទួលសេចក្ដីមេត្តាករុណា និងសេចក្ដីយុត្តិធម៌ដូចគេ ។

ពួកសាសនិកជននៅទីនោះមានចំនួនតិច ទើបជាហេតុឲ្យខ្សោយ ជាធម្មតា ហេតុនោះទើបថាមុខងារនៃរដ្ឋបាល ដែលនឹងគប្បីពិនិត្យមើល ឲ្យដឹងថា គេអំបាលនោះជាត្រូវអ្នកឯណានីមួយកំហែងបៀតបៀនឬទេ? បើ ជាមិនហៅថាត្រូវកំហែងដោយត្រង់ៗហើយតើនឹងហៅថាអ្វីទៅវិញ ដែល បណ្ដាសាសនិកជនមិនបានទទួលអនុញ្ញាតឲ្យសំណាក់អាស្រ័យនៅទីពុទ្ធ-គយាសិងជាបូជនីយស្ថានដ៏សក្ដិសិទ្ធិរបស់គេ? ។

រឿងរ៉ាវផ្សេងៗ នៃព្រះវិហារដ៏មានមកដោយលំដាប់ដរាបដល់សព្វ ថ្ងៃនេះ រមែងធ្វើឲ្យពុទ្ធគយាទៅជាស្ថានដ៏សំខាន់ក្រៃពេក សម្រាប់ពួក ពុទ្ធបរិសទ្យទូទៅក្នុងលោក ព្រះពុទ្ធមេត្តេយ្យ ដែលជាអ្នកដំណពុទ្ធវង្ស នៃព្រះគោតមនឹងស្ដេចមកត្រាស់ដឹងនៅទីពុទ្ធគយាទៀតដែរ ពុទ្ធសាស-និកជនទាំងឡាយជឿថា ព្រះពុទ្ធគ្រប់ៗ អង្គក្នុងអតីតកាល និងព្រះពុទ្ធ គោតមរបស់យើងក្នុងបច្ចុប្បន្ននោះ សុទ្ធតែទ្រង់មកត្រាស់នៅទីពុទ្ធគយា ទាំងអស់ ហេតុនោះពុទ្ធគយាទើបជាស្ថានដ៏សក្ដិសិទ្ធិរបស់ពុទ្ធបរិសទ្យ ទាំងឡាយនៅរហូតនិរន្តកាល ។

ដើមព្រះមហាពោធិដែលត្រូវផ្សាំអំពីដើមនៅពុទ្ធគយា ហើយនាំយកទៅដាំនៅអនុរាធបុរៈក្នុងកោះលង្កានោះ នៅល្អបរិបូណ៌ដរាបដល់សព្វថ្ងៃនេះ មាននមនុស្សទៅនមស្សការយ៉ាងពោរពេស ៈនោះត្រឹមតែមែកដែលបំបែកទៅ ក៏នៅមានមនុស្សសំដែងសេចក្ដីគោរពដល់ម្ល៉េះទៅហើយ បើប្រែះលើដើម ៗ នោះ សេចក្ដីគោរពរាប់អានរបស់គេតែងនឹងទ្វេឡើងប៉ុន្មានទៅ ខ្ញុំមិនបាច់អធិប្បាយ លោកអ្នកទាំងឡាយគង់ជ្រាបបានជាប្រាកដ ; ព្រះបាទសិរិមេឃាវរាម ជាព្រះរាជានៃកោះលង្កា បានទ្រង់សាងសង្ឃារាម ១ ខ្ពង់ទុកនៅពុទ្ធគយា សឹងប្រាកដថា គង់នៅរុងរឿងឋិតថេរដរាបមកដល់វេលាដែលអ្នកចារិក (អ្នកដំណើរ) ចិនម្នាក់បានដើរទៅដល់ស្ថានដ៏សក្ដិសិទ្ធិនោះ ព្រះពុទ្ធឃោសាចារ្យដែលយើងអាចឲ្យឈ្មោះបានថា ជាអ្នកជ្រោមជ្រួយព្រះពុទ្ធសាសនាឡើងក្នុងសម័យកណ្ដាល ក៏បានដើរផ្លូវទៅលង្កាអំពីពុទ្ធគយានោះឯង ។

ពួកឥណ្ឌូមហន្តអាចអាងថាទីដីត្រង់ដែលសាងព្រះវិហារនោះ ជារបស់គេ ឯពុទ្ធសាសនិកជន ដែលមានចំនួនទាំង ៤៧៨ លាននាក់ក្នុងលោកនេះ ហេតុម្ដេចទើបមិនបានទទួលមរតក ដែលផ្ទេរមកអំពីបុព្វបុរសរបស់ខ្លួន កាលមុននោះយេរុសាលេមបានធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃពួកមហាម៉ាត់ តែវេលានេះ ពួកអង់គ្លេសបានដណ្ដើមយកមកវិញ ហើយតទៅយើងមិនគោងសង្ស័យថា ពួកអង់គ្លេសនឹងបណ្ដោយឲ្យ

យេរុសាលេមឲ្យធ្លាក់ទៅក្នុងកណ្ដាប់ដៃពួកមហាម៉ាត់ទៀត ពុទ្ធគយាជាស្ថានដ៏សក្តិសិទ្ធិសម្រាប់ពុទ្ធសាសនិកជនក្រៃលែងនោះទាំង ៣ គាត់ទៅទៀត បើនិយាយតាមផ្លូវយុត្តិធម៌ និងផ្លូវមេត្តាករុណាដ៏ស្មោះហើយ ពុទ្ធគយាសមគួរត្រឡប់បានមកជារបស់ពុទ្ធសាសនិកជន ដែលជាម្ចាស់ដើមវិញដោយពិតប្រាកដ បិតាប៉ុណ្ណោះដែលអាចដឹងបន្ទុកសេចក្តីស្រឡាញ់របស់ខ្លួនដែលមានដល់បុត្រ បុត្រប៉ុណ្ណោះដែលអាចដឹងបន្ទុកសេចក្តីស្រឡាញ់របស់ខ្លួនដែលមានដល់បិតា, ម្តាយចិញ្ចឹមមិនអាចដឹងបន្ទុក ឬសំដែងសេចក្តីស្រឡាញ់ស្មោះរបស់ខ្លួនដូចយ៉ាងមាតាបង្កើតបានឡើយ ពួកមហន្តដែលជានិកាយសៃវៈនិងជាសិស្សរបស់សង្កាចារ្យមើលទៅមិនមានថ្ងៃដែលនឹងស្រឡាញ់ពុទ្ធសាសនាត្រាំទៅក្នុងដួងចិត្តរបស់គេទេ កាលមហាសង្គ្រាមលោកដែលហើយមក ពុទ្ធសាសនិកជនរហូតដល់ជាតិទីបេតនៅខាងអង់គ្លេសនាំគ្នាជួយជ្រោមជ្រែងរដ្ឋបាល ទាំងមនុស្សទាំងទ្រព្យសម្បត្តិប្រាក់កាសយ៉ាងពេញបន្ទុក ពួកយើពុទក៏បានក្លាយមកជាមិត្តនឹងអង់គ្លេស ជាការយុត្តិធម៌ហើយ បើព្រះវិហារពុទ្ធគយាត្រឡប់បានមកជាកម្មសិទ្ធិរបស់ពុទ្ធសាសនិកជនវិញ ហើយនៅក្រោមសេចក្តីមើលថែទាំរបស់អង់គ្លេស ។

គំរាជាមពិតក្នុងកោះលង្កា ដែលប្រជាជនរាប់អានថាសក្តិសិទ្ធិនោះ នៅក្នុងសេចក្តីគ្រប់គ្រងថែទាំរបស់ភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ទាំង

ពួកឥណ្ឌូទាំងពួកមហាម៉ាត់ បានទទួលសេចក្ដីបដិសណ្ឋារៈយ៉ាងស្មើភាគ អំពីព្រះភិក្ខុសង្ឃអំបាលនោះ, នៅវត្តព្រះបទុមកែវ (នៅលង្កា) មាន មហាជនមិនរើសជាតិសាសនា អាចចូលទៅនមស្ការបាន ដោយ ប្រាសចាកអន្តរាយឯណានីមួយឡើយ, ពុទ្ធសាសនិកជន ស្រឡាញ់ សាន្តិភាព នឹងមានសេចក្ដីអត់ធ្មត់ជានិច្ច ទោះបីត្រូវគេកំហែងសង្កត់ សង្កិនក៏ដោយ រយៈវេលា ២.៤០០ ឆ្នាំ ព្រះពុទ្ធសាសនាមួយប៉ុណ្ណោះ ដែលបានផ្សាយទូទៅ គ្រប់ច្រកល្ហកក្នុងលោកដោយប្រាសចាកឈាម ស្រក់ សូម្បីមួយដំណក់ឡើយ សាសនាព្រះពុទ្ធជាសាសនាដែលពេញ ទៅដោយសេចក្ដីមេត្តាករុណា សមគួរហើយឬ ដែលវិហារដ៏សក្ដិសិទ្ធិ៍ របស់ព្រះពុទ្ធអង្គដែលជាអ្នកលះបង់យ៉ាងធំ ហើយបានបំពេញទុក្ករ កិរិយាយ៉ាងលំបាកក្រក្រីជាបំផុត អស់វេលា ៦ ឆ្នាំ ដោយសេចក្ដី ប្រាថ្នាដ៏ខ្លាំងក្លាដើម្បីយឹតយោងព្រះអង្គ នឹងស្រោចស្រង់សត្វលោកឲ្យ ផុតអំពីសង្សារវដ្ដ ដាក់ដល់ត្រើយគឺព្រះនិព្វាន ត្រឡប់មកត្រូវពួកសិស្ស ដ៏ឥតប្រាជ្ញារបស់ឥណ្ឌូមហន្ត ធ្វើឲ្យអប្បឱនពសី? ព្រះធម៌ជាច្បាប់គ្រប់ គ្រងលោកនេះ ពួកមហន្តមិនបានគិតទេ នឹងមិនថាជាសេចក្ដីសុចរិតយុត្តិ ធម៌នឹងល្អប៉ុន្មានទេ ដែលពុទ្ធគយាត្រូវធ្លាក់មកនៅក្នុងកម្មសិទ្ធិ៍របស់ម្ចាស់ ដើមវិញតាមគន្លងធម៌, មរតកបិតាត្រូវធ្លាក់ទៅជារបស់កូនប្រុស ហេតុ នោះ ទើបមិនមានបញ្ហាអ្វីឡើយដែលពុទ្ធគយានឹងគួរធ្លាក់ទៅជារបស់

ពុទ្ធសាសនិកជន យើងយល់ថា បើពួកមហាទ្រព្យក្នុងរឿងនេះហើយ ពុទ្ធសាសនិកជនទាំងឡាយនឹងតបស្នងសងគុណគេវិញ ឲ្យយ៉ាងពេញចិត្តតែម្តង ទាំងរដ្ឋបាលអង់គ្លេសក៏មិនគួរនឹងក្រេបសំដែងសេចក្តីមេត្រីដល់ពុទ្ធសាសនិកជន ដោយអំពើដូច្នេះឡើយ កាលនឹងប្រមូលសេចក្តីស្មុតត្រង់ ដោយយុត្តិធម៌កំពុងឈានចូលមកហើយ យើងទាំងឡាយកំពុងទន្ទេញដោយសេចក្តីគោរពយ៉ាងខ្ពស់ថា "ពុទ្ធគយានឹងធ្លាក់មកជាសម្បត្តិរបស់យើងក្នុងមិនយូរនោះឯង សមាគមមហាពោធិក្នុងឥណ្ឌា
✓ បានព្យាយាមធ្វើការតវ៉ាមកហើយកប់វេលាជាច្រើនឆ្នាំ ដោយសេចក្តីបំណងដែលនឹងចូលទៅកាន់យកកម្មសិទ្ធិរបស់ព្រះវិហារត្រឡប់មកវិញឲ្យបាន, ប្រាក់ជាច្រើនបានចាត់ចាយទៅក្នុងការតវ៉ានេះ ហើយកំពុងតែចាត់តថែមទៀតរឿយ ៗ មកដរាបដល់សព្វថ្ងៃនេះ ។

# ប្រជុំពាក្យកាព្យ

## ភាគទី ២

## ជារបស់ផ្សេងអោបហារគ្នា

(តទី ៦)

៙ អនិច្ចាចិត្តអើយអីដល់ម្ល៉េះ
ដូច្នេះដីតែឃើញជាក្ស័យ
ព្រោះដ្យិតសង្ខារសែនសង្ស័យ
កែវថ្លៃចូរស្លាប់បង់ថ្លៃទុក្ខ ។
៙ ឮផ្គរហើយថែមទាំងភ្លៀងធំ
ខកក្រៀមក្រំសមសៀតចុក
ព្រោះស្មានដោយខ្លួនមិនជួនមុខ
កើតទុក្ខរកអ្វីប្រៀបពុំបាន ។
៙ នេះគឺជាកម្មផងខ្លួនហើយ
កែវអើយដូចក្នុងសន្តត់ប្រាណ
ទ្រូងទ្រាំផ្សាជាំមិនស្រាកស្រាន្ត
មិនមានល្ហែល្ហើយក្ដីខ្វល់ខ្វាយ ។
៙ តាកព្រាងប្រុះធ្លុះវេហាស៍
អស់ទាំងមនុស្សម្នាសុខក្នុងកាយ
ព្រាត់គ្នាជួបគ្នាគេសប្បាយ
តែប្រាណឯកាយឯកោនៅ ។
៙ កំព្រាវេទនាសែនរំខាន
ហើយថែមទាំងមានសេចក្ដីក្ដៅ

ម៉ោងប្រាំមួយចិត្តព្រួយព្រោះទឹកទៅ
ឱជ្ងាំតែណោះនៅប្តីទៅឯណា ៗ

៙ ចិត្តនឹករឭកមិនមានភ្លេច
ចង់ដឹងកលកិច្ចពីស្ងួនភ្ងា
នឹករៀមប្តីស្ងៀមប្តីចរចា
ប្តីមួយមានគ្នាទឹងសាសង ៗ

៙ អនិច្ចាខ្លួនបងដូចសមុទ្រ
មៀងមើលងងឹតមិនយល់ត្រើយ
ព្រាត់មួយឆ្នាំជួបមួយថ្ងៃព្រាត់វិញហើយ
ម៉េះសមកន្តើយបងអសារ . . . . . . .

. . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . .

ស៊ុមនោមៃ (ប៉ែន)

ពាក្យកាព្យបទនេះមានច្រើនទៅទៀត ចាំបានតែប៉ុណ្ណោះ នាំយកមកបោះពុម្ពដើម្បីរក្សាសំនួនទុក ៗ

៙ ផ្កាអើយ ៗ ផ្កាផ្កាបុប្ផាព្រៃ
រីកប៉ប្រៃប្ញុកប៉ប្រិមញញឹមស្រស់
ជូនព្រះពាយរាយរាកមកស្រណោះ

មិនដឹងសោះគិតម្តេចម្តាប្រាប់ផល់ ។

៙ ជួបជួនអរុណរៀងរពីបុព្វៃ
ក្នុងមាល័យមាលាលាតក៏ទាបសល់
ជូនដំនោរទៅព្រះពាយរំភាយរល់
សែនស្រងល់សល់ស្រងាត់បាត់ស្មារតី ។

៙ ផ្កុលអើយ ៗ ផ្កុលផ្កាបុប្ផាព្រឹក្ស
ចិត្តពេកនឹករលេញមិនចេញស្តី
អត់សង្កត់ទៅជាខ្វល់បែកពីរបី
នឹងស្រដីក្រែងពុំបានដូចប្រាថ្នា ។

៙ តែងពេកនឹករលែកដេកមិនលក់
សែនវិតក្កអផ្សុកបុកក្នុងឧរា
នេត្រលង់ប្រុងពេកនឹកផ្កុលផ្កា
នឹងថ្លែងថាឲ្យបានសុខនឹងទុក្ខខ្វល់ ។

មិនស្គាល់ឈ្មោះ ។

៙ សារលិខិតនឹកខឹងចិត្តលិខិតសារ
ចិន្តាស្មានហើយមិនបានដូចចិន្តា
មួម៉ងសៅក្តៅឯកសែនមួម៉ង
សោកសែនទ្វីស៊ីទឹកនេត្រដោយសែនសោក ។

៙ បងឃ្លាតប្អូនទួនវិយោគដោយឃ្លាតបង
កន្ទង់ឆ្នាំត្រងចាំកាយឆ្ងាយកន្ទង់
ចិត្តគិតនួនល្អងគ្មានល្មៀងទៀងទឹកចិត្ត
សព្វថ្ងៃក្តួលអួលក្តៅចិត្តសៅសព្វថ្ងៃ ៗ

៙ គិតអាល័យថ្ងៃគ្មានក្លេបអាល័យគិត
ស្និទ្ធស្នាលស្នេហ៍ព្រួយព្រាណប្រែក្តីស្នេហ៍ស្និទ្ធ
រកាំកាយខ្វាយខ្វល់កលរកាំកាយ
សារៀមថ្ងៃងមកឲ្យជ្រាបក្នុងរឿងសារ ៗ

៙ ឆោមឆាយឆើតកើតមេត្តាណា ឆោមឆាយ
ណាយទឹកសេចក្តីព្រួកគ្មានទឹកណាយ
សញ្ញាស័ត្យប្រយ័ត្នកាយស្តាយសញ្ញា
គិតដូចស្មានបើពុំបានស្មានដូចគិត ៗ

៙ អសារសោះស្ងួនគំនិតសោះអសារ
ពាស្នាគិតបុណ្យក៏តូចតាមពាស្នា
ឃ្លាតបើទុកទៅជាតិមុខកុំឲ្យឃ្លាត
ខ្ញុំបំណាងសាងផ្សងដូចបំណងខ្ញុំ ៗ

៙ ជាតិក្រោយទៅទៀតសូមសុំជួបសព្វជាតិ
ទៀតបងស្មានអ្នកក៏ស្មោះទើងបងទៀត

វាចាសុំកុំឲ្យឃ្លាតពីវាចា
លុះដល់ព្រះអរហត្តកាត់បានលុះ ។

◎ ករុណាមិត្រឲ្យចិត្តនៅករុណា
មេត្តាសោះអស់ស្រឡាញ់នៅមេត្តា
រៀមរ័កស្មោះស្ម័គ្រចូរអ្នកស្ម័គ្ររៀមក៏
ថ្លែងវាចាប្រាថ្នាសុំបានដូចថ្លែង ។

◎ លិខិតសារលេខាសានមធុរស
មធុរឿងរៀមរ័កអ្នកស្ម័គ្រស្មោះ
សូមឲ្យអនុគ្រោះកុំក្រោធ
កុំក្រោធក្រេនខ្លួនរៀមឥតទីពឹង ។

◎ ឥតទីពាក់ពំនឹងនៅកំព្រា
កំព្រាប្រាណពុំមានញាតិមិត្រជាគ្នា
ជាកន្ទុកវេទនាជាចិន្ត្រៃយ
ជាប់ចិត្តត្រេកកាលក្រឡេកជួបនេត្រ ។

◎ ជួបនេត្រនឹកស្មោះស្ម័គ្រឥតឧបមៃយ
ឧបមាកាលថ្ងៃចាកចោលថ្ងៃ
មកបាត់ដួងវិល័យពីឧរា
ឱរៀមមករងទុក្ខ ៗ ពីព្រេង ។

◎ ទុក្ខពីព្រោះខ្លួនឯងឥតក់ស្មា
ព្រោះតែស្នេហ៍ឲ្យប្រែជាទុក្ខា
ទុក្ខអើយចំផ្ញើសារជូនមកដល់
មកដោយសេចក្តីគិតមានអាល័យ ។

◎ ដែលអាឡោះនឹកថ្ងៃសោកសែនសល់
ហើយសែនណែនទ្រូងខ្ញុំទ្រាំទុក្ខទល់
ទ្រាំទុក្ខទៀបដាច់ខ្យល់ខ្ចាត់ពីកាយ
ពីកើតមករៀមមិនដែលទុកដូច្នឹង ។

◎ ទុក្ខដូច្នេះសមនឹងទ្រូងប្រេះខ្ចាយ
ទ្រូងបែកខ្ចាត់បាត់ជន្មចេញពីកាយ
ទុកក្រំផ្សាជាំពុំមានសោយ
ទឹកនេត្រស្រោបស្រប់កាយមិនស្រាកស្រាន្ត ។

## ទុក្ខំ អនិច្ចំ អនត្តា

កកើតប្រាពោសទុក្ខំ
ទុក្ខពាល់អស់កាលជាតិជាន់ជុំ
ទុក្ខធំក្រមនឹងល្ហែល្ហើយ ។

៙ កាយអើយគួរគិតឲ្យឆ្អិនឆ្អៅ
មនោមកនៅថ្វីព្រាងើយ
គួរកាត់កលវដ្តរត់រកត្រើយ
នៅនេះណាឡើយនឹងស្បើយទុក្ខ ។

៙ គួរស្វែងអរហំតាំងនិពេជ
លះលោភក្រេវក្រោធមនោទុក
ក្ដែកបិទបុងចិត្តគិតរកសុខ
ភូមិភពនៃនរកគ្មានសុខសោះ ។

៙ អំបាលព្រះធមិសំកប់លោក
បង្កើតកាល្បមកភ្លើងឆេះអស់
មិនមានទីណាសល់បន្ទោះ
នឹងភ្លើងឆេះនោះគ្មានសោះឡើយ ។

៙ សោឡសសួគ៌សុខតែបុណ្យបាន
កុសលដែលបានសាងជាត្រើយ
ទ្រទ្រង់បំរុងគ្រាន់ល្ហែល្ហើយ
កុសលអស់ហើយកើតទុក្ខក្រប់ ។

៙ ដូចកលទិកនឹងកក្រើ
បាត់ស្មើថ្ងៃងងឹតឈប់

ជាទីអនិច្ចំក្នុងត្រៃភព
កប់ជាតិគំរប់ជាធម្មតា ។

៙ អនិច្ចំទាំងបានស្លឹសោឡស
គង់វិនាសចុះចាកស្លឹគា
អនិច្ចំពុំទៀងទាំងវេលា
គួរឲ្យវេទនាពល់រូបកាយ ។

៙ គួរគិតឲ្យឃើញព្រះអនិច្ចំ
គួរតាំងចិត្តខ្ជាប់កុំពយមាយ
គួរគិតបៀសចាកផ្លូវអបាយ
អស់ឃើងទាំងឡាយគួរអនិច្ចំ ។

៙ អនិច្ចាវេទនាជានិរន្តរ៍
រូបគង់អស់ជន្មគ្មានខានខាំង
នឹងរកទីណាពួនកំបាំង
អនិច្ចំពុំទៀងទាំងត្រៃភព ។

៙ អនិច្ចំមុខគួរឲ្យវេទនា
ខ្លះរងវេទុក្ខពាន់គ្រប់
ល្ហុះល្ហោចផ្សាខ្លោចផ្សៃផ្សាយផ្សេង
ផងនឹងឈឺងឈ្លប់អប់អាប់អួរ ។

៙ អនិច្ចាមុខគួរឲ្យវេទនា
មនុស្សខ្លៅថាជាប្រាជ្ញតាប់គួរ
លោភោទោសោមោហ៍ម៉ៅមួ
តាំងតួតណ្ហាថាសប្បាយ ។

៙ សេចក្តីតណ្ហាសាបសូន្យទេ
ពុំគួរកប់កេលរូបកាយ
រឿងរូបដូចភ្លើងឆេះព្រោងព្រាយ
រឿងកាយកេលកលរូបអាត្មា ។

៙ គួរគិតកុំភ្លើនឲ្យភ្លេចភ្លាំង
នឹងគេអនិច្ចំតាំងអនត្តា
ធម្មតារូបរស់ក្នុងសង្ខារ
ធម៌ថាគង់ជារលាយបាត់ ។

៙ ខំទឹករព្យកផល់មគ្គផល
ព្រះអង្គដំកល់ជាបរមត្ថ
ប្រុងប្រុងក្នុងវង្សព្រះអរហត្ត
កាត់កម្មកិលេសប្រាសពីទុក្ខ ។

៙ មនោះអើយគួរមានះកាត់ឲ្យបាន
កុំឲ្យរំខានតទៅមុខ

ជាតិនេះជាតិនាយនឹងបានសុខ
ចៀសចាកទុក្ខមុខជាស្បើយ ៗ
៙ ខំគិតមានះទើបកាត់បាន
ជ្រះថ្លាសន្ដានបានយល់ត្រើយ
នីរនេសនឿយណាយនិរទុក្ខហើយ
កាយអើយកាយគិតឲ្យជ្រះជ្រៅ ៗ
៙ និត្យនៅក្នុង លោកជាធម្មតា
លំបាកច្រើនគ្រាមិនដែលហៅ
បានស្បើយល្ហែល្ហើយសោចក្ដីក្ដៅ
នៅនេះនៅនឹងរើថែមទុក្ខ ៗ
៙ ត្រែកតាំងពីនេះលន្ទង់
លន្ទោបផុតផុងរងទេក
ខំនឹកត្រេកត្រកទិសុខ
កុំមិកតពនៃនរកទុក្ខសែនសល់ ៗ
៙ ប្រាជ្ញខ្លះសង្សារថាបងជាប់
តុំគួរបើកប់ឲ្យរលប់
ប្រានបោលស្រឡះកុំឲ្យផល់
កុំខ្វល់កុំខ្វាយកុំស្ដាយថ្មី ៗ

៙ សង្សារពៅតែងទឹងល្អងលោម
មិនឲ្យរំលងរួចទុក្ខភ័យ
ប្រាជ្ញប្រុះធុះសព្វទាំងកពៅត្រៃ
ម្តេចបាញ់កលស្រីមកសោយទុក្ខ ៗ
៙ ខំគិតខំកាត់កុំអាល័យ
សង្សារចង្រៃក្របានសុខ
ហ្នឹងហើយជាដើមកូមិនរក
នាំបង្កើតទុក្ខពល់រូបា ៗ
៙ សិនធ្វើឲ្យខ្វល់សល់សែនខ្នាត
សិនធ្វើឲ្យខាតផ្លូវមេត្តា
សិនឲ្យកើកាយដួងចិន្តា
សិនឲ្យក្តៅផ្សាគ្មានល្ហែល្ហើយ ៗ
៙ សន្តានអ្នកខ្មៅឥតប្រាជ្ញា
បាញ់កលតណ្ហាកើតឯក្រោយ
ឲ្យរាំធ្វើទុក្ខព្រមបណ្តោយ
ទឹងខ្លោយគំនិតពិតសូន្យសោះ ៗ
៙ នោះពេញជាថយថោកប្រាជ្ញា
បាញ់កលតណ្ហាគ្មានចន្លោះ

កិលេសត្រាំសឹកសន្ទានអស់
ម៉េះម៉ោះកាលណានឹងស្ពានទុក្ខ ៗ.
៙ បើអ្នកឯណាមានសទ្ធា
ប្រកបប្រាជ្ញាស្វែងរកសុខ
មានពិចារណាសេចក្តីទុក្ខ
នឹងបានរៀនត្រកេធម៌អាថ៌
៙ ព្រះពុទ្ធព្រះធម៌សង្ឃសេដ្ឋ
ប្រោសជាកំពង់មានប្រាជ្ញា
ដឹងមគ្គផលដឹងធម៌អាថ៌
ក្នុងដួងចិន្តាជ្រះថ្លាឈ្វេង ៗ
៙ លុះយប់ស្ងានស្ងាត់កាត់សង្ស័យ
រំពឹងព្រះត្រៃបិដកស្តែង
ទាំងក្នុងទាំងក្រៅនៅខ្លួនឯង
កុំឲ្យវង្វេងទៅសោយទុក្ខ ៗ
៙ គន់គិតតាមឋានព្រះអរហន្ត
អរហន្តលោកកាត់កលផុងកក់
ផ្លូងត្រើយល្ហៃល្ហើយស្បើយពីទុក្ខ
សម្រេចដល់ស្រុកព្រះនិព្វាន ៗ

◎ នរណាសង្ខាកាត់ឱ្យស្រួល
កុំឱ្យក្តៅក្តួលគិតរំខាន
កុំធ្វើឱ្យដល់ខ្វល់សន្តាន
ក្រែងខានសម្រេចក្តីប្រាថ្នា ។

◎ អស់យើងទាំងឡាយដែលកើតមក
គួរគិតរិះរកផ្លូវបញ្ញា
គួរគិតគួរគន់ពិចារណា
ឱ្យភ្លឺជ្រះថ្លាក្នុងសន្តាន

◎ ភ្លឺក្នុងទឹងភ្លេចរបស់ក្រៅខ្លួន
ទឹងមួនទឹងមុជផ្លូវកម្មដ្ឋាន
ទឹងជ្រះកិលេសក្នុងសន្តាន
ទឹងបានសម្រេចដោយប្រាជ្ញា ។

◎ ឃើញបានបុណ្យដែលដំកល់ទុក
ស្វែងរកទីសុខផ្សិតជ្រះថ្លា
ដឹងខ្លះយល់ច្បាស់ដោយប្រាជ្ញា
បុះផ្លូវឯកគ្គតាភ្លឺសុះសាយ ។

◎ ឃើញច្បាស់ព្រះធម៌នេះសែនក្រ
ដំកល់ទុកឱ្យល្អទើបបានភាយ

តែឲ្យកំពប់ជ្រុះខ្ចាត់ខ្ចាយ
ល្អិតណាស់មិនអាយនឹងកើបបាន ។

៙ បើអ្នកឯណាប្រាស់ធម៌ពិត
ទើបគិតស្រឡាញ់ព្រះនិព្វាន
ផ្ចិតកើតឡើយណាយក្នុងសន្តាន
វេទនារំខានឃើញអនត្តា ។

៙ ឃើញកើតហើយស្លាប់មុខគួរធុញ
ខ្ពុះស្បែកបុញ្ញយសសក្តា
ស្លាប់បាត់សូន្យស្ងាត់សោះអសារ
ពោលយសសក្តាទីភូមិស្ថាន ។

៙ នឹងឃាត់អង្វរថាកុំទៅ
ឈប់សិនឲ្យនៅបូថ្កើងថ្កាន
មានបុណ្យយសសក្តិទ្រព្យធនធាន
បរិវារក៏មានប្រើត្រៀបត្រា ។

៙ សង្ខារនោះទៀតដ៏រឹងមានៈ
ឃើញថាគ្មានម្ចាស់លើផ្ទា
គ្មានព្រមអាណិតយសសក្តា
មិនស្គាល់បរិកនៅណាសោះ ។

៙ គួរពេក៏ខាលផាតិកពកំណើត
ឃើញហើយរីកើតពេញបំពោះ
ឃើញច្បាស់វេទនាគ្មានសង្គ្រោះ
ចំពោះគំនិតខុសខាតអន្តរាយ ។
៙ ខ្លួនទៅទ្រព្យនៅចោលអសារ
បុណ្យសក្តិបរិវារនៅឯអាយ
ដឹងហើយឃើញហើយមិនគិតស្តាយ
បានចោលនៅកាយទៅតែខ្លួន ។
៙ ប្រសិនបើជាមានប្រាជ្ញា
គិតរកបរិវាររៀបជាក្បួន
វៃហាយើងឲ្យជាប់ទៅតាមខ្លួន
នោះឃើញសមសួនថាមានសក្តិ ។
៙ អ្នកនោះហៅពេញជាគិតត្រូវ
សំណាងអ្នកទៅឥតតុរ:
ព្រោះចេះបាត់បែងដោះអន្ទាក់
ឃើញជាក់ជាបានខ្លួនដល់ត្រើយ ។
៙ ផ្សិតព្រះពុទ្ធអង្គទ្រង់ប្រៀបទុក
សង្សារជាតិដក់ជាប់ឯក្រោយ

កែខៃខំគិតកុំឲ្យឆ្ងាយ
កុំតាមបណ្តាយផ្លូវតណ្ហា ។
◎ ដំបូរនេះគាបចូលគ្រប់រូប
គួរដោះឲ្យរបូតកុំរកា
គិតកាត់ដើមនងឫសតណ្ហា
កុំឲ្យផ្លែផ្កាជាប់ជាពូជ ។
◎ រំពឹងធមិគាថជាប្រយោជន៍
តាំងចិត្តកុំឲ្យខូចផ្លូវមេត្តា
កាត់ផ្លូវតណ្ហា ទូវអវិជ្ជា
គង់ថយតាមគ្នាខានគ្រប់រូប ។

ឧកញ៉ានភក្សត្រ ( គង់ )

---

រឿងនេះមានតទៅទៀតតែច្បាប់ដើម
បាត់រកមិនឃើញ បានតែប៉ុណ្ណេះ ។

ហិតោបទេស ភាគទី ១

“ការចងមិត្រ”

ឧកញ៉ា ទេព ពិទូរក្រសេម - គន្ធរបនបណ្ឌិត

ប្រែនិងរៀបរៀង (ត)

ដល់វេលារសៀលតាបហើយ ប្រើសនឹងចចកក៏នាំគ្នាមកកាន់ទីលំនៅរបស់ប្រើស ។ មានក្អែកឈ្មោះសុពុទ្ធិ ជាមិត្រចាស់របស់ប្រើសអាស្រ័យនៅលើដើមចម្បក បានឃើញសត្វទាំងពីរបណ្តើរគ្នាមកក៏ស្រែកសួរមកថា សំឡាញ់ប្រើស អ្នកនាំនរណាមកហ្នឹង? ប្រើសតបថា "សុនខចចក, ត្រូវការចងជាមិត្រនឹងខ្ញុំ ។

ប្រើសរំលឹកថា "សំឡាញ់! ការដែលជឿទុកចិត្តគ្នាភ្លាមនឹងអ្នកដែលជាអាគន្តុកទើបមកថ្មីនោះមិនគួរ មិនជាសេចក្តីប្រព្រឹត្តដ៏ត្រឹមត្រូវឡើយ ព្រោះលោកថា :

៥៧ "អ្នកឯណាក៏ដោយ ដែលមិនបានស្គាល់ជាតិត្រកូលនឹងសេចក្តីប្រព្រឹត្ត មិនគួរឲ្យអាស្រ័យរួមគេហស្ថាន ត្មាតឈ្មោះជរទ្គវៈត្រូវប្រហារស្លាប់ ក៏ព្រោះសេចក្តីខុសដែលបានទទួលឆ្មាឲ្យនៅផង" ។

ប្រើសនឹងចចកសួរថា "រឿងនោះដូចម្តេច" ក្អែកនិទានរឿង

## រឿងទី ៤

នៅឆ្នេរទន្លេភាគីរថី[១] លើភ្នំគិជ្ឈកូដ[២] មានជ្រៃ ១ ដើមធំក្នុងដើមមានប្រហោងរហូតដើម ។ ត្មាតជរទ្គវៈ ដោយអំណាចកម្មអំណោយផលឲ្យត្រូវលំបាកក៏មានភ្នែកងងឹតងងល់ ក្រចកសណ្តករស់

---

១ ទន្លេគង្គា មួយកន្លែងនោះ ហៅភាគីរថី ។ ២ ភ្នំគិជ្ឈកូដ ។

អាស្រ័យនៅលើដើមជ្រៃនោះ ។ បណ្ដាបក្សីសត្វដែលធ្វើសំបុកពងនៅដើមឈើជាមួយគ្នានោះ មានសេចក្ដីករុណា បានបែងចែកអាហារឲ្យបរិភោគល្មមបន្តជីវិតទៅមួយថ្ងៃៗ ។ គ្រានោះ នាថ្ងៃមួយ ឆ្មាឈ្មោះទីឃកណ្ណ មកកាន់ទីនោះ ដោយបំណងនឹងចាប់កូនសត្វអំបាលនោះស៊ី តែលុះចូលទៅជិត កូនសត្វអំបាលនោះឃើញក៏ស្រែកខ្ញៀវខ្ញារឡើងដោយសេចក្ដីខ្លាច ជរទ្គវៈបានឮក៏គម្រាមសួរទៅថា "អ្នកណាចូលមកនុ៎ះ ហ៎ះ?

ទីឃកណ្ណឃើញត្មាតក៏ភ័យស្លុតព្រលឹងគិតថា "ហើយអញម្ដងនេះ មុខជាស្លាប់ហើយអញ តែ —

៥៨ ភ័យណាដែលអន្តរាយនៅឆ្ងាយ ក៏គួរជាខ្លាចភ័យនោះ តែកាលអន្តរាយមកជិតផ្ទាល់ខ្លួនហើយ នរជាតិត្រូវចាត់ការកែខ្លួនឲ្យគួរតាមហេតុ ៗ ឥឡូវខ្លួនយើងចូលជិតអន្តរាយហើយ នឹងគេចរត់ទៅក៏ឃើញជាមិនផុត ចូលហួសមកហើយក៏ត្រូវតែកែខ្លួនដោះទាល់តាមការ ហេតុនោះ គួរយើងចូលទៅរកត្មាតឲ្យដល់ផ្ទាល់ខ្លួន គិតឃើញដូច្នេះហើយក៏ទន្ទុបលលបចូលទៅរកត្មាតនិយាយថា "បពិត្រលោកអាចារ្យ! ខ្ញុំសូមសំដែងសេចក្ដីគោរពដល់លោក" ។

ត្មាតសួរថា "នរណា ហ៎ះ ។

ទីឃកណ្ណឆ្លើយថា "ខ្ញុំជាឆ្មា ឈ្មោះទីឃកណ្ណ" ។

ត្មាតគម្រាមថា "យើ! អាចោរខូច, ចូរប្រញាប់ចេញទៅឲ្យឆ្ងាយ មិនដូច្នោះ នឹងត្រូវអញប្រហារស្លាប់ឥឡូវនេះ" ។ ឆ្មាអង្វរថា មេត្តាប្រោសស្ដាប់ពាក្យខ្ញុំសិន កាលណាលោកបានស្ដាប់ហើយ បើនៅតែឃើញថា ខ្ញុំសមគួរនឹងស្លាប់សោត ខ្ញុំក៏សុខចិត្តទទួលទោសប្រហារតាមចំណង់ ព្រោះ —

៥៩ មាននរណាឯណាខ្លះ ដែលត្រូវធ្វើទោសឬត្រូវបានទទួលកិត្តិយសដោយជាតិត្រកូលប៉ុណ្ណោះ; មានតែគេធ្វើទោសឬឲ្យកិត្តិយសក្នុងកាលដែលបានត្រួតពិនិត្យសេចក្ដីប្រព្រឹត្តស្រេចហើយ ។

ត្មាតតាំងបញ្ហាសួរថា អ្នកឯងចូរប្រាប់ឲ្យដឹងថា "ខ្លួនអ្នកមានសេចក្ដីប្រព្រឹត្តដូចម្ដេច?" ។

ឆ្មាឲ្យការថា "ខ្ញុំអាស្រ័យនៅទៀបទន្លេគង្គា ធ្វើកិច្ចស្នានបាប(១) ជានិច្ចសីល វៀរបរិភោគមំសាហារ កាន់ព្រហ្មចរិយសមាទានសីលចន្ទ្រាយណៈ(២) ឥឡូវនេះ ខ្ញុំបានឮពួកបក្សីដែលជាទីស្រឡាញ់នឹងជាទីទុកចិត្តរបស់លោក សរសើរកិត្តិគុណរបស់លោកថា មានសេចក្ដីចេះដឹងជ្រៅជ្រះច្រើន ប្រព្រឹត្តក្នុងសម្មាបដិបត្តិ ព្រោះហេតុនោះ ខ្ញុំមកនេះដើម្បីស្ដាប់ច្បាប់វិន័យ នៃសាសនាក្នុងសំណាក់លោកដែលជាអ្នកមានអាយុចាស់ជាង នឹងចេះចប់សព្វគ្រប់ក្នុងក្បួនសិល្បវិទ្យាផ្សេង ៗ កាល

---

១ ងូតទឹកលាងបាប ។ ២ គឺសីលដែលត្រូវរក្សាក្នុងថ្ងៃព្រះចន្ទពេញបូណ៌មី ។

បើដូច្នេះទេតើ ហេតុម្ដេចលោកអ្នកទ្រង់ទ្រូវធម៌ទើបមកគិតចំណាយខ្ញុំដ៏ជាភ្ញៀវមករកនេះបង់ ព្រោះមុខងាររបស់អ្នកជាគហបតីលោកពោលថា

៦០ គួរសំដែងសេចក្ដីអើពើដល់អ្នកដ៏ជាភ្ញៀវចូលមកក្នុងផ្ទះ ទោះបីជាសត្រូវក៏ដោយ ! រុក្ខជាតិក៏នៅឲ្យម្លប់សំណាក់អាស្រ័យដល់អ្នកដែលមកកាប់ ។ ទោះបីគ្មានអាហារលៀងភ្ញៀវដែលមក យ៉ាងហោចទៅ ក៏គួរជាសំដែងកថាអើពើបដិសណ្ឋារៈដោយល្អ ព្រោះថា –

៦១ ចំបើង (សម្រាប់បក្អាត់ក្លើង), ទីសំណាក់អាស្រ័យ ទឹក និងពាក្យ-ពាផ្អែមល្ហែម ៤ យ៉ាងនេះ រមែងមិនឥតមានក្នុងផ្ទះនៃសប្បុរសសព្វកាល ។

៦២ អ្នកមកកាន់គេហស្ថាន ទោះជាក្មេង កំលោះ ក្រមុំ ចាស់ទុំក៏ដោយ យើងត្រូវទទួលអ្នកនោះ (ព្រេញទី) ត្រូវគាប់ថា ភ្ញៀវដែលមករកជាអ្នកខ្ពស់ជាងអ្នកណាទាំងអស់ ។

៦៣ អ្នកដែលមានចរិយាល្អ គោរពសំដែងសេចក្ដីមេត្តាករុណាសូម្បីក្នុងសត្វដែលថយថោក, ព្រោះព្រះចន្ទ្រមិនបានវៀរការបំភ្លឺពន្លឺទៅក្នុងផ្ទះមនុស្សចណ្ឌាលក៏ទេដែរ ។

៦៤ ផ្ទះអ្នកណាដែលត្រូវភ្ញៀវត្រឡប់ទៅវិញដោយសេចក្ដីទោមនស្ស ក៏ទុកដូចជាភ្ញៀវនោះទម្លាក់បាបនូវសេចក្ដីអវមង្គលទុកឲ្យអ្នកម្ចាស់ផ្ទះ ហើយនាំយកសួស្ដីមង្គលចេញទៅផង ។

៦៥ ក្អែកទោះបីជាអ្នកថោកទាប មកដល់ផ្ទះអ្នកមានត្រកូលទោះជាអ្នកមានបណ្ឌាស័ក្តិខ្ពស់ គួរអ្នកម្ចាស់ផ្ទះទទួលតាមគុណានុរូប ព្រោះក្អែកទាំងអស់មានទេវតាប្រចាំនៅក្នុងខ្លួន ។

គាត់តបថា “ឈ្មោះថា ឆ្មាហើយរមែងចូលចិត្តស៊ីមំសៈជាអាហារ, នៅលើដើមឈើនេះមានកូនសត្វជាច្រើន ព្រោះហេតុនោះ ទើបយើងនិយាយដំទាស់ដូច្នោះ” ។

ឆ្មាបានស្តាប់ហើយទើបឱនក្បាលចុះទល់ដី ពោលថា បំណែកខ្ញុំ (ខុសនឹងឆ្មាធម្មតា) ព្រោះបានសមាទានសីលចន្ទ្រយណៈ ដោយសេចក្តីព្យាយាមដ៏ក្លា ទាល់តែជាវីតរាគៈប្រាសចាកសេចក្តីដំរេកត្រេកអរ បានសិក្សាគម្ពីរព្រះធម្មសាស្ត្រចប់ ។ រីឯព្រះគម្ពីរនៃព្រះជាម្ចាស់នោះ ទោះនឹងមានសេចក្តីខុសប្លែកចំឡែកទទឹងទាស់គ្នាខ្លះ ក៏ត្រឹមតែបន្តិចបន្តួច តែត្រង់សេចក្តីសំខាន់ រមែងត្រង់គ្នាទាំងអស់ គឺ អហិង្សាបរមធម៌ ធម៌មានការមិនបៀតបៀនគ្នាជាកំពូល ព្រោះ–

៦៦ អ្នកណាវៀរធ្វើឲ្យអ្នកដទៃក្តៅក្រហាយ អ្នកណាមានសេចក្តីព្យាយាមអត់ធន់នឹងសភាវៈទាំងពួង នឹងជាទីពឹងពំនាក់នៃសត្វទាំងឡាយ, អ្នកនោះរមែងដំណើរចូលទៅកាន់ផ្លូវសួគ៌ ។

៦៧ សេចក្ដីល្អប៉ុណ្ណោះ ដែលជាមិត្រជិតដោយតាមខ្លួនទៅបាន ដោយពិតក្នុងយាមដែលអស់ជីវិត, ចំណែកឯរបស់ដទៃ ៗ ក្រៅអំពីនោះ ក៏ដល់នូវសេចក្ដីទំលាយអន្តរាយព្រមជាមួយនឹងរាងកាយ ។

៦៨ អ្នកដែលនឹងស៊ីគេ គួរជារលឹកឲ្យបានថា យើងនឹងអ្នកដែលយើងស៊ីនោះខុសគ្នា អ្នកស៊ីបានឆ្អែតពោះតែមួយពេល, តែអ្នកដែលត្រូវបង់សាច់ រមែងបានទុក្ខវេទនាដល់ក្ស័យជីវិត ។

៦៩ ទុក្ខអំបាលណា កើតប្រាកដដល់មនុស្សដែលឃើញថា សូម្បីខ្លួនក៏តោងស្លាប់ដែរ កាលអនុមានទុក្ខអំបាលនោះមកធៀបនឹងខ្លួនហើយ ទោះបីជាសត្រូវនឹងគ្នាក៏អាចជួយការពារអន្តរាយឲ្យគ្នាបាន ។

៧០ អ្នកណាឡើយនឹងសុខចិត្តកការអកុសល ព្រោះឃើញផលពោះដែលស្រេកឃ្លាន ប្រសិនជាឃ្លាន លតាស្មៅព្រៃដែលដុះឯងក្នុងព្រៃដេរដាសក៏អាចនឹងចំអែតពោះឲ្យឆ្អែតបានដែរ ។

លុះវិឡារនិយាយសម្រួលឲ្យត្មាតបាត់សន្ទុះហើយ ក៏ចូលទៅអាស្រ័យនៅក្នុងរូងឈើ ៗ ថ្ងៃតមក ត្មាតក៏លបចាប់កូនសត្វអំបាលនោះមកស៊ីរាល់ ៗ ថ្ងៃ ៗ ចំណែកសត្វទាំងឡាយ ក៏សោយសោកក្ដៅក្រហាយ ដោយហេតុកូនរបស់ខ្លួនរលះបាត់ទៅរាល់ថ្ងៃ ទើបនាំគ្នាស្រាវជ្រាវរក

ហេតុឯណោះឯណោះ ។ ត្មាតកាលដឹងទម្រោយក៏លបគេចចេញចាកទីនោះ ក្រោយនោះពួកបក្សីទាំងឡាយស្រាវជ្រាវទៅស្រាវជ្រាវមក ក៏ប្រទះឃើញឆ្អឹងកូនខ្លួននៅក្នុងព្រៃឈើ ក៏សម្រេចសន្និដ្ឋានថា ត្មាតចាស់នេះឯងជាអ្នកស៊ីកូនរបស់ខ្លួន ទើបនាំគ្នាចោមរោមប្រហារត្មាតនោះស្លាប់, ព្រោះហេតុនោះខ្ញុំ (អ្នកសុពុទ្ធិ) ទើបថា អ្នកណាក៏ដោយ ដែលយើងមិនបានស្គាល់ជាតិត្រកូលទឹងនិស្ស័យ ។ល។ កុំគប្បីគប់ (៤៨) ។

(មានតទៀត)

# រឿងព្រេង-បុរសផ្កាប់ត្រឡោក

និយាយរឿងមួយមានសេដ្ឋីប្តីប្រពន្ធមានកូនក្រមុំមួយនាក់មានរូបឆោមល្អណាស់ បណ្តាជនកំឡោះប៉ុន្មានៗជាច្រើនឈ្មោះស្ម័គ្រស្រឡាញ់បានដំកបមាតាបិតាឲ្យទៅដណ្តឹងកូនក្រមុំមហាសេដ្ឋីៗ នោះក៏ឥតប្រកែកព្រមឲ្យ តែមានខសន្យាថា បើកំឡោះឈ្មោះណាចង់បានឲ្យសង់ផ្ទះ៤ល្វែងតែមួយថ្ងៃឲ្យហើយ បើធ្វើមិនហើយ សេដ្ឋីនោះផ្តាច់មិនឲ្យកូនក្រមុំ ។ កំឡោះដទៃប៉ុន្មានៗខូចខាតជំនូនជាច្រើននាក់ ដោយធ្វើផ្ទះមួយថ្ងៃមិនហើយ សេដ្ឋីក៏ផ្តាច់មិនឲ្យកូនក្រមុំ ខណៈនោះមានកំឡោះម្នាក់ជាអ្នកមានគំនិតគិតឧបាយកលប្រាជ្ញ ឈ្មោះហៅថា អាផ្កាប់ត្រឡោក ជាកូនអ្នកមានគ្រាន់បើ បានសុំប្រាក់មាតាបិតាយកទៅទិញឈើលបធ្វើប្រុងប្រៀបគ្រប់ប្រដាប់ផ្ទះហើយស្រេច រួចកោសរូសខាត់ត្រឡោកស្អាតហើយដំកបមាតាបិតាឲ្យទៅដណ្តឹងកូនក្រមុំមហាសេដ្ឋីនោះ ឯមាតាបិតាក៏ទិញផ្លែឈើមើមឈើបានច្រើនគុ ហើយពឹងញាតិសន្តានឲ្យជួយកាន់ជំនូននោះទៅដល់ផ្ទះមហាសេដ្ឋីប្រណម្យសំពះដំកបថា ខ្ញុំបាទមកសូមដណ្តឹងកូនក្រមុំលោកផ្សំផ្គុំនឹងកូនប្រុសកំឡោះខ្ញុំបាទនាងខ្ញុំ ពោះបើខុសត្រូវសូមលោកសេដ្ឋីអភ័យទោស សូមឲ្យបានជាសាច់សន្តានតរៀងទៅ ៗ

សេដ្ឋីទាំងប្តីប្រពន្ធស្តាប់ហើយឆ្លើយថា យើងឥតប្រកែកថាអ្វីទេអ្នក តែថាថ្ងៃស្អែកនេះអ្នកធ្វើផ្ទះ៤ល្វែងឲ្យហើយស្រេច បើធ្វើមិនហើយយើង

ក៏ផ្ដាច់មិនឲ្យកូនក្រមុំ ។ ឯមាតាបិតាអាផ្កាប់ត្រឡោកឮហើយដំកបថា បើកូនខ្ញុំធ្វើផ្ទះថ្ងៃស្អែកនេះមិនហើយស្រេចទេ សូមលោកសេដ្ឋីផ្ដាច់កុំឲ្យកូនក្រមុំលោកចុះ ជំនូនប៉ុន្មានតុះនេះខ្ញុំបាទនាងខ្ញុំក៏សុខចិត្តជូនលោកទាំងអស់ឥតគិតយកថ្លៃពីលោកឡើយ ហើយជូនជំនូនទាំងអស់ទៅសេដ្ឋី ។ ក៏ឲ្យខ្ញុំកំដរលើកទៅដាក់ទុកពេញមួយល្វែងផ្ទះ ក៏យកសម្បកតុថាសមកឲ្យនោះមាតាបិតាអាផ្កាប់ត្រឡោកទទួលតុថាសគ្រប់ចំនួនហើយ ក៏សំពះលាមហាសេដ្ឋីនាំគ្នាត្រឡប់មកផ្ទះវិញ ។

ក្រោយនោះមហាសេដ្ឋីនឹងភរិយា នាំគ្នាទៅមើលជំនូននៅលើផ្ទះនោះសុទ្ធតែថ្លៃឈើមានដំឡៃប្លែកៗពីប្រទេសឆ្ងាយខ្លះ នៅស្រុកអាយខ្លះ សេដ្ឋីក៏ញញឹមញញាក់មុខទាំងប្រពន្ធថា ជំនូននេះយើងមុខជាបានស៊ីទទេទៀតហើយ ។

ចំណែកមាតាបិតាអាផ្កាប់ត្រឡោកទៅដល់ផ្ទះក៏និយាយប្រាប់កូនថា សេដ្ឋីព្រមឲ្យហើយ ។ សេដ្ឋីថា ឲ្យកូនធ្វើផ្ទះតែក្នុងថ្ងៃស្អែកនេះឲ្យហើយស្រេច អាផ្កាប់ត្រឡោកឮមាតាបិតានិយាយប្រាប់ដូច្នោះមានចិត្តត្រេកអរណាស់ដំកបមាតាបិតាថា លោកម៉ែលោកឪកុំព្រួយបារម្ភមុខជាបានដូចគំនិតដែលកូនគិតទុកពីថ្ងៃមុននោះ ហើយអាផ្កាប់ត្រឡោកក៏ទៅនិយាយពឹងបងប្អូនអ្នកដែលចេះការធ្វើផ្ទះបានគ្នាច្រើន ឲ្យគេជួយសង់ផ្ទះតែក្នុងថ្ងៃស្អែកនេះឲ្យហើយ បងប្អូនគេទទួលជួយទាំងអស់គ្នា អាផ្កាប់ត្រឡោក

ត្រឡប់មកផ្ទះវិញក៏ស្លៀកពាក់តែងខ្លួនស្អាតបាត នាំកំឡោះផងគ្នាឲ្យជូនទៅផ្ទះសេដ្ឋីនោះ លុះដល់ឡើងទៅលើផ្ទះសេដ្ឋី ៗ សួរថា ហៅឯងមកមានការអ្វី ។ នោះអាផ្កាប់ត្រឡោកលុតជង្គង់ប្រណម្យដំកបសេដ្ឋីថា លោកម៉ែលោកឪខ្ញុំប្របាទ ប្រើខ្ញុំប្របាទជាកូនឲ្យមកសូមក្រាបប្រណិប័តន៍លោកឪពុកម្តាយសូមមានប្រាប់ទីកន្លែងត្រង់ណាឲ្យទានខ្ញុំប្របាទសង់ផ្ទះ ខ្ញុំប្រ-បាទនឹងអាលទៅចាប់ការធ្វើក្រែងមិនហើយជូនលោកម្តាយឪពុកក្នុងវេលាថ្ងៃស្អែកនេះ ។

នោះសេដ្ឋីទាំងប្តីប្រពន្ធគន់មើលរូបឬកអាផ្កាប់ត្រឡោកនឹកក្នុងចិត្តសរសើរថា កូនប្រសាអញគ្រាន់បើដែរ តែថាមុខជាខូចខាតជំនួនដូចអាមុន ៗ ទៀតហើយ ៗ សេដ្ឋីប្រាប់ទីកន្លែងឲ្យសង់នៅទិសខាងជើងឲ្យឆ្ងាយពីផ្ទះធំចំនួន ៥ ម៉ែត្រ ។

ឯអាផ្កាប់ត្រឡោកបានឮសេដ្ឋីប្រាប់ជាក់ហើយក្រាបសំពះលានាំគ្នាត្រឡប់ទៅផ្ទះវិញ លុះដល់ប្រមូលបងប្អូនជួបជុំព្រម គ្រឿងផ្ទះណាដែលធ្ងន់ ៗ ផ្ទុកដាក់រទេះឲ្យស្រេចពីយប់ របស់ណាល្មមគួរលីសែងក៏ចាត់ចែងគ្រឿងដាក់មុខគ្នាស្រេច ។

លុះព្រឹកឡើងខ្លះដឹកនឹងរទេះខ្លះលី-សែងទៅដល់ផ្ទះសេដ្ឋី ខ្លះកាប់ដីខ្លះជីករណ្តៅសសរតាមខ្នាតទំហំផ្ទះ ៥ ល្វែង ខំធ្វើស្រុះស្រួលគ្នាមិនឈប់ ៗ តែពេលបរិភោគបាយ បរិភោគបាយរួចនាំគ្នាធ្វើទៀត លុះតែ

ហើយស្រេចក្នុងវេលាថ្ងៃនោះ រូបអាផ្កាប់ត្រឡោកឡើងទៅលុតជង្គង់សំពះជូនផ្ទះមហាសេដ្ឋីជាមាតាបិតាក្មេក ហើយនាំគ្នាត្រឡប់ទៅផ្ទះវិញ ៗ

លុះដល់ថ្ងៃខែបានឫក្សល្អ មាតាបិតាទាំងសងខាងក៏រៀបវិវាហមង្គលការកូនរួចស្រេច ឯអាផ្កាប់ត្រឡោកលាក់តែត្រឡោកមិនឲ្យឈ្មោះណាឃើញសោះ ដល់ពេលយប់រៀបសែនផ្សំដំណេករួចហើយក៏ដេកនៅក្នុងផ្ទះជាមួយគ្នា អាផ្កាប់ត្រឡោកយកត្រឡោកនោះទៅផ្កាប់គ្របពីលើស្វាស រូបស្លៀកសំពត់ចងក្បិនប្រយ័ត្នមិនឲ្យត្រឡោកធ្លាក់បាន ហើយដេកឃ្លាតពីភរិយា ធ្វើភរិយាសំងំមិនបានពាល់ដល់ចុងដៃ-ជើងភរិយានោះឡើយ ប្រើឧបាយយ៉ាងនេះ អត់ធន់បាន ៣-យប់ ៗ ក្រោយទៀតនាងភរិយានោះសោប់សល់ខ្វល់ចិត្តគិតសង្ស័យថា ប្ដីអញនេះដេកនៅជាមួយគ្នាបីយប់ហើយ គាត់ធ្វើព្រងើយកន្តើយហាក់ដូចជាគ្មានដំរេកត្រេកត្រង់នឹងអញសោះ ជាគាត់ខ្ទើយឬក្ស័យលិង្គ គិតក្នុងចិត្តដូច្នោះហើយក៏ប្រថុយចង់ដឹងលបលូកស្ទាបឲ្យច្បាស់ ៗ

ឯអាផ្កាប់ត្រឡោកដេកពុំលក់ធ្វើជាស្រមុកខ្វិល ៗ នាងប្រពន្ធនោះលូកដៃស្ទាបត្រង់កន្ទេងស្វាស នោះពានទៅលើត្រឡោកផ្កាប់លើងណាលដកដៃមកវិញគិតថា ប្ដីអញនេះទឹងជាខ្ទើយឬក្ស័យលិង្គក៏មិនមែន សណ្ឋានហាក់ដូចជាកើតស្រី តែថាទាស់គ្មានប្រឡាយមុខគួរឲ្យឆ្ងល់ ៗ

លុះព្រឹកឡើងខ្សឹបនិយាយប្រាប់ម្ដាយ តាមដំណើរដែលលបស្ដាប់ ប្ដីសព្វគ្រប់ ម្ដាយក្ដីហើយដកដង្ហើមធំថា ឱកូនអញអើយ បានប្ដីអីក មិនដូចបុរសទាំងពួង ហើយនឹកបន្ទោសកូនប្រសាប្រុសនោះថា បើឯង គ្មានប្រជាប់ដូចប្រុសទាំងពួងទេ ហេតុម្ដេចក៏ស្រឡាញ់កូនអញអម្ល៉េះ គិតហើយក៏ជំរាបសេដ្ឋីជាប្ដីតាមដំណើរកូនស្រីប្រាប់សព្វគ្រប់ សេដ្ឋី ស្ដាប់ហើយគិតថា បើអញនិយាយខ្លាំងខ្មាសគេផ្ទះជិតខាង ហើយក៏ និយាយខ្សឹបខ្សៀវប្ដីប្រពន្ធថា កូនប្រសាយើងនេះក៏គ្រាន់បើដែរ ណ្ហើយ គេហ៍ យើងអាណិតវា ឲ្យប្រាក់ថ្លៃពស្ដុការបណ្ណាការ ទិញថ្លៃផ្ទះមួយពាន់ ប្រាំរយណែនឲ្យទៅវា ហើយប្រាប់ឲ្យទៅនៅម៉ែឪវាវិញចុះ គិតព្រមគ្នា ហើយហៅកូនប្រសាថា ដីឯងមកឯណេះ អាផ្កាប់ត្រឡោកក្ដីសេដ្ឋី ឪពុកក្មេកម្ដាយក្មេកហៅខ្ញុំហើយ ក៏ទៅអង្គុយជិតសំពះសេដ្ឋីៗថា ឯង កិរិយាហាក់ដូចជាមិនស្រឡាញ់កូនអញ ណ្ហើយចុះអញឲ្យប្រាក់មួយ ពាន់ប្រាំរយណែន ឯងយកទៅទៅផ្ទះឪពុកម្ដាយឯងវិញចុះ រួបកប់ ប្រាក់ប្រគល់ឲ្យគ្រប់ចំនួន អាផ្កាប់ត្រឡោកទទួលយកប្រាក់ហើយជំរាប ថា លោកឪពុកខ្ញុំបាទសុំហឹបធំ ១ ដាក់ប្រាក់ដែលឲ្យខ្ញុំបាទ ហើយ សូមទានឲ្យបាវប្រុស ១ ជួយសែងយកប្រាក់ទៅផ្ទះខ្ញុំបាទផង សេដ្ឋីក៏ឲ្យ ហឹបដាក់ប្រាក់ចាត់បាវឲ្យសែងតាមអាផ្កាប់ត្រឡោកទៅដល់ផ្ទះ ហើយ ជូនប្រាក់មួយពាន់ប្រាំរយណែន ដែលនៅក្នុងហឹបទៅមាតាបិតាជំរាប

រឿងសព្វគ្រប់ ក៏ត្រឡប់មកផ្ទះសេដ្ឋីវិញ លុះដល់អាផ្កាប់ត្រឡោកធ្វើឫកកិរិយាសញ្ជប់សញ្ជឹងហាក់ដូចជាលើកអាល័យសេដ្ឋីនីកិរិយានោះពន់ពេក ។

សេដ្ឋីឃើញហើយសួរថា ឯងអញឲ្យប្រាក់ទៅនៅផ្ទះម៉ែឪឯងវិញ ហេតុម្ដេចក៏មិនទៅ ។

ឯអាផ្កាប់ត្រឡោកឆ្លើយជំរាបសេដ្ឋីថា ខ្ញុំបាទលើកអាល័យលោកម៉ែ លោកឪនឹងនាងជាកិរិយាខ្លាំងណាស់ សុំនៅទទួលដំណេកតែមួយយប់នេះទៀត ព្រឹកឡើងខ្ញុំបាទសូមប្រណិប័តន៍លាទៅផ្ទះវិញ ។

សេដ្ឋីប្តីប្រពន្ធនិយាយគ្នាថា យើងឲ្យវាដេកមួយយប់ទៀតចុះ វាមិនទាន់ជាអ្វីទេ ដូចជាដេកជាមួយនឹងប្រុសផងគ្នា លុះដល់ពេលយប់បរិភោគបាយរួចអាផ្កាប់ត្រឡោកក៏ចូលទៅដេកជាមួយនឹងកិរិយា ត្រឡោកក៏ផ្កាប់ដដែល នោះនាងកិរិយាដល់យប់ជ្រៅគិតថា យប់ស្អែកនេះប្ដីអញទៅនៅផ្ទះគាត់វិញហើយ អញចង់ស្ទាបសង្កេតឲ្យច្បាស់ ។ ឯអាផ្កាប់ត្រឡោកដេកផ្កាប់ពុំលក់កើតមានសេចក្ដីតំរេកជាខ្លាំង ប៉ះដូចជាគេទូលត្រឡោក នាងកិរិយានោះលូកដៃទៅប៉ះលើត្រឡោក ៗ ធ្លាក់ព្រួសរូវតែខូស អាផ្កាប់ត្រឡោកឆាកជានិចិតចូលទៅរួមសេន៍នឹងនាងកិរិយានោះ ដោយកំឡោះកំឡាំងក្លា កិរិយាក៏ក្រមុំរើរិតប្រតិព័ទ្ធគ្នាទៅវិញទៅមកពន់ប្រមាណ ។

លុះព្រឹកឡើងនាងនោះនិយាយដំកបមាតាថា ម៉ែបើប្ដីខ្ញុំលាទៅផ្ទះវិញ សូមម៉ែអាណិតកូនឃាត់កុំឲ្យទៅ មាតាសង្ស័យណាស់សួរកូន ៗ និយាយខ្សឹបដំកបមាតាថា ម៉ែប្ដីខ្ញុំគាត់មានប្រដាប់ដូចប្រុសទាំងពួងមិនមែនជាខ្ទើយឡើយ ។

ឯម្ដាយនោះដឹងចិត្តកូនហើយ ក៏ខ្សឹបនិយាយដំកបសេដ្ឋីជាប្ដីដោយស្ងាត់ថា កូនយើងទាំងពីរក់ត្រូវចិត្តគ្នាហើយ ។

សេដ្ឋីឮភរិយានិយាយប្រាប់ពីរឿងកូនសព្វគ្រប់ក៏តបថា កាលមុនគេហ៍ឯងនិយាយប្រាប់អញ ៗ ក៏ជឿថា ពិតមែន អញបានសងថ្លៃពស្ដុការបណ្ណាការទឹងថ្លៃផ្ទះមួយពាន់ប្រាំរយណែនឲ្យទៅក់ ឥឡូវថា កូនប្រុសយើងមានប្រដាប់ដូចប្រុសទាំងពួង ណ្ហើយចុះគេហ៍ បើក់ត្រូវចិត្តគ្នាហើយប្រាក់ដែលយើងឲ្យទៅកូនប្រុសនោះដូចជាឲ្យទៅកូនយើងទេ ប្ដីប្រពន្ធក៏មានក្រជាមួយគ្នា សេដ្ឋីក៏ស្ងៀមស្ងាត់កប៉ានជាកូនតរៀងទៅ ។

លុះដល់សេដ្ឋីប្ដីទឹងភរិយាចាស់ដកមរណភាពទៅវេលាណា ស្ដេចក្រុងព្រះនគរនោះទ្រង់ព្រះមេត្តាប្រោសតាំងអាផ្កាប់ត្រឡោកទឹងភរិយាឲ្យធ្វើជាសេដ្ឋីតាងបិតាលុះអស់ជីវិត ។

« រឿងអាផ្កាប់ត្រឡោកចប់តែប៉ុណ្ណោះ »

ឧកញ៉ាអក្ខរលេខា (ណុប) តែង ។

# ពិធីសូត្រមន្តរំដោះគ្រោះ

ឧកញ៉ាទេពពិទូរ ក្រសេម គន្ធរបនបណ្ឌិត

រៀបរៀង

# ទំនៀមសូត្រមន្តរំដោះគ្រោះ

អ្នកដែលមានជម្ងឺឈឺមកយូរថ្ងៃហើយ រកគ្រូព្យាបាលដូរនេះហើយ ដូរនោះហើយមិនជា គេរមែងរកគ្រូហោរ គន់គូរមើលហេតុដែលបណ្ដាល ឲ្យឈឺនោះ បើមើលទៅត្រូវថា មានគ្រោះថ្នាក់ នោះគេរមែងនិមន្តលោក មកសូត្រមន្តរំដោះគ្រោះនោះឲ្យបានសះជាស្បើយល្ហើយទៅ ។

ក្នុងកិច្ចនេះត្រូវរៀបរណ្ដាប់ផ្សេងៗ តាមទម្លាប់របស់គ្រូ-អាចារ្យដែល ធ្លាប់ធ្វើរៀងមក ក៏ទម្លាប់របស់គ្រូ-អាចារ្យនោះមិនដូចគ្នា, ខ្លះមានគ្រឿង ប្រដាប់ច្រើន ខ្លះមានគ្រឿងប្រដាប់តិចសមគួរ ។ ក្នុងទីនេះនឹងរៀប រៀងតាមបែបមធ្យម ល្មមឲ្យអ្នកទាល់ក្រធ្វើបានផងដូចមានតទៅនេះ-

ឲ្យរៀបគ្រឿងពុទ្ធបូជា គឺបាយសីប៉ាក់ឆាម ១ គូ ស្លាធម៌ ១ គូ ទឹក អប់ ១ គូ ទៀន ៥ ធូប ៥ លាជ ៥ ផ្កា ៥ ។

នឹងរៀបគ្រឿងបូជាទេវតា គឺស្លាធម៌ ៨ ទឹកអប់ ៨ ឲ្យរៀបដាក់ខាង ខ្លួនអ្នកជម្ងឺម្ខាង ៤ ។

នឹងធ្វើតែ ១ ហៅថា "តែមឈូស" បណ្ដាយប្រវែង ១ ហត្ថអ្នក ជម្ងឺ ទទឹងប្រវែង១ចំអាមអ្នកជម្ងឺ ឲ្យរៀបដាក់បាយ សំឡ ញាំ ភ្លា នំ ចំណី ក្នុងតែនោះតាមទំនៀម នឹងសូនរូប ១ ដោយម្សៅ គឺជារូបស្នងខ្លួនអ្នក ជម្ងឺឲ្យរៀបដាក់ក្នុងតែ, នឹងមានប្រឹស្សស្បូវស្ងួតប្រមាណ១ក្ដាប់ទុកនឹងដុតរូប នោះ ។ សំពត់សប្រវែង៥ហត្ថអ្នកជម្ងឺ ។ នឹងមានអង្ករវាល់ដោយនាឡិ

ឬដោយតានតូច ។ ចំនួនស្មើនឹងអាយុអ្នកជម្ងឺ បើមានសេសខែថ្ងៃប៉ុន្មាន ឲ្យកល់ប៉ុណ្ណោះដាក់ទៅទៀត ។ នឹងកល់ទឹកអប់សំបួរចំនួនដូចគ្នានេះដាក់ក្នុងផ្តិលធំ ១ នឹងមានពូនភ្នំខ្សាច់ ១ ដាក់នៅជាស ។

របស់អំបាលនេះឲ្យយកទៅរៀបដាក់នៅមុខកន្ទេលលោកសូត្រមន្ត ។ ដល់វេលានិមន្តលោកមកសូត្រមន្តមុននឹងសូត្រមន្តអាចារ្យរៀបសែនប្រ-បេរគ្រោះថ្នាក់នោះឲ្យស្បើយល្ហើយ ហើយយកភ្លើងអុចប្រឹមស្បូវដុតរូបមេព្យនោះជាបតិច្ចជា បានដុតរូបអ្នកជម្ងឺនោះហើយ ។ ហើយដូនពែនោះទៅតាមទិសដែលអាចារ្យបង្គាប់ ។

ពាក្យសែន

អញខ្ញុំសូមអញ្ជើញទេវតា នូវព្រះបរមេស្វរ ព្រះពិស្ណុការ ព្រះម្រឹត្យូវ, ព្រះកាល, ទើបអញ្ជើញព្រះអាទិត្យ ព្រះចន្ទ្រ, ព្រះអង្គារ, ព្រះពុធ, ព្រះព្រហស្បតិ៍, ព្រះសុក្រ, ព្រះសៅរ៍, ព្រះរាហូ, ព្រះកេតុ ។ ទើបអញ្ជើញនូវបូពិ-ព្រះភូមិ អគ្នេយ៍-ខរ, ទក្សិណ- ព្រះលក្ស្មណ៍, និរតី-កពណ៌, បស្ចិម-សិតា, ពាយព្យ សិតាយុ ឧត្តរ-ហាណុមាន, ឥសាណ-ពិភេក, ទើបអញ្ជើញអ្នកមកយកក្រយាបូជា អញខ្ញុំសូមស្មាហោទោស អ្នកហោង ។ ទោះឈើក្បាលក្បូរ ឈើក ឈើទ្រូង សាច់ស្លូតហឫទ័យ

ទោះឈើដើងដៃ សរសៃពេគា សូមស្មាលាទោសកុំអ្នកប្រកួត ទោះឈើ ថ្កាត់ចុះ រមួតរមួល ចង្អោរក្អែរក្អួត ទោះឈើដោតចាក់ ឈើច្បាក់សាច់ ស្ងួត បំពង់កស្ងួតខាន់ខះទឹកមាត់ ទើបអញ្ជើញអ្នក លំដោះគ្រោះដម្កាត់ ពេគាឲ្យបាត់វិនាសទៅហោង បពិត្រវិងថ្វាត់ ទៅដោយស្ពានទទៃ ហោង ឩម នមោ ពុទ្ធស្ស នមោ ធម្មស្ស នមោ សង្ឃស្ស ចុលោ ចុលោ ស្វាហាយ ចរណាយចេញទៅ ។

លំដាប់នោះគេរៀបសូត្រមន្ត គឺសូត្រធម៌យោងគ្រោះ តាមទម្លាប់ ដែលសូត្ររៀងមកហោង ។